RECONSTRUCTION, AN EXCEPTION THAT IS BECOMING A NORM

When we were invited to hold a conference on the topic of urban reconstruction, we quickly came to the view that "resilience" is the term that best describes the way in which certain cities, like Phnom Penh, were able to find the means to rebuild after large-scale destruction.
The notion of urban resilience refers to the capacity of cities and their inhabitants to recover from a traumatic event, to face a shock caused by a disaster, an exceptional and often violent event, which may result in destruction and death, the displacement of populations, the collapse of existing political and social structures, as well as major and long term trauma to individuals and societies.
Forty years after the expulsion of the entire urban population and the destruction of a significant part of Phnom Penh under the Khmer Rouge regime, the reconstruction of the Cambodian capital is a particularly uplifting example of the capacity for resilience of cities and urban societies.[1] However, while Phnom Penh stands alone for the violence of the Khmer Rouge's anti-urban policy, disasters and rebuilding issues affect an ever-growing number of cities around the world, to the point that urban reconstruction is gradually becoming a norm.
Indeed, the increasing frequency and impact of natural hazards, along with global warming, are leading to an acceleration in natural disasters. As a recent UN report has shown, 1.4 billion people around the world living in cities with more than 500,000 inhabitants are now exposed to at least one type of natural risk. In Asia in particular, as a recent study has shown, rising sea levels threatens many cities in the region, such as Jakarta, Bangkok or Ho Chi Minh City. In addition to these risks, the acceleration in urban growth (particularly on the African and Asian continents) is increasing the impact of natural hazards, and therefore the vulnerability of territories and populations.
In other words, the city has become a "high risk area", and the need for urban reconstruction an ever more present probability. Against this background, risk management and urban vulnerabilities have become absolute priorities for cities and should be central to urban development policies.

ANTICIPATING URBAN RECONSTRUCTION: RISKS AND VULNERABILITIES

The risk of a disaster or a traumatic event is very difficult to assess, because all risks remain theoretical and uncertain. Our attitude to risk is therefore based on what has happened in the past, on what could happen in the future, and on how we think about this uncertainty in the present. While large-scale disasters often seem inevitable, it is now accepted that the consequences of such disasters are never "exogenous" fatalities, but rather the outcome of our economic, technical, political and social structures. In fact, today we have the capacity to protect ourselves again climate disasters and hazards, or at least to largely mitigate their effects. That is why a risk management strategy is a crucial component of urban policies.

What is an urban risk management strategy? Risk management entails on the one hand looking forward to identify potential risks, and on the other identifying vulnerabilities to those risks. For example, to what extent can the existing drainage infrastructures cope with exceptional rainfall events? Which populations and areas are most exposed to potential risks? Urban vulnerabilities are complex to assess, because they are generally interdependent and mutually reinforcing. Reducing vulnerabilities is not only about lessening or preventing the impact of disasters, but also protecting the most vulnerable populations.

When risk becomes reality, one must already have developed the technical and institutional resources to manage the consequences of disasters, such as population movements or material destruction. Anticipating risk is about developing scenarios and action plans so as to respond to an emergency in an organised way.

Finally, a risk management policy must anticipate resilience. Because resilience is not innate: it is something that is built up and fed by public policies, by social and economic development programmes, by citizen action and participatory practices. This is particularly necessary as not everyone is equal when it comes to sudden urban changes caused by disasters. Since the poorest populations are those most vulnerable to disasters, they are the ones most called upon to "show resilience".

While a disaster is always sudden, risk management operates in multiple timeframes, both before, during and after the traumatic event. So vulnerability, risk and urban reconstruction refer to complex processes that demand systemic and global approaches, as much as more situated and targeted interventions.

APPROACHES TO RISK

How should one approach risk? There are three central factors that need to be mentioned here. First, risk management is political. It requires the implementation of public policies that can reduce vulnerabilities, develop appropriate regulatory frameworks and educate urban stakeholders (private, inhabitants, public) about risk management, in particular as risk is fed by individual and collective perceptions and behaviours in response to uncertainty.

Second, risk management is social. It must be understood as a community issue, and requires close collaboration between all urban stakeholders. Citizen participation is essential, because it facilitates awareness and implementation of appropriate solutions to the different forms of vulnerability that city dwellers may encounter. Economic status, education, living environment, along with social and family networks, will significantly determine the effect of disasters on populations, as well as the capacity of individuals to cope with them. Moreover, safety for one group may mean greater vulnerability for another. Equality in relation to vulnerabilities is a crucial factor in the construction of stable, durable and more egalitarian societies. For this reason, it is essential to implement public policies that target the most vulnerable groups in society.

Third, risk management is economic. Above all, it requires allocating funds to the identification of risks and vulnerabilities, to their reduction, and to their management if risk turns into reality. Economic investment, both public and political, needs to go into reducing vulnerabilities, particularly in the most disadvantaged populations. In consequence, risk management often requires us to change or adapt our models, which are still ill-suited to handling the "uncertain" nature of risk. Such changes include, for example, the introduction of legal and regulatory frameworks that place greater constraints on private actors, who also benefit from public risk reduction policies. Finally, risk management is economic because cities are increasingly exposed to recessions, to financial crises and to the bursting of speculative bubbles.

In other words, while resilience should be seen as a positive dynamic, it is not a choice, but a necessity in the face of sudden urban change. This is precisely why we need to improve our approach to and recognition of risk and vulnerabilities to natural disasters: to prevent destruction so that there is no need to rebuild, and therefore no need to be resilient.

RESILIENCE NARRATIVES

In the course of this conference, there have been many papers that have helped us to understand the pathways of urban reconstruction. From the first hours to the first years of the reconstruction process, the accounts given by H.E. Thong Khong and H.E. Mok Mareth demonstrate how, in Phnom Penh, every minor initiative counted in the restoration of institutions and governance. Their accounts illustrate how many challenges had to be tackled simultaneously, such as insecurity, disease, the re-establishment of a public administration, the shortage of schools and teachers, the reactivation of commerce, and food production and supplies to the city. In this regard, the story of the Phnom Penh Water Board reconstructed by H.E. Ek Sonn Chan perfectly illustrates the challenges of reactivating infrastructures and developing methods of managing and supplying resources.

For their part, the papers given by Nak Moneang Men Chandevy and Fabienne Luco retrace a largely neglected aspect of urban reconstruction in Phnom Penh (as elsewhere): the story of the inhabitants, who had to adapt, develop community networks and exercise ingenuity in order to survive and rebuild their lives. In these circumstances, informality is not an anomaly, but the primary raw material of resilience. These narratives are in counterpoint with the story told by Jean Marie Théodat who, through the example of Port-au-Prince, showed how the absence of effective public governance has the effect of further increasing the fragility of the most vulnerable population groups.

In Phnom Penh, as H.E. Mann Choeun explained, managing neighbourhoods that were considered "informal" became a major preoccupation of the public authorities from the early 1990s. The removal of populations living in informal housing areas in the city centre, and their resettlement in the outskirts, took place through coordination between the public authorities and local associations. Regarding these groups, however, questions remain: does the possibility of owning property really represent the primary condition for socio-economic development? Is not household vulnerability exacerbated by forced uprooting and relocation to areas remote from centres of economic activity?

H.E. Kep Chuktema, H.E. Pa Socheat Vong and Vannak Seng from Phnom Penh Municipality, and Christiane Blancot from APUR, gave important accounts about how the issues of urban reconstruction have changed over the last 30 years. While the development and maintenance of infrastructures were a priority in the 1990s, the 2000s have seen a shift in emphasis towards different questions such as landownership, governance (with the introduction of decentralisation policies), transport or urban planning. Today, big urban projects (e.g. satellite cities) and rapid urban growth testify to the vitality of the Cambodian capital. As many speakers, for example Natharoun Ngo, have pointed out, the interaction between a dynamic real estate market and the adoption of internationalised models of development, such as the smart city, are significant drivers of current urban transformations. However, as Chan San Hun recalled, in relation to architecture, the aim is not to erase the past and start from scratch, but rather to integrate these innovations into the long timescales of city-making. The account by Nadine Umutoni Gatsinzi, Deputy Mayor of Kigali, shows us how these urban development policies needed to be linked with social policies for poverty reduction and against corruption, which have made the capital of Rwanda a model to be followed in Africa and around the world. Social development, inclusion and citizen participation are essential ingredients of resilience. As Hassan Hajam clearly explained, they can effect essential changes in existing economic models.

Placed end to end, the many accounts heard in the course of this conference and transcribed into this book weave a genuine "oral history" of urban reconstruction, a history summarised by Lionel Prigent at the end of this text. These stories are all the more important in that they fill a gap in our knowledge of these very sudden and turbulent episodes in the history of cities and individuals. Once written down, this oral history can become memory and thereby help to guide contemporary policies for the management of urban risk and the reduction of vulnerabilities.

1. See in particular: Carrier A., 2007, *Les "lois de la possession" à Phnom Penh: conversion des droits d'usage résidentiel issus du contexte socialiste de réappropriation urbaine (1979-1989) en droits de propriété*, thèse de doctorat, Architecture, Université Paris 8, 599 p.; Pierdet C., 2008, *Les temporalités de la relation ville-fleuve à Phnom Penh: la fixation d'une capitale fluviale par la construction d'un système hydraulique (1865-2005)*, thèse de doctorat, Géographie, Université de Paris 1 Panthéon-Sorbonne, 589 p.; Fauveaud G., 2015, *La production des espaces urbains à Phnom Penh. Pour une géographie sociale de l'immobilier*, Paris, Publications de la Sorbonne, 368 p.

© Gabriel Fauvaud

Phnom Penh, habitat précaire sur un site inondable.

Precarious housing in a flood zone.

ទីក្រុងភ្នំពេញ លំនៅដ្ឋានមិនមាំទាំនៅក្នុងទីតាំងអាចលិចទឹក

ទីក្រុងមានភាពធន់៖ គិតអំពីបញ្ហាប្រឈមនៃការកសាងទីក្រុងឡើងវិញ

អង្គមហាសន្និបាតលើកទី៣៩នៃសមាគម AIMF នេះ គឺជាឱកាសមួយដ៏សំខាន់ ដែលអនុញ្ញាតឲ្យយើងត្រឡប់មកពិចារណាទៅលើដំណើរការនៃការកសាងទីក្រុងភ្នំពេញឡើងវិញ ៤០ឆ្នាំក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅ និងបន្ទាប់ពីចេតនារបស់ពួកខ្មែរក្រហមក្នុងការលុបបំបាត់ទីក្រុង។ ក្រៅពីការនិយាយអំពីទីក្រុងខ្មែរ សក្ខីកម្មអំពីទីក្រុងគីហ្គាលី ឬទីក្រុងព័រអូប្រាំងស៍ ក៏ត្រូវបានធ្វើឡើងដែរ ដើម្បីធ្វើឲ្យការពិភាក្សាកាន់តែមានភាពផុលផុសនិងសម្បូរបែបថែមទៀត។

ដោយលោក **GABRIEL FAUVEAUD,** សាស្ត្រាចារ្យជំនួយនៃសាលកវិទ្យាល័យម៉ុងត្រេអាល់

ការកសាងឡើងវិញគឺជាករណីពិសេសដែលកំពុងក្លាយទៅជាបទដ្ឋានមួយ

នៅពេលដែលយើងខ្ញុំត្រូវបានអញ្ជើញឲ្យរៀបចំសន្និសីទមួយស្តីអំពីប្រធានបទនៃការកសាងឡើងវិញ ពាក្យ **ភាពធន់** យើងខ្ញុំយល់ថាគឺជាពាក្យដែលសមរម្យជាងគេ ដើម្បីពិពណ៌នាអំពីរបៀបដែលទីក្រុងមួយចំនួន ដូចជាទីក្រុងភ្នំពេញ ចេះស្វែងរកមធ្យោបាយដើម្បីកសាងខ្លួនឡើងវិញ បន្ទាប់ពីមានការបំផ្លិចបំផ្លាញមួយក្នុងទ្រង់ទ្រាយធំ។

សញ្ញាណនៃភាពធន់ទីក្រុង គឺសំដៅទៅសមត្ថភាពនៃទីក្រុង និងសមត្ថភាពរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងទីក្រុង ចេះងើបឈរឡើងវិញ បន្ទាប់ពីបានឆ្លងកាត់ព្រឹត្តិការណ៍ដ៏គ្រាំគ្រាមួយ ចេះប្រឈមមុខទៅនឹងការប៉ះទង្គិច ដែលបង្កឡើងដោយគ្រោះមហន្តរាយ ឬដោយព្រឹត្តិការណ៍ពិសេសណាមួយ ហើយព្រឹត្តិការណ៍ទាំងនោះ ជាទូទៅ មានវិសាលភាពធំ អាចបង្កឲ្យមានការខូចខាតធ្ងន់ធ្ងរ និងសម្លាប់ជីវិតមនុស្សច្រើននាក់ ធ្វើឲ្យប្រជាជនត្រូវធ្វើបន្លាស់ទី ធ្វើឲ្យរចនាសម្ព័ន្ធនយោបាយនិងសង្គមដែលមានស្រាប់ចុះទន់ខ្សោយ ព្រមទាំងបង្កភាពគ្រាំគ្រាយ៉ាងខ្លាំងទៅលើប្រជាជននិងសង្គម នៅក្នុងរយៈពេលមួយដ៏វែង។

រយៈពេល៤០ឆ្នាំ ក្រោយពីមានការជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុង និងការបំផ្លិចបំផ្លាញមួយផ្នែកធំនៃទីក្រុងភ្នំពេញ ដោយពួកខ្មែរក្រហម ការកសាងទីក្រុងខ្មែរឡើងវិញ គឺជាឧទាហរណ៍ដ៏ល្អពិសេសមួយបង្ហាញពីសមត្ថភាព ភាពធន់នៃទីក្រុង និងសង្គមរស់នៅក្នុងទីក្រុង[1]។ ប៉ុន្តែថ្វីត្បិតថា ទីក្រុងភ្នំពេញជាករណីពិសេសមួយ ដោយសារហឹង្សានៃគោលនយោបាយប្រឆាំងនឹងទីក្រុងរបស់ពួកខ្មែរក្រហម ក៏ប៉ុន្តែគ្រោះមហន្តរាយនិងបញ្ហានៃការកសាងទីក្រុងឡើងវិញនៅកន្លែងផ្សេងទៀត ពិតជាមានចំនួនកាន់តែច្រើនឡើងៗនៅក្នុងពិភពលោក រហូតដល់យើងអាចនិយាយបានថាការកសាងទីក្រុងឡើងវិញបានក្លាយបន្តិចម្តងៗជាបទដ្ឋានមួយ។

ពិតមែនហើយ ការកើនឡើងនូវសង្វាក់និងកម្លាំងនៃភាពមិនប្រាកដប្រជាធម្មជាតិ ក៏ដូចជាការកើនឡើងនូវកំដៅធម្មជាតិ បណ្តាលឲ្យមានការពន្លឿននៃព្រឹត្តិការណ៍គ្រោះមហន្តរាយ។ ដូចដែលរបាយការណ៍ថ្មីមួយរបស់អង្គការសហប្រជាជាតិបានបង្ហាញហើយថា មនុស្សចំនួន១,៤ពាន់លាននាក់នៅក្នុងពិភពលោក កំពុងរស់នៅក្នុងទីក្រុងដែលមានប្រជាជនលើសពី៥០ម៉ឺននាក់ បច្ចុប្បន្ននេះ ពួកគេកំពុងប្រឈមមុខយ៉ាងហោចណាស់ទៅនឹងហានិភ័យនៃគ្រោះធម្មជាតិមួយប្រភេទ ជាពិសេស នៅអាស៊ី ដូចដែលការសិក្សាស្រាវជ្រាវថ្មីមួយទៀតបានបង្ហាញដូចគ្នាដែរថា ការកើនឡើងនៃកម្រិតទឹកកំពុងគំរាមកំហែងទីក្រុងជាច្រើននៅក្នុងតំបន់នេះ ដូចជាទីក្រុងហ្សាការតា ទីក្រុងបាងកក ឬទីក្រុងហូជីមិញជាដើម។ បន្ថែមពីលើហានិភ័យទាំងនេះទៀត កំណើនប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងកាន់តែខ្លាំង (ជាអាទិ៍ នៅទ្វីបអាហ្វ្រិក និងអាស៊ី) កាន់តែបង្កើនវិសាលភាពនៃភាពមិនប្រាកដប្រជា ដូច្នេះ ក៏ទៅលើភេទនីយភាពនៃទីក្រុង និងប្រជាពលរដ្ឋផងដែរ។

បើនិយាយបែបម្យ៉ាងវិញទៀត ទីក្រុងបានក្លាយទៅជា "ដែនដីនៃហានិភ័យ" ហើយការកសាងទីក្រុងឡើងវិញកាន់តែមានលក្ខណៈភវនីយភាពខ្លាំងឡើងៗ។ នៅក្នុងបរិបទនេះ ម្យ៉ាង ការគ្រប់គ្រងហានិភ័យ និងម្យ៉ាងទៀតភេទនីយភាពនៃទីក្រុងបានក្លាយទៅជាអាទិភាពដាច់ខាតសម្រាប់ទីក្រុង ហើយគួរតែដាក់បញ្ចូលទៅក្នុងបេះដូងនៃគោលនយោបាយអភិវឌ្ឍន៍ក្រុង។

គិតគូរពីការកសាងឡើងវិញ គឺគិតគូរពីហានិភ័យនិងភេទនីយភាព

ហានិភ័យនៃការកើតមានគ្រោះមហន្តរាយ ឬព្រឹត្តិការណ៍បង្កភាពគ្រាំគ្រាណាមួយនោះ គឺយើងពិបាកនឹងដឹងខ្លាំងណាស់ ពីព្រោះថា រាល់ហានិភ័យ គឺតែងតែស្ថិតនៅក្នុងវិស័យនៃទ្រឹស្តី និងមិនប្រាកដប្រជាឡើយ ។ ដូច្នេះ ទំនាក់ទំនងរបស់យើងជាមួយហានិភ័យ គឺធ្វើឡើងដោយយោងទៅលើអ្វីដែលធ្លាប់បានកើតឡើងកន្លងរួចទៅហើយក្នុងអតីតកាល ទៅលើអ្វីដែលអាចនឹងកើតឡើងនៅក្នុងថ្ងៃអនាគត ព្រមទាំងទៅលើរបៀបដែលយើងគិតគូរពីភាពមិនប្រាកដប្រជាទាំងនេះនៅក្នុងបច្ចុប្បន្នកាល។ ថ្វីត្បិតថា ជាញឹកញាប់គ្រោះមហន្តរាយដែលមានវិសាលភាពធំ គេហាក់ដូចជាមិនអាចគេចផុត ក៏ប៉ុន្តែ បច្ចុប្បន្ននេះ គេទទួលស្គាល់ថា ផលវិបាកនៃគ្រោះមហន្តរាយទាំងនោះមិនមែនមកពីកម្មព្រេងវាសនាបង្កឡើងដោយកត្តាខាងក្រៅនោះទេ ផ្ទុយទៅវិញវាច្រើនតែជាផលិតផលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច បច្ចេកទេស នយោបាយ និងសង្គមរបស់យើងទៅវិញទេ។ ពិតមែនហើយ បច្ចុប្បន្ននេះ យើងមានសមត្ថភាពការពារខ្លួនយើង ទប់ទល់នឹងគ្រោះមហន្តរាយ និងភាពមិនប្រាកដប្រជានៃអាកាសធាតុ ឬក៏យ៉ាងហោចណាស់ អាចកាត់បន្ថយយ៉ាងច្រើននូវផលប៉ះពាល់បណ្តាលមកពីគ្រោះមហន្តរាយទាំងនោះដែរ។ ហេតុដូច្នេះហើយបានជាគោលនយោបាយក្រុង មិនអាចខ្វះគោលនយោបាយគ្រប់គ្រងហានិភ័យបានទេ។

តើគោលនយោបាយគ្រប់គ្រងហានិភ័យក្រុងជាអ្វី ? មុនគេបង្អស់គឺថា ម្យ៉ាង ការគ្រប់គ្រងហានិភ័យត្រូវឆ្លងកាត់តាមការគិតឱ្យឃើញពីហានិភ័យដែលអាចកើតមានឡើងជាយថាហេតុ និងម្យ៉ាងទៀត រកឲ្យឃើញនូវភេទនីយភាពនៅចំពោះមុខហានិភ័យទាំងនោះ។ ឧទាហរណ៍ តើហេដ្ឋារចនាសម្ព័ន្ធនៃលូបង្ហូរទឹកសព្វថ្ងៃនេះអាចទ្រាំទ្រកម្លាំងទឹកភ្លៀង ក្នុងរដូវដែលមានភ្លៀងធ្លាក់ច្រើនខ្លាំងហួសប្រមាណដល់កម្រិតណា ? តើប្រជាពលរដ្ឋណា និងទីតាំងណាខ្លះដែលប្រឈមមុខខ្លាំងជាងគេ ទៅនឹងហានិភ័យជាយថាហេតុទាំងនោះ ? ភេទនីយភាពនៃទីក្រុងពិតជាស្មុគស្មាញ ពិបាកនឹងយល់ណាស់ ពីព្រោះកត្តាភេទនីយភាពទាំងនោះ ជាទូទៅ ពឹងផ្អែកគ្នាទៅវិញទៅមក ហើយក៏បំពេញឲ្យគ្នាទៅវិញទៅមកដែរ។ កាត់បន្ថយភេទនីយភាព គឺមានន័យថា មិនត្រឹមតែកាត់បន្ថយ ឬត្រៀមបង្ការផលប៉ះពាល់នៃគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការពារប្រជាពលរដ្ឋទន់ខ្សោយជាងគេផងដែរ។

នៅពេលដែលហានិភ័យកើតឡើងជាក់ស្តែង មុននឹងហានិភ័យមកដល់ទៅទៀតនោះ គេត្រូវមានមធ្យោបាយបច្ចេកទេស និងស្ថាប័ន ដើម្បីគ្រប់គ្រងផលវិបាកបង្កឡើងដោយគ្រោះមហន្តរាយ ដូចជា គ្រប់គ្រងបញ្ហាបន្លាស់ទីរបស់ប្រជាពលរដ្ឋ ឬការខូចខាតហេដ្ឋារចនាសម្ព័ន្ធជាដើម។ បង្ការហានិភ័យ គឺមានន័យថា រៀបចំបង្កើតសេណារីយោ និងផែនការសកម្មភាពដែលអនុញ្ញាតឲ្យយើងឆ្លើយតបតាមបែបមួយ ដែលមានការរៀបចំត្រឹមត្រូវទុកជាមុននៅក្នុងករណីបន្ទាន់។

ចំណុចចុងក្រោយ គោលនយោបាយគ្រប់គ្រងហានិភ័យត្រូវតែគិតគូរទុកជាមុនពីភាពធន់ ពីព្រោះថា គោលនយោបាយនេះ មិនមែនកើតឡើងដោយឯកឯងនោះទេ មានន័យថា គោលនយោបាយនេះ យើងត្រូវកសាងឡើង និងទទួលការគាំទ្រពីគោលនយោបាយសាធារណៈ កម្មវិធីអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ច សកម្មភាពរបស់ប្រជាពលរដ្ឋ និងការអនុវត្តមួយបែបចូលរួម។ គោលនយោបាយនេះ រឹតតែសំខាន់ និងចាំបាច់ថែមទៀត ដោយហេតុថាយើងទាំងអស់គ្នា ទាំងស្រីទាំងប្រុស គ្មានសមត្ថភាពស្មើគ្នាទេ នៅចំពោះមុខការផ្លាស់ប្តូរដ៏គំហុកនៃទីក្រុង ដែលបង្កឡើងដោយគ្រោះមហន្តរាយ។ ប្រជាពលរដ្ឋក្រីក្រជាងគេ គឺជាអ្នកដែលមានភេទនីយភាពជាងគេនៅចំពោះមុខគ្រោះមហន្តរាយ គឺប្រជាពលរដ្ឋក្រីក្រជាងគេទាំងនេះហើយដែលរឹតតែត្រូវបង្ហាញឲ្យឃើញនូវសមត្ថភាពធន់ជាងគេ។

ពិតមែនហើយថា គ្រោះមហន្តរាយតែងតែកើតឡើងគំហុកភ្លាមៗ ប៉ុន្តែការគ្រប់គ្រងហានិភ័យ គឺត្រូវធ្វើឡើងទៅតាមពេលវេលា និងដំណាក់កាលច្រើន ពោលគឺមុនពេលព្រឹត្តិការណ៍កើតឡើង ក្នុងពេលព្រឹត្តិការណ៍កើតឡើង និ ងបន្ទាប់ពីមហន្តរាយកើតឡើង។ ដូច្នេះ ភេទនីយភាព ហានិភ័យ និងការកសាងឡើងវិញ គឺសំដៅទៅដំណើរការមួយដ៏ស្មុគស្មាញមួយ ដែលតម្រូវឲ្យមានវិធីសាស្រ្តស្វ័យប្រវត្តិ និងជារួម ក៏ដូចជាអន្តរាគមន៍ឲ្យចំគោលដៅ។

ចំណាត់ការចំពោះហានិភ័យ

តើត្រូវធ្វើចំណាត់ការបែបណា ក្នុងពេលមានហានិភ័យ ? មានចំណុច៣ សំខាន់ៗ ដែលត្រូវលើកយកមកបង្ហាញជូននៅពេលនេះ។ ចំណុចទី១ ការគ្រប់គ្រងហានិភ័យគឺជារឿងនយោបាយ។ ចំណុចនេះ តម្រូវឲ្យមានការអនុវត្តគោលនយោបាយសាធារណៈមួយ ដែលអនុញ្ញាតឲ្យកាត់បន្ថយភេទនីយភាព បង្កើតក្របខណ្ឌច្បាប់សមស្រប និងចលនាដៃគូក្រុងទាំងអស់ ទាំងឯកជន ប្រជាពលរដ្ឋ និងរដ្ឋ ឱ្យចូលរួមក្នុងការគ្រប់គ្រងហានិភ័យ ពីព្រោះថាហានិភ័យគឺពាក់ព័ន្ធទៅនឹងការយល់ឃើញ និងឥរិយាបទរបស់បុគ្គលនីមួយៗ ក៏ដូចជាឥរិយាបទរបស់មនុស្សរួមគ្នានៅចំពោះមុខភាពមិនប្រាកដប្រជា។

ចំណុចទី២ ការគ្រប់គ្រងហានិភ័យគឺជារឿងសង្គម។ ចំណុចនេះគួរត្រូវបានយល់ថា ហានិភ័យគឺជាបញ្ហារួមគ្នា និងតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងដៃគូក្រុងទាំងអស់។ ការចូលរួមពីប្រជាពលរដ្ឋគ្រប់រូបគឺជារឿងសំខាន់បំផុត ពីព្រោះការចូលរួមបែបនេះបង្កឱ្យមានការយល់ដឹងយ៉ាងទូលំទូលាយ និងសម្រួលការលើកសំណើដំណោះស្រាយសមស្របសម្រាប់គ្រប់ប្រភេទនៃភេទនីយភាពដែលប្រជាជនក្រុងអាចជួបប្រទះ។ ស្ថានភាពសេដ្ឋកិច្ច អប់រំ ទីកន្លែងរស់នៅ ឬក៏បណ្តាញសង្គម និងគ្រួសារ សុទ្ធតែចូលរួមកំណត់យ៉ាងទូលំទូលាយនូវផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើប្រជាពលរដ្ឋព្រមទាំងសមត្ថភាពនៃបុគ្គល ប្រឈមមុខនឹងគ្រោះមហន្តរាយ។ ម្យ៉ាងវិញទៀតសុវត្ថិភាពរបស់មនុស្សមួយក្រុមអាចនឹងបង្កើនភេទនីយភាពរបស់មនុស្សមួយក្រុមផ្សេងទៀត។ សមធម៌នៅចំពោះមុខភេទនីយភាពគឺជារឿងមួយដ៏សំខាន់បំផុតនៅក្នុងការកសាងសង្គមទីក្រុងមួយដែលមានស្ថិរភាព មាននិរន្តរភាព និងមានសមភាពខ្លាំងជាងមុន។ ដូច្នេះ ការដាក់ចេញនូវគោលនយោបាយសាធារណៈផ្តោតទៅលើប្រជាពលរដ្ឋដែលមានភេទនីយភាពជាងគេ មើលទៅគឺជារឿងចាំបាច់ខានមិនបាន។

ចំណុចទី៣ ការគ្រប់គ្រងហានិភ័យគឺជារឿងសេដ្ឋកិច្ច។ ជាបឋម ចំណុចនេះតម្រូវឱ្យមានកញ្ចប់ថវិកាប្រើសម្រាប់រកឱ្យឃើញនូវហានិភ័យនិងភេទនីយភាព សម្រាប់ការកាត់បន្ថយនិងគ្រប់គ្រងហានិភ័យទាំងនោះ ក្នុងករណីដែលគ្រោះមហន្តរាយកើតឡើង។ វិនិយោគសាធារណៈ គោលនយោបាយសេដ្ឋកិច្ច ត្រូវតែអនុវត្តដើម្បីជាប្រយោជន៍នៃការកាត់បន្ថយភេទនីយភាព ជាពិសេស ភេទនីយភាពប្រជាពលរដ្ឋដែលក្រីក្រជាងគេ។ ជាលទ្ធផល ការគ្រប់គ្រងហានិភ័យ ជាញឹកញ៉យ តម្រូវឲ្យមានការផ្លាស់ប្តូរ ឬការសម្របសម្រួលគម្រូសេដ្ឋកិច្ចរបស់យើង ដែលនៅតែពិបាកនឹងបញ្ចូលលក្ខណៈ "មិនប្រាកដប្រជា" នៃហានិភ័យនៅឡើយ។ ការផ្លាស់ប្តូរទម្លាប់នេះជាឧទាហរណ៍ តម្រូវឲ្យមានការដាក់ចេញនូវក្របខណ្ឌច្បាប់ និងបទបញ្ជាកាន់តែមានភាពតឹងតែងជាងមុន ចំពោះវិស័យឯកជន ដែលក៏ជាអ្នកទទួលបានផលពីនយោបាយសាធារណៈ លើការកាត់បន្ថយហានិភ័យដែរ។

ចំណុចចុងក្រោយ ការគ្រប់គ្រងហានិភ័យគឺជារឿងសេដ្ឋកិច្ច ពីព្រោះថា ទីក្រុងប្រឈមមុខកាន់តែខ្លាំងឡើងទៅនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ច ទៅនឹងវិបត្តិហិរញ្ញវត្ថុ និងការកើនឡើងយ៉ាងខ្លាំងនៃការទិញទុកសម្រាប់លក់។ បើនិយាយតាមបែបផ្សេងវិញ ថ្វីត្បិតថា ភាពធន់ត្រូវបានចាត់ទុកដូចជាថាមភាពវិជ្ជមាន ប៉ុន្តែភាពធន់មិនមែនជាជម្រើសនោះទេ មានន័យថា ភាពធន់គឺជារឿងចាំបាច់ ត្រូវធ្វើទីក្រុងឱ្យមានភាពធន់ នៅចំពោះមុខបម្រែបម្រួលក្រុងដ៏គំហុកនិងបន្ទាន់។ ដូច្នេះ គឺវិធីសាស្រ្តមួយល្អជាងមុន និងការគិតគូរអំពីហានិភ័យនិងភេទនីយភាពនៅចំពោះមុខគ្រោះមហន្តរាយទាំងនោះហើយ ដែលនាំមកនូវប្រយោជន៍ដល់ការគ្រប់គ្រងហានិភ័យ ពោលគឺការពារឲ្យបានកុំឲ្យមានការខូចខាត មិនចាំបាច់កសាងឡើងវិញ ដូច្នេះមានន័យថា មិនចាំបាច់មានភាពធន់។

ការរៀបរាប់អំពីភាពធន់

នៅក្នុងសន្និសីទនេះ បទបង្ហាញជាច្រើនបានអនុញ្ញាតឲ្យយើងយល់កាន់តែច្បាស់អំពីគន្លងផ្លូវនៃការកសាងទីក្រុងឡើងវិញ។ ចាប់ពីនាទីដំបូងនៅក្នុងឆ្នាំដំបូងនៃការកសាងឡើងវិញ សក្ខីកម្មរបស់ឯកឧត្តម ថោង ខុន និងឯកឧត្តម ម៉ុក ម៉ារ៉េត បានបង្ហាញថា តើនៅទីក្រុងភ្នំពេញ រាល់គំនិតផ្តួចផ្តើមតូចតាចនីមួយៗ មានសារៈសំខាន់យ៉ាងណា នៅក្នុងការធ្វើឲ្យស្ថាប័ននានា និងអភិបាលកិច្ចចាប់ផ្តើមដំណើរការឡើងវិញ។ ការរៀបរាប់របស់ឯកឧត្តមទាំងពីរបានឆ្លុះបញ្ចាំងថា តើបញ្ហាប្រឈមជាច្រើនត្រូវបានគ្រប់គ្រងដោយរបៀបណា ដូចជា បញ្ហាអសន្តិសុខ ជំងឺដង្កាត់ ការបង្កើតឡើងវិញនូវរដ្ឋបាលសាធារណៈ កង្វះខាតសាលារៀននិងគ្រូបង្រៀន ការចាប់ផ្តើមឡើងវិញនូវការលក់ដូរ ឬក៏ការផលិតម្ហូបអាហារ និងការផ្គត់ផ្គង់ស្បៀងដល់រដ្ឋធានីជាដើម។ នៅក្នុងន័យដូចគ្នានេះដែរ ប្រវត្តិរដ្ឋាករស្វយ័តទឹកក្រុងភ្នំពេញ ដែលរៀបរាប់ដោយឯកឧត្តមឯក ស៊ុនចាន់ ពិតជាបង្ហាញយ៉ាងល្អពិសេសអំពីបញ្ហាប្រឈមនៃការដាក់ឲ្យដំណើរការឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងការវិវឌ្ឍនៃរបៀបគ្រប់គ្រងការផ្គត់ផ្គង់ធនធានទឹក។

បទអន្តរាគមន៍របស់អ្នកម្នាង ស៊ីសុវត្ថិ ម៉ែន ចាន់ទេវី និងលោកស្រីហ្វាប៊ីយែន លុយកូ រៀបរាប់អំពីប្រវត្តិរឿងរ៉ាវមួយដែលមិនសូវមានគេសរសេរឡើយ គឺប្រវត្តិនៃការកសាងទីក្រុងភ្នំពេញឡើងវិញ (ដូចទីក្រុងផ្សេងទៀតដែរ) នោះគឺប្រវត្តិរឿងរ៉ាវរបស់ប្រជាពលរដ្ឋដែលត្រូវសម្របខ្លួន បង្កើតជាខ្សែបណ្តាញសាមគ្គីគ្នា បង្ហាញឲ្យឃើញនូវគំនិតច្នៃប្រឌិត ដើម្បីប្រឹងរស់ និងបង្កើតគំនិតច្នៃប្រឌិតថ្មីៗ។ នៅក្នុងបរិបទនេះ អ្វីដែលក្រៅផ្លូវការមិនមែនជារឿងមិនធម្មតានោះទេ ប៉ុន្តែគឺជាប្រភពធនធានសំខាន់នៃភាពធន់។ ប្រវត្តិរឿងរ៉ាវទាំងនេះឆ្លុះបញ្ចាំងអំពីប្រវត្តិរឿងរ៉ាវដែលរៀបរាប់ដោយលោក ហ្សង់ម៉ារី តេអូដាដោយផ្តើមចេញពីឧទាហរណ៍នៃទីក្រុង ព័រអូប្រាំងស៍ ថាតើអវត្តមាននៃអភិបាលកិច្ចសាធារណៈប្រកបដោយប្រសិទ្ធភាពមួយ ធ្វើឲ្យប្រជាពលរដ្ឋក្រីក្រធ្លាក់ចូលទៅក្នុងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើងយ៉ាងដូចម្តេច។ នៅទីក្រុងភ្នំពេញ ដូចដែលឯកឧត្តម ម៉ាន់ ឈឿន បានពន្យល់ដូច្នោះដែរថា ការគ្រប់គ្រងសង្កាត់ទាំងឡាយដែលត្រូវបានចាត់ទុកថាជាសង្កាត់ "ក្រៅផ្លូវការ" គឺជាក្តីបារម្ភយ៉ាងខ្លាំងរបស់អាជ្ញាធររដ្ឋ តាំងពីដើមដំបូងនៃទសវត្សរ៍ឆ្នាំ១៩៩០មកម្ល៉េះ។ ការបញ្ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់អាណាធិបតេយ្យក្នុងទីក្រុង ឲ្យទៅរស់នៅក្នុងទីតាំងថ្មី តាមជាយក្រុង ត្រូវបានធ្វើឡើងដោយមានការសម្របសម្រួលជាមួយអាជ្ញាធរសាធារណៈ និងសមាគមក្នុងស្រុក។ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋទាំងនោះ នៅតែមានចំណោទសំណួរជាច្រើន ដូចជាថា តើការទទួលបាននូវកម្មសិទ្ធិដីធ្លី គឺជាលក្ខខណ្ឌពិតប្រាកដនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចឬទេ ? អថាវរភាពរបស់ក្រុមគ្រួសារប្រជាពលរដ្ឋមិនកាន់តែធ្ងន់ធ្ងរទៀតទេឬ ? ដោយសារតែការផ្តាច់ឫសគល់របស់ពួកគេដោយបង្ខំ និងការទៅតាំងទីលំនៅថ្មីក្នុងដែនដីមួយដែលនៅឆ្ងាយពីបេះដូងនៃសកម្មភាពសេដ្ឋកិច្ច ? ឯកឧត្តម កែប ជុតិមា ឯកឧត្តម ប៉ា សុជាតិវង្ស និងលោក សេង វណ្ណៈ មកពីសាលារាជធានីភ្នំពេញ ព្រមទាំងលោកស្រី គ្រីស្ទ៉ាន ប្លង់កូ មកពីអង្គភាព APUR ទីក្រុងប៉ារីស ក៏បានផ្តល់នូវសក្ខីកម្មសំខាន់ៗផងដែរ ស្តីពីការវិវឌ្ឍនៃការកសាងទីក្រុងឡើងវិញ ក្នុងរយៈពេលជាង៣០ឆ្នាំចុងក្រោយនេះ។ ថ្វីបើការអភិវឌ្ឍនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធគឺជាអាទិភាពមួយក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ក៏ប៉ុន្តែ គឺនៅទសវត្សរ៍ឆ្នាំ២០០០ប៉ុណ្ណោះ ទើបមានអន្តរាគមន៍ទៅលើវិស័យផ្សេងទៀត ដូចជា កម្មសិទ្ធិដីធ្លី អភិបាលកិច្ច (ការដាក់ចេញនូវគោលនយោបាយវិមជ្ឈការ) ការដឹកជញ្ជូន ឬការធ្វើផែនការក្រុង ជាដើម។

បច្ចុប្បន្ននេះ គម្រោងក្រុងធំៗ ដូចជាក្រុងរណបជាដើម ព្រមទាំងកំណើនប្រជាពលរដ្ឋខ្លាំងនៅក្នុងក្រុង ពិតជាបង្ហាញពីភាពសកម្ម រស់រវើកនៃរាជធានីកម្ពុជា។ ដូចដែលវាគ្មិនជាច្រើន ឧទាហរណ៍ លោក ង៉ោ ណត្តរុនបានរំលឹកឡើងវិញរួចហើយថា អន្តរកម្មរវាងទីផ្សារអចលនទ្រព្យប្រកបដោយថាមភាព និងការអនុម័តយកតាមគំរូនៃការអភិវឌ្ឍបែបអន្តរជាតិ ដូចជាទីក្រុងឆ្លាតវៃជាដើម គឺតំណាងឲ្យចលករដ៏សំខាន់មួយនៃរូបបរិវត្តន៍ទីក្រុងបច្ចុប្បន្ននេះ។ ដូចដែលលោក ចាន់ សាន់ហ៊ុន ផ្តល់ជាសាក្សីស្រាប់អំពីស្ថាបត្យកម្ម គឺផ្ទុយទៅវិញ មិនមែនជាការបំផ្លាញអតីតកាលនោះទេ ប៉ុន្តែគឺបញ្ចូលនវានុវត្តភាពទាំងនេះទៅក្នុងរយៈពេលវែងនៃការកសាងទីក្រុង។

សក្ខីកម្មរបស់លោកជំទាវ ណាឌីន អ៊ុមុតូនី ហ្កាត់ស៊ីនហ្ស៊ីអភិបាលរងក្រុង គីហ្កាលី បង្ហាញយើងថា តើគោលនយោបាយអភិវឌ្ឍន៍ក្រុងទាំងនេះត្រូវផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយសង្គម ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងអំពើពុករលួយដោយរបៀបណា ដែលធ្វើឲ្យរដ្ឋធានីប្រទេស រ៉្វាន់ដា មួយនេះ ក្លាយជាឧទាហរណ៍មួយគួរយកគំរូតាមនៅទ្វីបអាហ្វ្រិក ក៏ដូចជានៅក្នុងពិភពលោកទាំងមូល។ ការអភិវឌ្ឍសង្គម បរិយាប័ន្នភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ សុទ្ធតែជាផ្នែកសំខាន់ៗនៃភាពធន់។ ដូចដែលលោក ហាសាន ហាចាម បានពន្យល់យ៉ាងក្បោះក្បាយហើយថា ចំណុចសំខាន់ៗទាំងនេះ អាចនាំទៅរកការវិវឌ្ឍសំខាន់មិនអាចខ្វះបាននៃគំរូសេដ្ឋកិច្ចបច្ចុប្បន្ន។

ក្រោយពីការដាក់បញ្ចូលគ្នារួចមក សក្ខីកម្មជាច្រើនទាំងនេះដែលយើងបានស្តាប់នៅក្នុងសន្និសីទ ហើយចម្លងចេញនៅក្នុងស្នាដៃដែលលោកអ្នកអានកំពុងកាន់នៅក្នុងដៃនេះ ពិតជាបង្កើតបាននូវប្រវត្តិរឿងរ៉ាវរៀបរាប់ដោយផ្ទាល់មាត់មួយពិតប្រាកដ អំពីការកសាងទីក្រុងឡើងវិញ ដែលលោក លីយ៉ូណែល ព្រីហ្សង់ លើកសំណើជាសេចក្តីសង្ខេបមួយ ជូនយើងទាំងអស់គ្នានៅផ្នែកខាងចុងនៃស្នាដៃនេះ។ ប្រវត្តិរឿងរ៉ាវទាំងនេះ កាន់តែសំខាន់ថែមទៀតដោយសារថា វាបំពេញបន្ថែមឲ្យកង្វះខាតនៃចំណេះដឹងអំពីសម័យកាលទាំងនោះ ដែលជារបត់មួយដ៏លឿន និងប្រកបដោយភាពក្តុកក្តួលនៃប្រវត្តិសាស្រ្តទីក្រុង និងប្រវត្តិសាស្រ្តប្រជាពលរដ្ឋជាលក្ខណៈបុគ្គល។ ក្រោយពីសរសេរចេញហើយ ប្រវត្តិរឿងរ៉ាវទាំងនេះ ដែលរៀបរាប់ដោយផ្ទាល់មាត់ អាចក្លាយទៅជាស្មារតីចងចាំមួយ និងបម្រើជាប្រយោជន៍នៃការកំណត់ទិសដៅគោលនយោបាយបច្ចុប្បន្ន ក្នុងការគ្រប់គ្រងហានិភ័យក្រុង និងកាត់បន្ថយភេទនីយភាព។

1. សូមអានជាអាទិ៍ ស្នាដៃរបស់អ្នកនិពន្ធ Carrier A. ឆ្នាំ២០០៧ មានចំណងជើងថា"ច្បាប់នៃការកាន់កាប់អចលនទ្រព្យ" នៅទីក្រុងភ្នំពេញ៖ ការប្រែក្លាយសិទ្ធិនៃការប្រើប្រាស់លំនៅដ្ឋាន បន្ទាប់ពីបរិបទសង្គមនិយមនៃការចូលមករស់នៅក្នុងទីក្រុងវិញ (ឆ្នាំ១៩៧៩-១៩៨៩) ឱ្យទៅជាកម្មសិទ្ធិឯកជន និក្ខេបបទថ្នាក់បណ្ឌិតផ្នែកស្ថាបត្យកម្ម សាកលវិទ្យាល័យប៉ារីស៨ កម្រាស់៥៩៩ទំព័រ ស្នាដៃលោក Pierdet C. ឆ្នាំ២០០៨ មានចំណងជើងថា "កាលវេលានៃទំនាក់ទំនងរវាងទីក្រុងនិងទន្លេនៅភ្នំពេញ"៖ ការតាំងទីនៃទីក្រុងជាប់មាត់ទន្លេ ដោយការកសាងប្រព័ន្ធធារាសាស្រ្តមួយ (ឆ្នាំ១៨៦៥-២០០៥) និក្ខេបបទថ្នាក់បណ្ឌិតផ្នែកភូមិវិទ្យា សាកលវិទ្យាល័យប៉ារីស១ Panthéon-Sorbonne កម្រាស់៥៨៩ទំព័រ ស្នាដៃរបស់លោក Fauveaud G. ឆ្នាំ២០១៥ ដែលមានចំណងជើងថា "ការបង្កើតលំហក្រុងនៅទីក្រុងភ្នំពេញ សម្រាប់ភូមិសាស្រ្តសង្គមនៃអចលនទ្រព្យ" ទីក្រុងប៉ារីស បោះពុម្ព ផ្សាយដោយសាកលវិទ្យាល័យ Sorbonne កម្រាស់៣៦៨ទំព័រ។

Retour sur les enjeux de la reconstruction à Phnom Penh

១. ត្រឡប់ទៅពិនិត្យមើលបញ្ហានៃការកសាងទីក្រុងភ្នំពេញឡើងវិញ

A look back at the challenges of the reconstruction of Phnom Penh

Après une brève chronologie des grandes étapes qui ont jalonné la reconstruction de Phnom Penh par S.E. Pa Socheat Vong, Christiane Blancot revient sur les actions clés de cette reconstruction et Fabienne Luco sur la résilience de la population et son rôle dans le renouveau de la ville.

After a short chronology of the main steps that punctuated the reconstruction of Phnom Penh by H.E. Pa Socheat Vong, Christiane Blancot describes the key measures in that reconstruction process and Fabienne Luco the resilience of the population and its role in the revival of the city.

បន្ទាប់ពីបានស្តាប់អំពីជំហានធំៗជាបន្តបន្ទាប់នៃការកសាងទីក្រុងភ្នំពេញឡើងវិញ រៀបរាប់ត្រួសៗដោយឯកឧត្តម ប៉ា សុជាតិវង្ស លោកស្រី Christiane Blancot បានត្រឡប់មកនិយាយអំពីសកម្មភាពគន្លឹះៗនៃការកសាងឡើងវិញនេះ ហើយលោកស្រី Fabienne Luco បានពន្យល់អំពីភាពធន់របស់ប្រជាពលរដ្ឋ និងតួនាទីរបស់ប្រជាពលរដ្ឋនៅក្នុងជីវិតរស់នៅថ្មីក្នុងទីក្រុង។

Gare de Phnom Penh, 9 février 1980 : réouverture du chemin de fer. Le transport ferroviaire est important et les Cambodgiens doivent le réhabiliter.

Phnom Penh railway station, 9 February 1980: reopening of the railway. Rail transport is important and Cambodia needs to revive it.

ស្ថានីយរថភ្លើងក្នុងទីក្រុងភ្នំពេញ ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៨០៖ ការបើកឲ្យផ្លូវដែកដំណើរការឡើងវិញ។ ការដឹកជញ្ជូនតាមផ្លូវដែកគឺជាបណ្ដាញគមនាគមន៍ដ៏សំខាន់ ដែលប្រជាជនកម្ពុជាចាំបាច់ត្រូវស្តារឡើងវិញ។

“Leadership, processus de reconstruction et de développement de la Ville de Phnom Penh”

Ancien Gouverneur de Phnom Penh de 2013 à 2017, Pa Socheat Vong partage son expérience et les défis que la municipalité de Phnom Penh a rencontrés pendant son mandat. **PAR S. E. PA SOCHEAT VONG**

SE RECONSTRUIRE

Phnom Penh, qui a traversé les tragédies et les épreuves les plus amères et les plus indescriptibles lorsqu'elle a été transformée en ville fantôme entre 1975 et 1979, est aujourd'hui une ville prospère et peuplée de près de 3 millions d'habitants bénéficiant désormais d'un mode de vie décent.

Phnom Penh est l'une des vieilles villes de la Francophonie. Après la libération du 7 janvier 1979 du régime génocidaire des Khmers rouges, la ville commence sa renaissance et sa reconstruction. Depuis la signature de l'Accord de paix de Paris en 1991, une plus grande attention a été accordée à la restauration de la ville. La propriété foncière privée est rétablie en 1989, entraînant une forte croissance dans les secteurs de la construction et de l'immobilier au cours de la décennie suivante. À partir des années 2000, les *borey*, ou communautés fermées, parsèment peu à peu le paysage et les immeubles de grande hauteur commencent à germer. La transformation de la ville entraine également de multiples défis concernant l'environnement. Les déchets solides et liquides augmentent en volume, mais les infrastructures de traitement restent très médiocres. Par ailleurs, du début des années 1980 à l'an 2000, la ville compte environ 2 000 établissements communautaires pauvres s'étendant au bord des lacs, des canaux, de la voie ferrée, sur les toits des bâtiments existants et dans certains espaces publics.

> Pour faire face à ces défis, des mesures ont été prises pour définir une vision à long terme de la ville.

Pour faire face à ces défis, des mesures ont été prises pour définir une vision à long terme de la ville. Entre 2003 et 2015, dans le cadre d'un projet financé par le FSP (Fonds de Solidarité Prioritaire français), la Ville de Phnom Penh et des experts cambodgiens, en étroite collaboration avec des experts français, entreprennent une étude pour concevoir et développer le Plan directeur stratégique de Phnom Penh à l'horizon 2035. Approuvé par le Conseil des ministres le 15 décembre 2015, le schéma directeur à l'horizon 2035 définit de grandes orientations du développement urbain de la capitale cambodgienne, comme la durabilité, son caractère multifonctionnel, la réalisation d'infrastructures et de nouvelles zones d'urbanisation, ainsi que le développement d'une ville inclusive pour tous, riches et pauvres.

De plus, grâce à une coopération avec l'Agence japonaise de coopération internationale (JICA), la ville développe un plan directeur des transports ainsi qu'un plan directeur pour gérer les inondations. Un plan stratégique de gestion environnementale de la ville est également conclu grâce à une coopération avec l'organisation Green International Science.

Avec le plan directeur 2015-2035 à notre disposition, l'administration municipale de Phnom Penh a lancé, pendant mon mandat, un certain nombre de plans d'actions prioritaires pour relever plusieurs défis clés au cours de la période 2013-2017 en utilisant la combinaison de 3 priorités clés nommées « 3.2.1 » 3 pour 3 défis, 2 pour 2 services et 1 pour une politique de décentralisation/déconcentration.

RELEVER TROIS DÉFIS PRIORITAIRES :

1. L'ordre public relatif à la circulation, aux parkings, aux transports, aux marchands ambulants, à la construction et à la gestion de l'aménagement du territoire ;
2. Les problèmes environnementaux liés à la gestion des déchets liquides et solides ;
3. Les problèmes d'infrastructure, y compris les routes, le système de drainage et les réseaux de distribution d'eau potable et d'électricité, qui doivent être améliorés dans le cadre du plan de relocalisation des usines et autres établissements d'entreprise sur des sites le long des routes de la ceinture de la ville.

FOURNIR DEUX SERVICES PRINCIPAUX AUX HABITANTS DE LA VILLE :

1. Un service de sécurité : la sécurité et la stabilité politique doivent être assurées à tout moment. Cela a été mis en œuvre à diverses reprises lors de manifestations, parfois violentes, de la population.

© Cambodge Nouveau

Chantier de construction du réseau de drainage, Phnom Penh, 2007.

Phnom Penh, drainage system construction site, 2007.

ការដ្ឋានសាងសង់លូ នៅទីក្រុងភ្នំពេញ ឆ្នាំ២០០៧

2. Fournir des services publics, y compris les services de santé et d'éducation, aux citoyens avec transparence, responsabilité et efficacité.

POLITIQUE DE DÉCENTRALISATION ET DE DÉCONCENTRATION :

1. Poursuite de la mise en œuvre de la politique de décentralisation et de déconcentration, de manière plus large et approfondie, dans le cadre du développement démocratique infranational afin de rapprocher les services publics de la population. Cela se fait grâce à une coopération renforcée entre la ville et les organisations de la société civile, les partenaires du développement et par la consultation publique, ainsi que par le renforcement du mécanisme du service à guichet unique à tous les niveaux administratifs et avec un degré élevé de confiance.

Avec les plans directeurs et des stratégies ciblées comme principaux outils à notre disposition, appuyés par la sagesse de la « ville nourricière de la ville » mise en place par Samdech Techo Hun Sen, Premier ministre du Royaume du Cambodge, Phnom Penh a réussi certaines réalisations majeures. Pour n'en nommer que quelques-unes : la construction des routes de ceinture de la ville, des autoponts et des routes du centre-ville pour éviter la congestion du trafic, un autopont piétonnier érigé pour minimiser les accidents de la route, des châteaux d'eau publics construits dans des zones excentrées pour répondre aux besoins du public, un système de transport public par bus, la rénovation des parcs publics, l'amélioration de l'éclairage public et l'installation de caméras de sécurité, la pavement d'une voie piétonne le long de la rivière Tonlé Bassac, ainsi que l'amélioration du système de drainage (la capacité des 12 stations de pompage a été multipliée par trois).

Ces réalisations ont également été accompagnées par la forte croissance du nombre d'immeubles de grande hauteur, des *borey* et des villes satellites. Des conflits fonciers chroniques dans des communautés non organisées ont également été résolus. Sur ce front, la politique visant à relever le niveau de vie des communautés défavorisées a été appliquée avec vigueur. Un comité interministériel a été formé pour mener une étude et une évaluation afin de déterminer la compensation et les droits de propriété pour les résidents ou les communautés qui sont affectés par l'objectif du plan directeur. Entre 2001 et 2014, le nombre de communautés pauvres est passé de 1 369 à 252 grâce à une campagne de concession de terres octroyées à ceux qui résident dans les zones touchées et grâce à leur intégration dans les structures formelles de village et de sangkat.

Malgré ces progrès, la ville de Phnom Penh fait toujours face à de nombreux défis et face à une importante concurrence économique, qui dépasse ce que le plan directeur de la ville prévoyait. Le développement inégal entre les différentes zones de la ville et les modes d'utilisation du sol et de la géographie de la ville se traduisent par

des pertes économiques. Celles-ci s'accompagnent d'un déséquilibre entre les besoins d'ouvrir plus d'espace foncier pour les activités de construction axées sur les services, et les infrastructures publiques. Ces dernières restent insuffisantes face à la croissance démographique et au boom de la construction, comme en témoigne l'aggravation des embouteillages année après année dans le centre-ville. Pendant ce temps, alors que la ville se transforme de plus en plus en une métropole pouvant accueillir jusqu'à 6 millions d'habitants, alors qu'elle ne compte maintenant que 2 millions d'habitants, elle créera alors également un précédent pour d'autres grandes provinces, qui doivent être régies par la même loi.

Au cours des décennies suivantes, les villes et les municipalités de l'ANASE sont impatientes d'adopter le concept de réseau de villes intelligentes défendu par les dirigeants de l'organisation. À la lumière des défis que je viens de mentionner, je souhaiterais insister sur deux enjeux importants auxquels la ville devra faire face dans un futur proche.

Tout d'abord, avec son évolution et son développement, Phnom Penh a maintenant dépassé son statut de capitale et est en passe de devenir une métropole qui aura des fonctions plus spécifiques et nécessitera plus de ressources, de capacités et de responsabilités en matière juridique, technique, financière et de gestion.

Ensuite, avec la forte augmentation de la population, des moyens de transport et de la construction, le moment est venu pour les dirigeants de la ville de reconsidérer la révision du plan directeur de la ville de manière à répondre à la concurrence économique et afin d'assurer un développement plus durable. En tant que membre du réseau Smart City, la ville de Phnom Penh doit se préparer à pouvoir rattraper la tendance régionale.

Pour conclure, je souhaiterais dire que si les défis rencontrés par toutes nos villes respectives peuvent être similaires ou différents, j'espère que nous, en tant que partenaires de la Francophonie, continuerons de partager les bonnes leçons apprises avec la ville de Phnom Penh. J'espère aussi que nous travaillerons ensemble pour relever ces défis, pour garantir un développement urbain plus durable et une croissance économique dans un environnement sain, exempt de congestion routière, de détritus et d'inondations, afin de prendre soin du bien-être des résidents pour continuer à garantir l'équilibre de leur niveau de vie.

Figure 1.14: Increase in Vehicles in Phnom Penh Between 1990 and 2012



Figure 1.15: Change in Travel Speed Between 2001 and 2012



Source: JICA, 2014. The Project for Comprehensive Urban Transport Plan in Phnom Penh Capital City

Graphique 1.14 : Augmentation du nombre de véhicules à Phnom Penh de 1990 à 2012.

Graph 1.14: Increase in the number of vehicles in Phnom Penh from 1990 to 2012.

ក្រាហ្វិក១.១៤៖ ការកើនឡើងនៃចំនួនយានយន្តនៅទីក្រុងភ្នំពេញ ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១២

Graphique 1.15 : Evolution du trafic de 2001 à 2012.

Graph 1.15: Traffic growth from 2001 to 2012.

ក្រាហ្វិក១.១៥៖ កំណើនចរាចរណ៍ ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១២

"Leadership, Reconstruction Process and Development in the City of Phnom Penh"

Former Governor of Phnom Penh from 2013 to 2017, Pa Socheat Vong looks back on his experience and on the challenges that Phnom Penh municipality faced during his mandate.

BY H. E. PA SOCHEAT VONG

REBUILDING

Phnom Penh, which suffered the most bitter and indescribable trials and tragedies when it was turned into a ghost city between 1975 and 1979, is today a prosperous and populous city of almost 3 million people who now enjoy a decent way of life.

Phnom Penh is one of the world's old Francophone cities. After it was liberated on January 7, 1979 from the genocidal Khmer Rouge regime, the city embarked upon its renaissance and reconstruction. Since the signature of the Paris Peace Agreement in 1991, greater attention has been paid to the restoration of the city.

Private land ownership was re-established in 1989, leading to strong growth in the construction and real estate sectors over the decade that followed. From the 2000s onwards, the landscape gradually became peppered with borey, or gated communities, and high-rise buildings began to spring up. The transformation of the city also generated many environmental challenges. Volumes of solid and liquid waste increased, but the infrastructures for treating them remained very modest. Moreover, from the early 1980s to the year 2000, the city was home to some 2000 poor community settlements, located along lakes, canals, the railway, on the roofs of existing buildings and in certain public spaces.

To tackle these challenges, measures were taken to establish a long-term vision for the city. Between 2003 and 2015, as part of a project funded by the FSP (France's Priority Solidarity Fund), Phnom Penh Municipality and Cambodian experts, in close collaboration with French experts, undertook a study to design and develop the strategic masterplan for Phnom Penh up to the time horizon of 2035. Approved by the Council of Ministers on December 15, 2015, the 2035 Masterplan sets out the main orientations for the urban development of the Cambodian capital, such as sustainability, multi-functionality, the construction of infrastructures and new urban areas, as well as the development of a city that is inclusive for everyone, rich and poor alike.

Moreover, thanks to a cooperation with JICA (Japanese International Cooperation Agency), the city developed a transport masterplan as well as a flood control plan. A strategic plan for the environmental management of the city was also completed, in cooperation with the Green International Science organisation.

Once we had the 2015-2035 masterplan available, Phnom Penh's municipal administration – during my mandate – launched a number of priority action plans to tackle several key challenges over the period 2013-2017, using the combination of 3 key priorities named "3.2.1": 3 for three challenges, 2 for two services and 1 for a policy of decentralisation/devolution.

THREE PRIORITY CHALLENGES

1. Public order problems relating to traffic, parking, transport, street vendors, construction and spatial planning;
2. Environmental problems linked with the management of liquid and solid waste;
3. Infrastructure problems, including roads, the drainage system and the drinking water and power networks, which have to be improved under the plan to relocate factories and other enterprises to sites along the orbital roads around the city.

PROVIDING THE CITY'S INHABITANTS WITH TWO MAIN SERVICES

1. A security service: safety and political stability must be maintained at all times. This was implemented on several occasions in the context of sometimes violent demonstrations by the population.
2. Providing citizens with public services, including health and education services, with transparency, with accountability and with efficiency.

DECENTRALISATION AND DEVOLUTION POLICY

1. Broadening and intensification of the decentralisation and devolution policy, within the framework of infranational democratic development, in order to bring public services closer to the population. This is achieved through greater cooperation between the city and civil society organisations and development partners, and by public consultation, as well as by a reinforced and highly trusted one-stop shop mechanism for services at all administrative levels.

With the master plans and targeted strategies as the main tools available to us, underpinned by the wisdom of the "city nurturing the city" principle established by Samdech Techo Hun Sen, Prime Minister of the Kingdom of Cambodia, Phnom Penh has achieved some major accomplishments. To name but a few: the building of orbital roads around the city, elevated roads in the city centre to avoid traffic congestion, a pedestrian overpass to minimise road accidents, public water towers in peripheral areas to meet public needs, a public bus transport service, the renovation of public parks, improvements to public lighting and the installation of CCTV cameras, the creation of a pedestrian walkway along the Tonlé Bassac River, and improvements to the drainage system (with a tripling of the capacity of the 12 pumping stations).

These accomplishments were paralleled by significant growth in the numbers of high-rise buildings, boreys and satellite towns. Chronic land conflicts in the non-organised communities were also resolved. On this front, the policy to improve the living standards of disadvantaged communities was vigorously applied. An interministerial committee was set up to conduct a study and assessment to determine the compensation and property rights to be awarded to the residents or communities affected by the goals of the masterplan. Between 2001 and 2014, the number of poor communities fell from 1369 to 252 thanks to a land grant concession programme for people living in the affected areas and their integration into the formal village and sangkat structures.

Despite these advances, the city of Phnom Penh still faces many challenges, in particular significant economic competition, which exceeds the levels anticipated in the city's masterplan. Unequal development between the city's different zones and changes in the land use and geography of the city have led to economic losses. Alongside these, there is an imbalance between the quantities of land provided for service-oriented construction activities, and the need to build public infrastructures. The latter are inadequate to handle the level of demographic growth and the construction boom, as evidenced by the year-on-year increase in city centre congestion. During this time, as the city increasingly develops into a metropolis with the capacity to accommodate up to 6 million inhabitants, as compared with the current 2 million, it will also create a precedent for other big provinces, which must be governed by the same principles.

Over the coming decades, cities and municipalities in ASEAN are impatient to adopt the concept of the smart cities network advocated by the organisation's leaders. In the light of the challenges I have just mentioned, I would like to emphasise two important issues that the city will need to deal with in the near future.

First, as it has changed and developed, Phnom Penh has now become more than a capital and is in the process of becoming a metropolis, which will have more specific functions and require more resources, capacities and responsibilities in the legal, technical, financial and management domains.

Then, with the rapid increase in population, transport systems and construction, the time has come for the municipal leaders to consider revising the city masterplan in response to economic competition and to ensure more sustainable development. As a member of the Smart City network, the city of Phnom Penh needs to prepare in order to keep pace with regional trends.

To conclude, I would like to say that while the challenges our respective cities face may be similar or different, I hope that we – as partners in Francophonie – will continue to share the important lessons learned with the city of Phnom Penh. I also hope that we will work together to tackle these challenges, to guarantee more sustainable urban development and economic growth in a healthy environment, free of road congestion, detritus and flooding, where we can continue to advance the well-being of citizens and to guarantee them stable living standards.

“ការដឹកនាំ ដំណើរកសាង និងអភិវឌ្ឍន៍រាជធានីភ្នំពេញ”

ក្នុងនាមអតីតអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្នុងចន្លោះឆ្នាំ ២០១៣-២០១៧ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយចែករំលែកនូវប្រវត្តិ បទពិសោធន៍ បញ្ហាប្រឈម ក៏ដូចជាទស្សនវិស័យមួយចំនួនសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍរាជធានីភ្នំពេញក្នុងអាណត្តិរបស់ខ្ញុំ។

ដោយ ឯកឧត្តម ប៉ា សុជាតិវង្ស

រាជធានីភ្នំពេញ ដែលជាទីក្រុងមួយធ្លាប់ឆ្លងកាត់នូវសោកនាដកម្មយ៉ាងជូរចត់ ការលំបាករាប់មិនអស់ក្នុងអតីតកាល និងក្លាយជាទីក្រុងខ្មោចក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ បានក្លាយមកជាទីក្រុងមួយដែលមានមនុស្សរស់នៅជិត៣លាននាក់ ប្រកបដោយការអភិវឌ្ឍ សម្បូរសប្បាយ និងប្រជាជនមានជីវភាពសមរម្យនាពេលបច្ចុប្បន្ន។

រាជធានីភ្នំពេញជាក្រុងដែលមានវ័យចំណាស់មួយ ក្នុងចំណោមទីក្រុងនិយាយភាសាបាំរាំងនានា។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ទីក្រុងនេះបានចាប់ទទួលមនុស្សឲ្យចូលមករស់នៅឡើងវិញ និងត្រូវបានស្តារឡើងវិញជាបណ្តើរៗ។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ រាជធានីភ្នំពេញបានទទួលការយកចិត្តទុកដាក់ជាពិសេស ក្នុងការស្តារឡើងវិញជាបន្តបន្ទាប់ ជាមួយកំសួលនៃការអនុវត្តទីផ្សារសេរី និងការកំណត់ឲ្យមានសិទ្ធិលើកម្មសិទ្ធិឯកជនលើវិស័យដីធ្លី និងអចលនទ្រព្យ ដែលបានបើកតាំងពីឆ្នាំ១៩៨៩ បានធ្វើឲ្យភ្នំពេញ ក្នុងរង្វង់១០ឆ្នាំក្រោយ ចាប់ផ្តើមស្គាល់នូវការរីកដុះដាលយ៉ាងខ្លាំងក្លាលើវិស័យសំណង់និងអចលនទ្រព្យ។ ការលេចឡើងជាបន្តបន្ទាប់នូវសំណង់ខ្ពស់ៗ សំណង់បូរីជាច្រើនកន្លែង បណ្តាលឱ្យយើងជួបប្រទះបញ្ហាប្រឈមផ្សេងទៀត គឺបញ្ហាបរិស្ថាន បញ្ហាសំណល់រឹង រាវ ភាពទន់ខ្សោយហេដ្ឋារចនាសម្ព័ន្ធទាំងទន់និងរឹង និងភាពក្រីក្រ ដែលគេអាចសង្កេតឃើញមានសហគមន៍ក្រីក្រជិត២០០០ នៅចន្លោះពីដើមទសវត្សរ៍ទី៨០ ដល់ពាក់កណ្តាលឆ្នាំ២០០០ ដែលបានតាំងទីនៅរាយប៉ាយ តាមមាត់បឹង មាត់ប្រឡាយ តាមផ្លូវរថភ្លើង តាមដំបូលអគារ និងតាមទីសាធារណៈ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ វិធានការត្រូវបានចាត់ឡើងសំដៅទៅកំណត់ចក្ខុវិស័យរយៈពេលវែងសម្រាប់រាជធានី។ កិច្ចសហប្រតិបត្តិការក្រោមគម្រោងជំនួយមូលនិធិសាមគ្គីភាពអាទិភាព (FSP) របស់បារាំង សាលារាជធានីភ្នំពេញ អ្នកបច្ចេកទេសកម្ពុជា បានសហការយ៉ាងជិតស្និទ្ធជាមួយជំនាញការបារាំង បានចាប់ផ្តើមសិក្សានូវប្លង់មេយុទ្ធសាស្ត្រអភិវឌ្ឍន៍រាជធានីភ្នំពេញ ឆ្នាំ២០៣៥ ដោយបានផ្តើមចេញដំណើរពីឆ្នាំ២០០៣ និងបានបញ្ចប់ជាស្ថាពរ ដោយបានទទួលការអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥។ ប្លង់មេនេះបានដាក់ចេញនូវទស្សនវិស័យអភិវឌ្ឍន៍ដល់ឆ្នាំ២០៣៥ និងបានតម្រង់ទិសការអភិវឌ្ឍ លើចំណុចសំខាន់ៗមួយចំនួនដូចជា ភ្នំពេញជារាជធានីដែលទទួលយកការអភិវឌ្ឍប្រកបដោយចីរភាព និងមានមុខងារចម្រុះ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងតំបន់ក្រុងរណបថ្មីៗ ជាក្រុងសម្រាប់ទាំងអស់គ្នា ទាំងសម្រាប់អ្នកមាន ទាំងសម្រាប់អ្នកក្រ។

On the other hand, the housing shortage, urban poverty, and the commitment to do away with inadequate housing have generated programs to relocate people living in straw huts on subprime land. The people, with assistance from international NGOs, are organized into community associations on a site-by-site basis to contribute to the relocation policies and to be heard. Local authorities, with assistance from the UNPD (UN-Habitat) and ADB, have worked in close partnership with the NGOs and relevant communities to set up permanent coordinating bodies to organize rehousing with the financial support of international agencies (ADB, UN, EU). The new sites located in outlying districts will also foster urban extension.
One of the tentative conclusions of these first interventions suggests that the brisk pace of reconstruction is very much due to the conjunction of several factors: the energy of the people and their desire to rebuild their lives, action on the part of the governing authorities who, at all levels, were up to the task of finding innovative solutions, action on the part of donors who for over 20 years, despite the political ups and downs, have consistently supported the initiatives of private investors who, although they arrived late because they were waiting for evidence of stability, are now very active.

NEW CHALLENGES

Between 1973 and 2015, the area covered by Phnom Penh went from 3,100 ha to 25,400 ha. Some 21,000 ha of agricultural land and lakes were lost to gain land for city planning or land with development potential. We have gone from a city with a modest footprint surrounded by rice paddies and whose survival was in part ensured by its agricultural belt, to an expansive metropolis dependent on distant places for its supplies. Meanwhile, this sprawling metropolis is producing much of the national wealth through its economic activities. This spectacular, fast-track transformation generates new challenges, including increased pollution, traffic congestion, and greater exposure to risks such as flooding due to the loss of the great lakes. Faced with these many challenges, Phnom Penh may find itself weakened again. Assessing these risks is an ongoing necessity.

កំណត់សំគាល់មួយចំនួនស្តីអំពីសម័យកាលកសាងរាជធានីភ្នំពេញឡើងវិញ

គឺមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ ទើបការកសាងរាជធានីភ្នំពេញឡើងវិញត្រូវបានចាប់ផ្តើមពន្លឿនទៅមុខយ៉ាងលឿនដោយសារតែវិស័យឧស្សាហកម្មបានចាប់ផ្តើមឡើងវិញ និងដោយសារមានគម្រោងសហប្រតិបត្តិការជាច្រើនត្រូវបានអនុវត្ត។ គឺនៅក្នុងរយៈពេលនេះហើយ ដែលចាប់ផ្តើមមានមូលដ្ឋានគ្រឹះនៃកំណើនថ្មីក្នុងទីក្រុង។

ដោយលោកស្រី **CHRISTIANE BLANCOT**

កសាងឡើងវិញក្រោមទណ្ឌកម្មអន្តរជាតិ

ប្រវត្តិកាលថ្មីៗនៃរាជធានីភ្នំពេញបានជិតដាមដោយអន្តរកម្មមួយយ៉ាងខ្លាំង រវាងនយោបាយធំៗ ព្រឹត្តការណ៍ធំៗ នៃដំណើរទៅមុខរបស់ពិភពលោក និងប្រវត្តិសាស្ត្រក្នុងស្រុកមួយសុទ្ធសាធ ដែលកើតចេញពីទំនាក់ទំនងពិសេសមួយ រវាងប្រជាជននិងដែនដីរបស់ខ្លួន។

បន្ទាប់ពីការដួលរលំទៅនៃរបបខ្មែរក្រហម ខណៈដែលប្រជាជនចាប់ផ្តើមត្រឡប់ចូលមករស់នៅ និងកសាងជីវិតសារជាថ្មីក្នុងទីក្រុងវិញ ដំណើរការកសាងប្រទេសឡើងវិញក៏ចាប់ផ្តើមឡើងដែរ ក្នុងនោះរាជធានីភ្នំពេញ ក្នុងនាមជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងនយោបាយរបស់កម្ពុជា គឺជាកញ្ចក់ឆ្លុះបញ្ចាំងនៃដំណើរការកសាងនេះ។

ការត្រលប់ចូលមករស់នៅក្នុងទីក្រុងភ្នំពេញវិញរបស់ប្រជាជននៅឆ្នាំ១៩៧៩ ជាបឋម គឺការសម្របខ្លួនទៅនឹងជីវិតរស់នៅតាមធម្មតាឡើងវិញនៅក្នុងទីក្រុងមួយដែលពុំមានការរស់នៅធម្មតាទៀតឡើយនាពេលនោះ។ នៅក្នុងទីក្រុងភ្នំពេញ គ្មានទាំងទឹកស្អាតសំរាប់បរិភោគ គ្មានទាំងភ្លើងអគ្គិសនី។

ដើមដូង និងដើមចេក ត្រូវបានគេដាំនៅលើដីដែលមានក្រាលថ្ម អគារទាំងឡាយត្រូវបានគេបោះបង់ចោលអស់រយៈពេលជិតបួនឆ្នាំ ផ្ទះមួយចំនួនត្រូវបានគេរុះរើ ដើម្បីយកសម្ភារទៅប្រើប្រាស់ផ្សេង ហើយប្រព័ន្ធលូទាំងមូលបានបាក់បែក ឬក៏កកស្ទះទាំងអស់។ នៅពេលនោះហើយដែលការងារកសាងអ្វីៗឡើងវិញទាំងអស់ បានចាប់ផ្តើមឡើងក្នុងរយៈពេលមួយដ៏វែង។

នៅក្នុងបរិបទមួយជិតដាមទៅដោយទណ្ឌកម្មអន្តរជាតិ ដែលត្រូវបានគេដាក់មកលើកម្ពុជា ហើយទណ្ឌកម្មនោះនឹងបន្តរហូតដល់មានកិច្ចព្រមព្រៀងសន្តិភាព នៅឆ្នាំ១៩៩១ ជំនួយដែលមកពីសហភាពសូវៀត និងបណ្តាប្រទេសខាងកើត មកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងមកពីភ្នាក់ងារអង្គការសហប្រជាជាតិ ដូចជា អង្គការយូនីសេហ្វ បានធានាឱ្យមានការផ្គត់ផ្គង់ជាម្ហូបអាហារ និងផ្តល់អ្នកបច្ចេកទេស វិស្វករ រដ្ឋាបាលករគ្រប់ប្រភេទ ឱ្យមកជួយកសាងឡើងវិញនូវបណ្តាស្ថាប័នរដ្ឋ និងហេដ្ឋារចនាសម្ព័នជាមូលដ្ឋាននានា។ បែបនោះហើយទើបមានការប្រចាប់បញ្ចូលគ្នារវាងសកម្មភាពការងាររបស់អ្នកដែលនៅរស់ និងអ្នកជំនាញ ដើម្បីបំពេញបន្ថែមលើកង្វះចន្លោះខាងផ្នែកបុគ្គលិកដែលមានចំណេះជំនាញ បុគ្គលិកបច្ចេកទេស និងបុគ្គលិករដ្ឋាបាល ដែលមានសម្ថភាពគ្រប់គ្រងទីក្រុង។

នៅឆ្នាំ១៩៧៩ គេត្រូវធ្វើឱ្យដំណើរការឡើងវិញនូវរោងចក្រផលិតអគ្គិសនី ទឹកស្អាត ធ្វើស្ថិតិប្រជាជន បែងចែកប្រជាជនទៅតាមទីកន្លែងធ្វើការផ្សេងៗ បើកមណ្ឌលកុមារកំព្រា សាលារៀន និងមន្ទីរពេទ្យ បន្ទាប់ពីបានជួសជុលតិចតួច និងមានសម្ភារតិចតួចបំផុត។ រហូតដល់ឆ្នាំ១៩៩១ កង្វះខាតមធ្យោបាយហិរញ្ញវត្ថុ បានរារាំងមិនឱ្យការដ្ឋានធំៗអាចធ្វើទៅបានឡើយ។ អនាម័យនៅក្នុងទីក្រុង និងសំណង់អគារផ្សេងៗកាន់តែមានសភាពធ្ងន់ធ្ងរទៅៗ និងបណ្តាលឱ្យមានការលួចតប្រព័ន្ធទឹកស្អាត និងខ្សែរភ្លើងតាមបែបរញ៉េរញ៉ៃ ការកាប់ឈើដើម្បីយកមកធ្វើជាអុសដុត ការយកផ្នែករួមនៅក្នុងអគារមកធ្វើជាកន្លែងដាំស្លជាដើម ទឹកលិចធ្វើឱ្យគ្រឿងបង្គុំផ្ទះ និងអគារកាន់តែខូចខាតខ្លាំងឡើង។ល។ ប្រជាពលរដ្ឋច្រើនគ្រួសាររស់នៅពពាក់ពពូនគ្នាក្នុងផ្ទះដែលមានការរៀបចំតិចតួច ដោយប្រើឥដ្ឋនិងឈើ នៅក្នុងអគារចាស់ៗ ដូចជាសាលារៀន វត្តអារាម និងអគាររដ្ឋបាលនានា បានធ្វើឱ្យសំណង់អគារទាំងនោះកាន់តែខូចខាតធ្ងន់ធ្ងរខ្លាំងឡើងៗ និងនាំឱ្យការជួសជុលជួបប្រទះការលំបាក ឬក៏មិនអាចធ្វើទៅរួចតែម្តង។ ទណ្ឌកម្មសេដ្ឋកិច្ចដែលឃារឃាំងអស់រយៈពេលជាង១៥ឆ្នាំ មិនឱ្យមានការអនុវត្តទៅរួចនូវគោលនយោបាយនៃការកសាងប្រកបដោយនិរន្តភាពពិតប្រាកដ ធ្វើឱ្យទីក្រុងខូចខាតកាន់តែធ្ងន់ធ្ងរទៅៗ ហើយប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងក៏ប្រឈមមុខនឹងហានិភ័យជាច្រើន ដូចជា ផ្លូវថ្នល់លិចទឹកជំនន់ជាញឹកញាប់ នៅរៀងរាល់រដូវវស្សា មានជំងឺឆ្លង និងជំងឺគ្រុនឈាម ឬក៏អគ្គីភ័យជាដើម។

ការកើនឡើងនូវចំនួនភូមិដែលមានសំណង់ជាផ្ទះស្លឹក និងផ្ទះធ្វើពីឈើនៅលើដំបូលអគារចាស់ៗ ព្រមទាំងនៅតាមទីធ្លាសាធារណៈ ក៏ដូចជានៅតាមសួនច្បារនានា ឬក៏ការតាំងទីលំនៅតាមមាត់ទន្លេដែលអាចមានទឹកលិចធ្វើឱ្យមានគ្រោះមហន្តរាយដល់ជីវិតមនុស្សនៅដំណាច់ទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារភ្លៀងខ្លាំងមិនធ្លាប់មានពីមុនមក នៅឆ្នាំ១៩៩៦ និង ឆ្នាំ២០០០ ធ្វើឱ្យសង្កាត់មួយចំនួន និងដីដែលនៅតាមមាត់ទន្លេមេគង្គជន់លិចអស់។ ម៉្យាងវិញទៀត អគ្គីភ័យធំៗបានឆាបឆេះបំផ្លិចបំផ្លាញសង្កាត់មួយចំនួន ធ្វើឱ្យប្រជាជនរាប់រយគ្រួសារគ្មានផ្ទះសម្បែងជ្រកកោន។

ការកសាងឡើងវិញយ៉ាងស្វិតស្វាញអស់រយៈពេល២០ឆ្នាំ

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ចុះហត្ថលេខានៅខែតុលា ឆ្នាំ១៩៩១ បានបើកសាករាជថ្មីមួយ។ រដ្ឋបាលបណ្តោះអាសន្នលើកម្ពុជាមួយដែលហៅកាត់ថា អ៊ុនតាក់ (UNTAC) ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិដើម្បីត្រៀមរៀបចំការបោះឆ្នោតនៅឆ្នាំ១៩៩៣។

រដ្ឋបាលករ និងទាហានមួកខៀវបីម៉ឺននាក់បានមកដល់ប្រទេសកម្ពុជានៅដើមឆ្នាំ១៩៩២ និងបានចំណាយថវិការយ៉ាងច្រើនសន្ធឹកសន្ធាប់។ គ្រាន់តែវត្តមានរបស់ទាហានមួកខៀវនេះ ក៏បណ្តាលឱ្យមានការជួសជុលផ្ទះវីឡា និងអគារជាច្រើនដែរ ដើម្បីទទួលពួកគេឱ្យស្នាក់នៅ ព្រមទាំងការបើកបារ និងភោជនីយដ្ឋាននានា បណ្តាលឱ្យមានការជួសជុលទីក្រុងជាលើកដំបូង។ ចាប់ពីឆ្នាំ១៩៩៣មក សន្និសីទអន្តរជាតិមួយស្តីពីការកសាងប្រទេសកម្ពុជាឡើងវិញ ដែលមានការកៀរគរបណ្តាប្រទេសផ្តល់ជំនួយអភិវឌ្ឍន៍សំខាន់ៗ នឹងអនុញ្ញាតឱ្យស្ថាប័នខ្មែរនានាទទួលបាននូវគម្រោងជំនួយអន្តរជាតិ ជាជំនួយទ្វេភាគី ឬពហុភាគី។ ចាប់ពីពេលនោះមក ទឹកប្រាក់ជំនួយជាងមួយពាន់លានដុល្លារត្រូវបានបញ្ជូនមកប្រទេសកម្ពុជារៀងរាល់ឆ្នាំ ក្នុងនោះប្រាំរយលានមកពីសហរដ្ឋអាមេរិក និងពាក់កណ្តាលទៀតមកពីបណ្តាប្រទេសផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ថវិកាជំនួយត្រូវបានបែងចែកទៅតាមក្រសួង មន្ទីរផ្សេងៗរបស់រដ្ឋ រួមមានខាងផ្នែកសុខាភិបាល អប់រំ សាធារណៈការ រដ្ឋាករទឹកនិងអគ្គិសនី ផ្លូវថ្នល់និងស្ពាន រដ្ឋបាល និង យុត្តិធម៌។ល។ ទៅតាមកម្មវិធីវិនិយោគប្រចាំឆ្នាំមួយ ដែលបង្ហាញជូនដោយរដ្ឋាភិបាលកម្ពុជា និងផ្តល់សុពលភាពដោយបណ្តាប្រទេស និងស្ថាប័នផ្តល់ជំនួយជាង៤០។ វិធីសាស្ត្របែបនេះមានប្រសិទ្ធភាពរយៈពេលជាង២០ឆ្នាំ។

តួនាទីដ៏សំខាន់នៃឧស្សាហកម្ម

ទន្ទឹមនឹងកម្មវិធីជំនួយនេះ វាជារឿងចាំបាច់ដែលត្រូវរៀបចំឱ្យមានវិនិយោគិនឯកជន អនុញ្ញាតឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យឧស្សាហកម្មចាប់ផ្តើមដំណើរការឡើងវិញ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល នឹងក្លាយជាច្រកចេញចូលតែមួយគត់នៅកម្ពុជាសម្រាប់វិនិយោគិនបរទេស។ តួនាទីរបស់ក្រុមប្រឹក្សានេះ គឺសម្របសម្រួលការវិនិយោគ ផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង និងស្ថាប័ននានារបស់រដ្ឋាភិបាលជួយក្រុមហ៊ុននៅក្នុងដំណើរការវិនិយោគនៅកម្ពុជា និងជួយបង្កឱ្យមានភាពងាយស្រួលនូវការបង្កើតភាពជាដៃគូជាមួយក្រុមហ៊ុនខ្មែរ ជាពិសេស ក្នុងទម្រង់ជាការវិនិយោគរួមគ្នា។

ការដាក់ចេញនូវកំណែទម្រង់សេរី និងការសម្រេចប្រកាន់យកសេដ្ឋកិច្ចទីផ្សារបានអនុញ្ញាតឱ្យកម្ពុជាទទួលបាននូវកិច្ចព្រមព្រៀងអនុគ្រោះមួយ ដើម្បីនាំចេញនូវផលិតកម្មវាយនភណ្ឌរបស់ខ្លួន ជាពិសេសគឺសម្លៀកបំពាក់នាំចេញទៅទីផ្សារអាមេរិក និងអឺរ៉ុប។ កិច្ចព្រមព្រៀងទាំងនេះបាននាំឱ្យមានការអភិវឌ្ឍវិស័យវាយនភណ្ឌ ជាពិសេស លើកទឹកចិត្តឱ្យវិនិយោគិនអាស៊ីមករកកំលាំងពលកម្មថោកនៅក្នុងទីផ្សារកម្ពុជា។ ក្នុងរយៈពេលដប់ឆ្នាំ ពោលគឺចាប់ពីឆ្នាំ១៩៩៦មក ភ្នំពេញបានក្លាយជាទីក្រុងឧស្សាហកម្មមួយ។ នៅឆ្នាំ២០០៤ គេរាប់ឃើញ នៅទីក្រុងភ្នំពេញ មានជាង២៨០រោងចក្រដែលត្រូវបានសាងសង់ឡើង ជាពិសេស នៅតាមជាយក្រុងភ្នំពេញ។ រោងចក្រទាំងនោះប្រើប្រាស់កម្មករ កម្មការនី នៅក្នុងវិស័យវាយណភណ្ឌ ប្រមាណជាម្ភៃម៉ឺននាក់ ជាពិសេសគឺកម្មករ កម្មការនីវ័យក្មេងដែលភាគច្រើនមកពីជនបទ។ ការគោរពដោយកម្ពុជាចំពោះបទដ្ឋានអន្តរជាតិការងារមួយចំនួន ដែលមានការត្រួតពិនិត្យដោយអង្គការពលកម្មពិភពលោក បានពង្រឹងការវិនិយោគនៅក្នុងឧស្សាហកម្មនេះ ដែលជួយមួយផ្នែកធំនៃប្រជាជនក្នុងទីក្រុង ឱ្យចាកផុតពីភាពក្រីក្រ។ ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងវិធានការចាត់ឡើងដើម្បីគោរពតាមបទដ្ឋានអង្គការពលកម្មអន្តរជាតិ ពិតជាសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ប៉ុន្តែផលវិបាកនៃឧស្សាហកម្មភាវូបនីយកម្មនេះគឺមានសភាពធំធេងខ្លាំង។ ផ្ទៃដីក្រុងកាន់តែរីកធំ ពីព្រោះរោងចក្រត្រូវបានសាងសង់នៅលើដីស្រែដែលគ្មានប្រព័ន្ធស្រោចស្រព ធ្វើឱ្យដីស្រែទាំងនោះក្លាយជាដីដែលគេអាចប្រែក្លាយឱ្យទៅជាផ្នែកមួយនៃទីក្រុង។

បញ្ហាដីធ្លី និងការកសាងលំនៅដ្ឋាន

បញ្ហាលំនៅដ្ឋានក៏ជាការឆ្លុះបញ្ចាំងមួយនៃដំណើរការចាកចេញផុតពីវិបត្តិ ដែលអាចទៅរួច ដោយសារតែសកម្មភាពរួមគ្នាមួយចំនួនរបស់ដៃគូសង្គម។ នៅដំណាច់ទសវត្សរ៍ឆ្នាំ១៩៩០ ស្ថានភាពលំនៅដ្ឋានមានសភាពធ្ងន់ធ្ងរខ្លាំងពោលគឺគេប៉ាន់ប្រមាណឃើញថា ត្រូវកសាងលំនៅដ្ឋានប្រមាណជាមួយម៉ឺនផ្ទះក្នុងមួយឆ្នាំ ដើម្បីអនុញ្ញាតឱ្យប្រជាជនដែលរស់នៅពពាក់ពពូនគ្នាក្នុងអគាររដ្ឋតាមសង្កាត់នានានៅកណ្តាលក្រុង អាចមានលទ្ធភាពទទួលបានផ្ទះថ្មីនៅ។ ម៉្យាង ច្បាប់សុរិយោដីឆ្នាំ២០០១ និងអនុក្រឹត្យនានាដែលពាក់ព័ន្ធនឹងច្បាប់នេះបានបង្កើតឡើងវិញនូវកម្មសិទ្ធិឯកជន ព្រមទាំងអនុញ្ញាតឱ្យគេទទួលបានសម្បទានដីរដ្ឋមកប្រើប្រាស់រយៈពេលរហូតដល់៩៩ឆ្នាំ។ ច្បាប់នេះនឹងអនុញ្ញាតឱ្យវិនិយោគិនចាប់ផ្តើមកសាងផ្ទះល្វែងនៅលើផ្ទៃដីធំៗ។ គំនិតផ្តួចផ្តើមទាំងនេះនាំឱ្យមានការពង្រីកទីក្រុង ជាអាទិ៍ ទៅដល់ដីបឹងដែលគេចាក់ដីលុប និងដីស្រែដែលគ្មានប្រព័ន្ធស្រោចស្រព។

ម៉្យាងវិញទៀត កង្វះខាតផ្ទះសម្បែង សភាពក្រីក្រក្នុងទីក្រុង និងចេតនាលុបបំបាត់លំនៅដ្ឋានអនាធិបតេយ្យ បាននាំដល់ការដាក់ចេញនូវកម្មវិធីរកទីតាំងថ្មីឱ្យប្រជាជនដែលរស់នៅតាមផ្ទះស្លឹក នៅក្នុងទីកន្លែងដែលប្រឈមនឹងហានិភ័យ។ ប្រជាពលរដ្ឋដែលទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ បានរៀបចំខ្លួនឯងជាសមាគម ឬសហគមទៅតាមទីតាំងរស់នៅរបស់ខ្លួន ដើម្បីធ្វើឱ្យសម្លេងរបស់ពួកគេមានទម្ងន់ទៅលើនយោបាយរបស់រដ្ឋាភិបាលក្នុងការរកទីតាំងថ្មីជូនពួកគេ និងឱ្យអជ្ញាធរគិតគូរដល់ពួកគេ។ អជ្ញាធរមូលដ្ឋានដែលទទួលបានជំនួយពីអង្គការ UNDP ឬអង្គការ UN Habitat និងធនាគារអភិវឌ្ឍន៍អាស៊ី រួមជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងសហគមប្រជាពលរដ្ឋទាំងនេះ បានបង្កើតអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៅតាមមូលដ្ឋាន ដើម្បីរៀបចំការរើទៅរស់នៅក្នុងទីតាំងថ្មី និងបង្កើតភាពជាដៃគូយ៉ាងជិតស្និទ្ធ ដោយមានជំនួយហិរញ្ញវត្ថុពីអង្គការអន្តរជាតិនានា ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី អង្គការសហប្រជាជាតិ ឬសហភាពអឺរ៉ុបជាដើម។ ទីតាំងថ្មីដែលស្ថិតនៅតាមជាយក្រុងក៏នឹងក្លាយទៅជាទីតាំងនៃការចាប់ផ្តើមពង្រីកទីក្រុងដែរ។

សេចក្តីសន្និដ្ឋានមួយក្នុងចំណោមសេចក្តីសន្និដ្ឋានបណ្តោះអាសន្ននៃអន្តរាគន៍មបឋមៗទាំងនេះអាចថា ថាមភាពនៃការកសាងឡើងវិញ អាចធ្វើទៅរួច គឺដោយសារមានកត្តាជាច្រើនរួមគ្នា នោះគឺកំលាំងរបស់ប្រជាជន និងចេតនារបស់ប្រជាពលរដ្ឋដែលចង់កសាងជីវិតរបស់ខ្លួនឡើងវិញ ចំណាត់ការរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាល ដែលនៅក្នុងគ្រប់កំរិតទាំងអស់ ចេះស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍ ព្រមទាំងដោយសារសកម្មភាពរបស់ប្រទេស និងស្ថាប័នផ្តល់ជំនួយនានា ដែលតែងតែផ្តល់ជំនួយអស់រយៈពេលជាង២០ឆ្នាំ ទោះជាពេលខ្លះ មានភាពមិនប្រាកដប្រជាផ្នែកនយោបាយយ៉ាងណាក្តី ហើយមួយផ្នែកទៀត គឺដោយសារគំនិតផ្តួចផ្តើមរបស់វិនិយោគិនឯកជន ទោះបីជាពួកគេចូលមកវិនិយោគយឺតបន្តិចយ៉ាងណាក្តី នោះគឺពីព្រោះតែពួកគេរង់ចាំមើលឱ្យឃើញថា កម្ពុជាមានស្ថិរភាពពិតប្រាកដសិន។ ចាប់ពីពេលនោះមក វិស័យឯកជនពិតជាមានលក្ខណៈសកម្មយ៉ាងខ្លាំង។

បញ្ហាប្រឈមថ្មីៗ

នៅចន្លោះឆ្នាំ១៩៧៣ និងឆ្នាំ២០១៥ ផ្ទៃដីរាជធានីភ្នំពេញបានប្តូរពី ៣១០០ហិចតា ទៅដល់ ២៥៤០០ហិចតា។ ផ្ទៃដីកសិកម្ម និងដីបឹង ២១០០០ហិចតា ត្រូវបានប្រែក្លាយទៅជាដីក្រុង ឬក៏កំពុងត្រូវបានកសាងជាទីក្រុង។ ដូច្នេះភ្នំពេញបានក្លាយពីទីក្រុងមួយដែលមានទំហំតូចល្មម ព័ទ្ធជុំវិញទៅដោយដីស្រែនិងដីកសិកម្ម ហើយការផ្គត់ផ្គង់បន្លែបង្កានៅពេលនោះ គឺពឹងផ្អែកទៅលើកសិកម្មនៅជាយក្រុង ទៅជាទីក្រុងមួយដ៏ធំ ដែលពឹងផ្អែកទៅលើការផ្គត់ផ្គង់បន្លែបង្កាពីដែនដីមានចម្ងាយឆ្ងាយជាងមុន។ ទន្ទឹងនឹងគ្នានេះ ទីក្រុងដ៏ធំនេះបង្កើតបានមួយផ្នែកធំនៃទ្រព្យសម្បត្តិជាតិ ដោយសារសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន។ ការកែប្រែដ៏អស្ចារ្យ និងយ៉ាងលឿន នូវមុខមាត់នៃទីក្រុងនេះបាននាំឱ្យមានបញ្ហាប្រឈមថ្មីៗ ដូចជាការកើនឡើងនៃការបំពុលបរិស្ថាន ការកកស្ទះចរាចរណ៍ ឬទឹកជំនន់ដែលបណ្តាលមកពីការបាត់បង់បឹងបួធំៗជាច្រើន។ នៅចំពោះមុខបញ្ហាប្រឈមថ្មីៗទាំងនេះ ភ្នំពេញអាចត្រឡប់ចូលមកក្នុងស្ថានភាពផុយស្រួយសារជាថ្មី។ វាយតម្លៃលើហានិភ័យទាំងនេះ គឺប្រាកដជារឿងចាំបាច់គ្រប់កាលៈទេសៈ។

Sur les toits terrasse, des maisons en bois
et en maçonnerie sont bâties.

Wooden houses and masonry houses are built on the flat roofs.

នៅលើដំបូលអគារ គេសង់ផ្ទះឈើនិងផ្ទះឥដ្ឋ

II. Urgence de la reconstruction

Urgency of reconstruction

២. ភាពបន្ទាន់នៃការកសាងឡើងវិញ

Men Chandevy, enfant à l’époque, témoigne de son retour dans la ville. S.E. Thong Khon nous parle des premières décisions politiques et sociales et S.E. Mok Mareth de la difficulté de remettre en marche une ville entière. En contrepoint, Jean Marie Théodat narre l’impossible reconstruction de Port au Prince après le tremblement de terre.

Men Chandevy, a child at the time, recalls her return to the city. H.E. Thong Khon tells us about the first political and social decisions and H.E. Mok Mareth about the difficulty of restarting an entire city. By way of a counterpoint, Jean Marie Théodat describes the impossible rebuilding of Port au Prince after the earthquake.

អ្នកម្នាង ស៊ីសុវត្ថិ ម៉ែន ចាន់ទេវី ដែលជាកុមារីម្នាក់នៅឡើងកាលពីសម័យនោះ បានរ៉ាយរ៉ាប់ពីដំណើររបស់អ្នកម្នាងវិលត្រឡប់ចូលក្នុងទីក្រុងវិញ។ ឯកឧត្តម ថោង ខុន បានប្រាប់យើងពីសេចក្តីសម្រេចដំបូងៗផ្នែកនយោបាយនិងសង្គម ហើយឯកឧត្តម មុក ម៉ារ៉េត បានរៀបរាប់អំពីការលំបាកក្នុងការរៀបចំឲ្យទីក្រុងទាំងមូលដំណើរការឡើងវិញ។ ផ្ទុយទៅវិញ លោក Jean Marie Théodat បានពិពណ៌នាអំពីសភាពមិនអាចកសាងទីក្រុង Port au Prince ឡើងវិញបាន បន្ទាប់ពីរញ្ជួយដី។

Réception du riz par les réfugiés en Thaïlande, Mai 1983.
Refugees receiving rice in Thaïland, May 1983.
ជនភៀសខ្លួនទទួលអង្ករ នៅប្រទេសថៃ ឆ្នាំ១៩៨៣

© Dave Hillman

Etre jeune à Phnom Penh en 1979

Chandevy a presque dix ans quand elle revient à Phnom Penh avec sa famille en 1979. Elle raconte les débuts de cette nouvelle vie.

PAR NAK MONEANG MEN CHANDEVY

Chandevy et son père dans l'usine de clous où il travaillait et où ils habitaient.

Chandevy and her father in the nail factory where he worked and where they lived.

អ្នកម្នាង ចាន់ទេវី និង ឪពុករបស់អ្នកម្នាង នៅក្នុងរោងចក្រផលិតដែកគោល ឪពុករបស់អ្នកម្នាងធ្វើការ និង រស់នៅក្នុងរោងចក្រ

En 1979, j'avais moins de 10 ans quand j'ai retrouvé ma ville natale en empruntant des petits chemins à travers les champs et les rizières. Malgré mon jeune âge, des images que mes yeux capturaient comme autant de photos sont imprimées dans ma mémoire et certaines apparaissent encore clairement dans mes souvenirs. Je me revois avec ma mère et ma grand-mère, d'autres parents et des sœurs. Nous revenons de la province de Kandal à pied. Mes sœurs portent leurs sacs de vêtements et de la nourriture sur la tête. Comme de nombreuses autres familles qui revenaient à Phnom Penh, nous étions extenués et nous nous reposions sur le bord des chemins ou des trottoirs quand il y en avait pour faire une halte. Quand nous sommes entrés dans Phnom Penh, la rue était calme et on voyait les gens scruter la foule avec l'espoir de retrouver des proches et des membres de leur famille.

Dès les premiers pas dans Phnom Penh, la ville florissante de jadis apparait vide, calme, lugubre, morne, sans âme. Les maisons abandonnées sont comme imprégnées de tristesse, semblant attendre le retour des anciens habitants. On ne voit aucune voiture ni aucun autre mode de transport. Les rues sont envahies de feuilles mortes et d'herbes folles. Une sensation de malaise flotte dans l'air ; pas d'eau propre, d'électricité ni de soins médicaux. La ville est d'une tristesse insigne.

Autour de moi les survivants du régime de Pol Pot cherchent des membres de leur famille disparus. Ils sont en haillons. Jeunes ou vieux, ils sont tous maigres et pâles. Seuls leurs yeux sont grands ouverts, cherchant des voisins, des personnes de leur famille. Ce qui me frappe aussi, c'est l'angoisse des gens qui n'osent pas vivre dans les maisons et qui ont peur des lieux fermés. Ils préfèrent camper dans la rue. Partout, on entend des récits tragiques. Dans chaque famille, le soir après le dîner, les grands parents ou les parents racontent toutes les horreurs vécues pendant le régime de Pol Pot.

Nous nous installons à Chak Angrè Krom, le long du fleuve Tonlé Bassac, dans une maison qui servait autrefois de bureau à une usine de clous qui redémarrait ses activités. D'autres familles se sont installées dans une sorte de hangar pas loin de nous. Chaque famille cloisonne alors son espace avec une plaque de contreplaqué pour délimiter son périmètre. Nous avons peur de vivre isolés et les gens se rassemblent instinctivement. La proximité est recherchée. Notre maison est petite mais elle accueille deux ou trois autres familles en plus de nous. Au moins une personne par famille travaille dans l'usine de clous. Mon père, qui était médecin avant 1975, travaille aussi à la fabrication des clous.

© Françoise Demulder / Succession Demulder / Roger-Viollet / The Image Works

Cambodgiens essayant d'éviter les roquettes lancées par l'Armée Khmer rouge, février 1974.

Cambodians trying to avoid the rockets launched by the Khmer Rouge army, February, 1974.

ប្រជាពលរដ្ឋខ្មែរខំរត់គេចពីគ្រាប់ផ្លោងដោយទាហានខ្មែរក្រហម ទីក្រុងភ្នំពេញ ខែកុម្ភៈ ឆ្នាំ១៩៧៤

Je suis la benjamine de la famille. Mon activité principale consiste à aller à l'école qui a rouvert. Trop jeune, je n'ai normalement pas le droit d'y aller, mais je suis ma grande sœur. Pendant les récréations, nous jouons avec les autres enfants, mais mes parents me l'ont rapidement interdit car il n'était pas permis de laisser jouer des filles avec des garçons. En compensation en 1985-1986, mon père me fait lire des livres ramenés d'un centre culturel russe pas trop loin de chez nous. Mon autre occupation est d'aller collecter l'eau avec ma sœur et d'aider aux tâches ménagères. À cette époque, il n'y a pas d'eau courante. Des vendeurs privés utilisent une pompe pour collecter l'eau du Tonlé Bassac. Elle est mise dans des bidons métalliques recyclés, utilisés initialement pour les huiles industrielles et le carburant d'essence. Ces bidons remplis d'eau sont ensuite mis sur des charrettes que nous tirons et poussons jusqu'à la maison. Ensuite, il faut traiter l'eau avec du *sach chou*, un produit local très acide qui a pour effet d'éclaircir et de décontaminer l'eau. Je dois participer à diverses tâches, y compris celles qui demandent de la force physique. C'était le lot de beaucoup de familles dont les enfants sont uniquement des filles ou dont les hommes et les ainés sont absents de la maison. Dans mon cas, les deux parents travaillent (ma mère au marché, mon père à l'usine), une de mes sœurs est partie faire des études en Russie, et mon frère est au Vietnam. Je m'occupe donc des tâches ménagères (cuisine, lessive, ménage). A cette

Il faut traiter l'eau avec du sach chou, un produit local très acide qui a pour effet de l'éclaircir et de la décontaminer.

Sortie d'école en 1982. / End of school day, 1982.

សិស្សចេញពីសាលារៀន ឆ្នាំ១៩៨២

© AKP

époque, les conditions de vie sont pénibles, pour les femmes comme pour les hommes. Il y a une égalité dans la difficulté et la dureté de la vie. Ce qui m'a aussi beaucoup marqué, c'est de voir que la solidarité est toujours restée très forte entre les gens. Même si les familles sont très pauvres, on partage toujours nos vivres. Il est aussi très fréquent de rendre visite aux autres membres de la famille, même éloignés. À cause de la guerre et des pertes engendrées, les survivants de chaque famille cherchent à retisser et à resserrer les liens.

Les survivants de chaque famille cherchent à retisser et resserrer les liens.

Nous n'aimons pas être seuls quand nous nous déplaçons. Nos peurs sont liées aux récits des personnes plus âgées qui parlent tout le temps de fantômes et de morts. Cela marque beaucoup notre imagination. Cette peur des fantômes va poursuivre ma génération pendant longtemps.

Nous avons droit à des rations alimentaires distribuées de façon stricte. Grâce au travail de mon père, nous avons du riz, distribué par l'usine, et de la farine pour faire des gâteaux. Nous recevons aussi des poissons, mais bien sûr peu de viande et pas du tout de lait.

Les conditions d'étude sont difficiles mais nous n'avons pas le choix. Parfois, nous n'avons ni table ni chaise. Mais le côté positif est que nous recevons alors une éducation solide car les professeurs et institutrices survivants du régime Khmer rouge ont tous été formés pendant ou avant l'époque du Sangkum Reastr Nyum. Ils nous ont transmis des connaissances culturelles et historiques très complètes, ainsi qu'un enseignement moral et une éducation solide qui, en revanche, font défaut aujourd'hui.

Je me souviens aussi qu'après avoir retrouvé notre maison familiale d'antan, située dans le quartier de Toul Svay Prey à côté de la prison de Toul Sleng[1], nous sommes allés la visiter. Ma mère y a trouvé par hasard la photo de son frère. Depuis, la hantise nous poursuit et nous n'y sommes pas retournés.

On a souvent dit «rien ne vaut la jeunesse». Mais moi, je dis «rien de vaut la liberté». Durant ces premières années, la ville de Phnom Penh évolue lentement et la vie recommence tant bien que mal. Ce qui nous manque, alors, c'est une nouvelle «façon de vivre», car après le génocide, nous survivons en attendant des jours meilleurs.

Quelques années plus tard, la vie de la population s'améliore de jour en jour. Tout semble se développer, surtout dans des domaines prioritaires tels que l'éducation. Le gouvernement a pu envoyer la génération de mes frères et sœurs étudier à l'étranger, en particulier en URSS et au Vietnam. De retour au Cambodge, ces gens formés ont aidé à reconstruire le pays. Après l'impression de grande désolation que j'ai ressentie au sortir du régime Khmer rouge, je sens désormais que la ville a retrouvé son âme.

Les Accords de Paris de 1993 ont amorcé une transition importante avec le retour de la Royauté et une ouverture à l'international. À partir de ce moment, la ville change alors beaucoup. C'est aussi le moment du retour des Khmers partis à l'étranger. Ces derniers vont renforcer les capacités de formation, comme à l'Université Royale des Beaux-Arts. Les premiers contrastes sociaux et géographiques au sein de Phnom Penh se dessinent, favorisés par un important exode rural vers la capitale, ainsi que par les emplois dans les usines textiles. Cette nouvelle population s'agglomère et s'installe dans des espaces libres de la ville ou en périphérie, créant souvent des zones de précarité.

Les deux guerres civiles et le régime khmer rouge ont causé de grandes destructions sociales, économiques et culturelles au Cambodge. Dans ce pays autrefois décrit comme étant «le pays du sourire», retrouver son identité prend beaucoup de temps. Aujourd'hui, avec tout ce qui a été fait pour moderniser la ville, les années perdues ont été rattrapées.



© AKP

A côté de la fontaine, boulevard Preah Sihanouk, 1982.

By the fountain, Boulevard Preah Sihanouk, 1982.

នៅជិតនាគបាញ់ទឹក មហាវិថីព្រះសីហនុ ឆ្នាំ១៩៨២

1. L'ancien lycée de Tuol Sleng est devenu une prison et un centre de tortures sous le régime des Khmers rouges. En 1979, elle est transformée en lieu de mémoire que l'on peut visiter. Les très nombreuses photographies de détenus assassinés dans ce lieu y sont exposées.

Young in Phnom Penh in 1979

Chandevy was almost six years old when she came back to Phnom Penh with her family in 1979. She gives an account of the early stages of this new life.

BY NEAK MONEANG SISOWATH MEN CHANDEVY

In 1979, I was about six years old when I got back to my birth city after following pathways through the fields and rice paddies. Although I was young, the images that my eyes captured are like photographs imprinted in my memory and some still show up clearly in my recollections. I can see myself with my mother and grandmother, other relatives, and my sisters. We are returning from Kandal Province on foot. My sisters are carrying their bags of clothing and food on their heads.

Like so many other families returning to Phnom Penh, we are exhausted and so we take breaks along the road or sidewalk. When we get into Phnom Penh, the streets are quiet. We can see other people looking through the crowd in the hope of finding family members or close relatives.

After stepping into Phnom Penh, the formerly burgeoning city appears empty, quiet, dreary, dismal, spiritless. The abandoned houses seem overcome by sadness, seemingly awaiting the return of their former occupants. No automobile or any other form of transportation in sight. The streets are covered with dead leaves and wild grass. A kind of uneasiness is in the air; no clean water, no electricity, no medical care. A distinctive sadness pervades the city.

Around me the survivors of the Pol Pot regime are looking for family members who went missing. They are clothed in rags. They are thin and pale, young and old alike. Only their eyes are wide open in search of neighbors or family members. What surprises me as well is the anxiety people feel: they don't dare live in the houses and are afraid of closed spaces. They prefer camping out on the street. Everywhere, tragic stories are being told. In every family, after supper, the grandparents or parents recount all the atrocities they experienced under the Pol Pot regime.

We settle in Chak Angre Krom, along the Tonle Bassac River, in a house that was once used as an office for a nail factory now going back into business. Other families settle in a type of shed not far from us. Each family partitions off its space with panels of plywood. People are afraid of being isolated so they gather together instinctively. Closeness is desired. Our house is small but is home to two or three other families in addition to ours. At least one member of each family works at the nail factory. My father who was a doctor until 1975 also makes nails for a living.

I am the youngest child in the family. My main occupation is school, which has reopened. Because of my young age, I should not have been allowed in school but I followed my big sister there. During recess, we play with the other children but my parents quickly forbid it because girls should not play with boys. To make up for it, in 1985–1986, my father has me read books that he brought back from the Russian Cultural Center, not far from where we live. I also have to collect water with my sister and help with chores. There is no running water. Private sellers use a pump to get water from the Tonle Bassac that they put in recycled metal barrels initially meant for oil and gasoline.

Food rations are strictly distributed. With my father working, we get an allowance of rice from the factory, and flour for cake-making.

The barrels are filled with water and put on carts that we pull or push to the house. The water then has to be treated with *sach chou*, a very acidic local product which clarifies and purifies the water. I have to do various chores, even those that require physical strength. Many families with only girls or where the men and older siblings are away from home function that way. In my case, both my parents work (my mother in the market, my father at the factory). One of my sisters has left to study in Russia and my brother has gone to Vietnam. I do housework (cooking, laundry, cleaning).

At that time, living conditions are hard for both women and men: life is equally difficult and harsh. I am also impressed with the solidarity that always remained strong among people. The families are very poor but everyone shares what they have. People also frequently visit other family members, even those living far away. Because of the war and the losses sustained, each family's survivors seek to mend and tighten their bonds.

We don't like to travel alone. Our fears go back to what our elders always told about ghosts and the dead which has left a mark on our imagination. This fear of ghosts has haunted my generation for a long time.

Food rations are strictly distributed. With my father working, we get an allowance of rice from the factory, and flour for cake-making. We also get fish, but very little meat of course, and no milk.

Schooling is difficult, but we have no choice. Sometimes we don't even have desks or chairs. But on the positive side, we get a good education because the teachers who survived the Khmer Rouge were all trained during or after the *Sangkum Reastr Nyum* period. They pass on to their students a comprehensive understanding of culture and history as well as moral and sound education that is lacking today.

I also remember that after we found our former family home that was located in Tuol Svay Prey ward, beside the Tuol Sleng[1] prison, we visited the jail. There, my mother came across a photograph of her brother. We have been haunted by that ever since and have not gone back.

It has often been said that "nothing is better than youth." But I say that "nothing is better than freedom." During those early years, Phnom Penh gradually evolved, and life somehow started again. What we were missing then was a new "way of life" because after the genocide we were only surviving, awaiting better times.

A few years passed and people's lives were getting better day by day. Development was the byword, especially in priority fields such as education. The government was able to send my brothers and sisters' generation off to study abroad, particularly in the USSR and Vietnam. When they returned to Cambodia, these people used their training to help rebuild the country. After the incredible desolation that I had perceived at the end of the Khmer Rouge regime, I now felt that the city had found its soul.

The Paris Agreements of 1991 ushered in a major transition with the return of the royalty and an international opening up. From that time on, the city changed a great deal. The Khmers who had gone abroad started to return. They helped improve training capacity at the Royal University of Fine Arts for instance. The first social and geographical contrasts in Phnom Penh took shape, fostered by a major rural exodus to the capital and by work opportunities in textile factories. This new population wave gathered together and settled in empty spaces in the city or on its outskirts, often resulting in zones of precarious living conditions.

The genocidal war of the Khmer Rouge caused incalculable social, economic, and cultural devastation in Cambodia. In this country formerly described as "the country of smiles," recovering one's identity takes a long time. Today, all the efforts to modernize the city have made up for the lost years.

1. The former Tuol Sleng High School was turned into a prison and torture center during the Khmer Rouge regime. In 1979, it was made into a memorial site open to tours. A huge number of photographs of prisoners killed in the place are exhibited in it.

ជាក្មេងស្រីនៅភ្នំពេញឆ្នាំ១៩៧៩

ទេវី អាយុជិត៦ឆ្នាំ នៅពេលដែលនាងត្រឡប់មកភ្នំពេញវិញជាមួយគ្រួសារនាងនៅឆ្នាំ១៩៧៩ ។ នាងរៀបរាប់ពីពេលដំបូងនៃជីវិតថ្មីនេះ ។

ដោយអ្នកម្នាង ស៊ីសុវត្ថិ ម៉ែន ច័ន្ទទេវី

នៅឆ្នាំ១៩៧៩ ខ្ញុំអាយុតិចជាង ៦ ឆ្នាំនៅឡើយទេ ពេលដែលខ្ញុំត្រឡប់ចូលមកទីក្រុងកំណើតរបស់ខ្ញុំវិញ ដោយដើរតាមផ្លូវតូចៗ ឆ្លងកាត់វាលស្រែ។ ទោះបីជាខ្ញុំនៅក្មេងក៏ដោយ រូបភាពដែលខ្ញុំឃើញនៅពេលនោះគឺប្រៀបដូចជារូបថតដែលផ្តិតជាប់នឹងខួរក្បាលរបស់ខ្ញុំអ៊ីចឹង ហើយរូបភាពខ្លះនៅតែលេចឡើងច្បាស់នៅឡើយនៅក្នុងអនុស្សាវរីយ៍របស់ខ្ញុំ។ ខ្ញុំនៅចាំថា ខ្ញុំនៅជាមួយម្តាយខ្ញុំជីដូនខ្ញុំ និងជាមួយបងស្រីៗខ្ញុំផ្សេងទៀត។ ពួកខ្ញុំដើរមកពីខេត្តកណ្តាល។ បងខ្ញុំស្រីៗទូលសម្លៀកបំពាក់ និងម្ហូបអាហារ។

ដូចគ្រួសារជាច្រើនផ្សេងទៀតដែលត្រឡប់មកទីក្រុងភ្នំពេញដែរ ពួកខ្ញុំពិតជាអស់កម្លាំងខ្លាំងណាស់ ហើយពួកខ្ញុំឈប់សម្រាកនៅតាមផ្លូវ ឬនៅលើចិញ្ចើមផ្លូវច្រើនដង។ នៅពេលដែលខ្ញុំមកដល់ទីក្រុងភ្នំពេញ តាមផ្លូវស្ងប់ស្ងាត់ណាស់ ហើយខ្ញុំតែងឃើញគេទៅចោមរោមមើលកន្លែងដែលមានមនុស្សច្រើនដោយសង្ឃឹមថានឹងអាចជួបបងប្អូន ឬសមាជិកគ្រួសាររបស់គេ។

ចាប់ពីឈានជើងដល់ទីក្រុងភ្នំពេញភ្លាម ខ្ញុំឃើញទីក្រុងដ៏ស្រស់ស្អាតកាលពីមុននោះ ហាក់ដូចជានៅទទេរស្អាត ស្ងាត់ជ្រងំគួរឱ្យខ្លាច សោកសង្រេង និងគ្មានព្រលឹង។ ផ្ទះដែលគេបោះបង់ចោលដូចជាបង្កប់នូវក្តីក្រៀមក្រំហាក់ដូចជាកំពុងរង់ចាំអតីតម្ចាស់របស់វាត្រឡប់មកវិញ។ គេមិនឃើញមានឡាន ឬមធ្យោបាយដឹកជញ្ជូនណាមួយឡើយ។ ស្លឹកឈើងាប់ជ្រុះនៅរាយបាយពេញថ្នល់ ហើយថ្នល់មានស្មៅដុះពីលើទ្រុបទ្រុល។ អារម្មណ៍មិនស្រួលចិត្តដូចជាអណ្តែតនៅគ្រប់កន្លែង គ្មានទឹកស្អាត គ្មានអគ្គិសនី និងគ្មានពេទ្យព្យាបាលទេ។ ទីក្រុងពិតជាពោរពេញទៅដោយភាពសោកសៅគួរឱ្យសង្វេគ។

ជុំវិញខ្ញុំ អ្នកនៅរស់ពីរបបខ្មែរក្រហម ខិតខំស្វែងរកសមាជិកគ្រួសារគេដែលបានបាត់ខ្លួនទៅ។ ពួកគេស្លៀកសម្លៀកបំពាក់ចាស់ៗ រហែករយ៉េរយ៉ៃ។ ទាំងក្មេងទាំងចាស់សុទ្ធតែស្គមស្គាំង ស្លេកស្លាំង។ មានតែភ្នែកពួកគេប៉ុណ្ណោះដែលបើកធំៗ ខំសម្លឹងស្វែងរកអ្នកជិតខាង ឬក៏សមាជិកគ្រួសាររបស់ពួកគេ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ដែរនោះ គឺការភ័យខ្លាចមិនហ៊ានរស់នៅក្នុងផ្ទះ ឬភ័យខ្លាចកន្លែងបិទជិត។ ពួកគេសុខចិត្តផ្តុំគ្នានៅតាមផ្លូវ។ គ្រប់កន្លែង ខ្ញុំតែងតែឮគេនិទានពីរឿងប្រកបដោយសោកនាដកម្ម។ នៅក្នុងគ្រួសារនីមួយៗ បន្ទាប់ពីស្រស់ស្រូបអាហារពេលល្ងាចហើយ ជីដូនជីតា ឬឪពុកម្តាយរៀបរាប់អំពីក្តីរន្ធត់ដែលពួកគេបានជួបប្រទះក្នុងសម័យ ប៉ុល ពត។

ពួកខ្ញុំទៅរស់នៅក្នុងផ្ទះមួយ នៅចាក់អង្រែក្រោម ជាប់មាត់ទន្លេបាសាក់។កាលពីមុន ផ្ទះនោះគឺជាការិយាល័យរបស់រោងចក្រផលិតដែកគោលដែលចាប់ផ្តើមដំណើរការឡើងវិញ។ គ្រួសារផ្សេងទៀតបានទៅរស់នៅក្នុងឃ្លាំងមិនឆ្ងាយពីពួកខ្ញុំប៉ុន្មានទេ។ គ្រួសារនីមួយៗបានយកបន្ទះក្តាកុងផ្លាកកេ មកបាំងដើម្បីកំណត់បរិវេណទីតាំងផ្ទះរបស់ខ្លួន។ យើងភ័យខ្លាចមិនចង់រស់នៅដាច់តែឯងនោះទេ ហើយមនុស្សម្នាបានទៅនៅជុំគ្នា នោះគឺសភាវគតិរបស់មនុស្ស។ គេចង់នៅជិតៗគ្នា ហើយផ្ទះខ្ញុំតូចទេ ប៉ុន្តែមានពីរឬបីគ្រួសារផ្សេងទៀតមករស់នៅជាមួយពួកខ្ញុំដែរ។ ក្នុងគ្រួសារនីមួយៗ យ៉ាងហោចណាស់ក៏មានសមាជិកម្នាក់ដែរ ទៅធ្វើការនៅក្នុងរោងចក្រដែកគោលនោះ។ ឪពុកខ្ញុំដែលមុនឆ្នាំ១៩៧៥ ជាគ្រូពេទ្យ ក៏ធ្វើការក្នុងរោងចក្រដែកគោលដែរ។

© AKP

Le Boulevard Preah Norodom en 1982. / Boulevard Preah Norodom in 1982. មហាវិថីព្រះនរោត្តមនៅឆ្នាំ១៩៨២

ខ្ញុំជាកូនពៅនៅក្នុងគ្រួសារ។ ការងារសំខាន់របស់ខ្ញុំគឺត្រូវទៅសាលារៀនដែលចាប់ផ្តើមបើកទ្វារសារជាថ្មី។ ដោយសារខ្ញុំនៅក្មេងពេក ខ្ញុំគ្មានសិទ្ធិទៅសាលារៀនទេ ប៉ុន្តែខ្ញុំទៅតាមបងស្រីរបស់ខ្ញុំ។ នៅពេលចេញលេង ពួកខ្ញុំលេងជាមួយក្មេងផ្សេងទៀត ប៉ុន្តែឪពុកម្តាយខ្ញុំហាមខ្ញុំមិនឱ្យលេងទេ ពីព្រោះពួកគាត់មិនអនុញ្ញាតឱ្យក្មេងស្រីលេងជាមួយក្មេងប្រុសទេ។ ជំនួសមកវិញ នៅឆ្នាំ១៩៨៥-១៩៨៦ ឪពុករបស់ខ្ញុំបានយកសៀវភៅពីមជ្ឈមណ្ឌលវប្បធម៌រុស្ស៊ីដែលនៅមិនឆ្ងាយពីផ្ទះរបស់ពួកខ្ញុំប៉ុន្មានទេនោះ មកឱ្យខ្ញុំអាន។ ការងាររបស់ខ្ញុំមួយទៀតគឺទៅជួយរែកទឹកបងស្រីខ្ញុំ និងជួយការងារផ្ទះ។ នៅសម័យនោះមិនទាន់មានទឹកម៉ាស៊ីនទេ។ អ្នកលក់ទឹកឯកជនប្រើម៉ាស៊ីនបូមទឹកពីក្នុងទន្លេបាសាក់មកលក់។ គេបូមទឹកដាក់នៅក្នុងធុងដែក ដែលដើមឡើយគឺជាធុងសាំង។ ធុងសាំងដែលមានទឹកពេញនេះត្រូវបានគេដាក់នៅលើរទេះ ហើយអូសផង រុញផង រហូតដល់មុខផ្ទះ។ បន្ទាប់មក យើងត្រូវយកទឹកនេះទៅកូរជាមួយសាច់ជូរឱ្យថ្លា និងអាចកាត់បន្ថយមេរោគ។ ខ្ញុំត្រូវចូលរួមធ្វើការជាច្រើនផ្សេងទៀត រួមទាំងការងារដែលតម្រូវឱ្យប្រើកម្លាំងផងដែរ។ គ្រួសារភាគច្រើនគឺត្រូវធ្វើដូច្នេះ ជាពិសេស សម្រាប់គ្រួសារដែលមានតែកូនស្រីៗ ហើយប្រុសៗ ឬក៏បងៗមិននៅផ្ទះ។ នៅក្នុងករណីគ្រួសារខ្ញុំ ឪពុកម្តាយខ្ញុំទាំងពីរនាក់សុទ្ធតែធ្វើការ។ ម្តាយខ្ញុំលក់ដូរនៅផ្សារ ឪពុកខ្ញុំធ្វើការនៅរោងចក្រ។ បងស្រីខ្ញុំម្នាក់ចេញទៅបន្តការសិក្សានៅប្រទេសរុស្ស៊ី បងប្រុសរបស់ខ្ញុំម្នាក់ទៅរៀននៅវៀតណាម។ ដូច្នេះ ខ្ញុំត្រូវធ្វើការងារផ្ទះ ដូចជាដាំបាយ ចម្អិនម្ហូប បោកខោអាវ ជូតផ្ទះ។ នៅសម័យនោះ ជីវិតរស់នៅលំបាកណាស់ លំបាកទាំងស្រី ទាំងប្រុស។ អ្នកណាក៏លំបាកដូចគ្នាដែរក្នុងជីវភាពប្រចាំថ្ងៃ។ អ្វីដែលខ្ញុំនៅចាំច្បាស់ដែរនោះគឺថា ខ្ញុំឃើញមនុស្សម្នាសាមគ្គីគ្នាខ្លាំងនៅឡើយ។ ទោះបីជាយើងក្រីក្រខ្លាំងក៏ដោយ ក៏យើងតែងតែចែករំលែកម្ហូបអាហារជាមួយគ្នាដែរ។ ជាញឹកញាប់យើងតែងទៅលេងសួរសុខទុក្ខសមាជិកគ្រួសារផ្សេងទៀត ទោះបីជាពួកគាត់នៅឆ្ងាយក៏ដោយ។ ដោយសារសង្គ្រាម និងការបាត់បង់ជីវិតក្នុងសង្គ្រាមនេះ ក្រុមគ្រួសារនីមួយៗដែលនៅរស់តែងតែខិតខំផ្សារភ្ជាប់ និងពង្រឹងទំនាក់ទំនងគ្នាឡើងវិញ។

យើងមិនចូលចិត្តធ្វើដំណើរតែឯងទេ។ ក្មេងៗតែងតែខ្លាចដោយសារចាស់ៗឧស្សាហ៍និយាយរៀបរាប់ពីរឿងខ្មោច និងមនុស្សស្លាប់។ ដូច្នេះ យើងតែងតែស្រម៉ៃឃើញខ្មោច និងខ្លាចខ្មោចបែបនេះ។ រឿងខ្លាចខ្មោចនេះបានបន្តដិតដាមក្នុងខួរក្បាលមនុស្សជំនាន់ខ្ញុំយូរតមកទៀត។

យើងមានសិទ្ធិទទួលរបបអាហារដែលគេចែកជូនតាមរបៀបមួយប្រិតប្រៀង។ ដោយសារការងាររបស់ឪពុកខ្ញុំ យើងទទួលបានអង្ករដែលរោងចក្រចែកជូន និងម្សៅមីសម្រាប់ធ្វើនំ។ ពួកខ្ញុំក៏ទទួលបានត្រី សាច់តិចតួចដែរ ប៉ុន្តែគ្មានទឹកដោះគោទេ។ លក្ខខណ្ឌនៃការសិក្សារៀនសូត្រគឺលំបាកណាស់ ក៏ប៉ុន្តែយើងគ្មានជម្រើសអ្វីផ្សេងទេ។ ពេលខ្លះ ក្នុងថ្នាក់រៀនគ្មានទាំងតុទាំងកៅអីផង។ ប៉ុន្តែចំណុចវិជ្ជមាននៅពេលនោះគឺថាយើងទទួលបានការអប់រំមួយដ៏ល្អ ពីព្រោះ លោកគ្រូ អ្នកគ្រូដែលនៅរស់ពីរបបខ្មែរក្រហម សុទ្ធតែធ្លាប់ទទួលបានការបណ្តុះបណ្តាលក្នុងសម័យ ឬមុនសម័យសង្គមរាស្ត្រនិយម។ ពួកគាត់បានផ្តល់ចំណេះដឹង វប្បធម៌ និងប្រវត្តិសាស្ត្រពេញលេញដល់ពួកយើង ព្រមទាំងមានបង្រៀនផ្នែកសីលធម៌ក្នុងការរស់នៅទៀតផង នោះគឺជាការអប់រំមួយដែលស៊ីជម្រៅ ដែលយើងមិនឃើញមានក្នុងការបង្រៀនពេលបច្ចុប្បន្ននេះទេ។

ខ្ញុំនៅចាំផងដែរថា បន្ទាប់ពីរកឃើញផ្ទះរបស់គ្រួសារខ្ញុំពីមុន ដែលនៅជិតសង្កាត់ទួលស្វាយព្រៃ ម្តុំគុកទួលស្លែង[1] យើងក៏បានទៅមើលផ្ទះ និងចូលទៅក្នុងគុកទួលស្លែងនោះ (ព្រោះជាសាលារបស់បងស្រីខ្ញុំ)។ នៅក្នុងគុកនោះ ម្តាយខ្ញុំបានរកឃើញរូបថតបងប្រុសគាត់ដោយចៃដន្យ។ តាំងពីពេលនោះមក រូបបងប្រុសម្តាយខ្ញុំតែងតែអន្ទោលតាមប្រាណយើងជារៀងរហូត ហើយយើងក៏មិនដែលត្រឡប់ទៅទីកន្លែងនោះវិញទៀតឡើយ។

ភាគច្រើនគេនិយាយថា គ្មានអ្វីប្រសើរជាង "យុវវ័យ" ទេ។ ប៉ុន្តែខ្ញុំនិយាយថា គ្មានអ្វីប្រសើរជាង "សេរីភាព" ទេ។ នៅក្នុងបណ្តាឆ្នាំដំបូងៗនេះ ទីក្រុងភ្នំពេញមានការវិវឌ្ឍយឺតៗ ហើយការរស់នៅក៏ចាប់ផ្តើមឡើងវិញយ៉ាងលំបាកលំបិនដែរ។ អ្វីដែលយើងខ្វះខាតនៅពេលនោះ គឺរបៀបរស់នៅថ្មី ពីព្រោះ បន្ទាប់ពីរបបប្រល័យពូជសាសន៍បានដួលរលំទៅ យើងប្រឹងត្រដររស់ឡើងវិញដោយរង់ចាំថ្ងៃដែលមានពន្លឺល្អជាងមុន។

ប៉ុន្មានឆ្នាំក្រោយមកទៀត ជីវិតប្រជាជនមានភាពប្រសើរឡើង ពីមួយថ្ងៃទៅមួយថ្ងៃ។ អ្វីៗហាក់ដូចមានការអភិវឌ្ឍឡើង ជាពិសេស នៅក្នុងវិស័យអាទិភាពដូចជា វិស័យអប់រំជាដើម។ រដ្ឋាភិបាលបានបញ្ជូនមនុស្សជំនាន់បងប្រុស បងស្រីខ្ញុំទៅសិក្សានៅបរទេស ជាពិសេស នៅរុស្ស៊ី និងនៅវៀតណាម។ ពេលត្រឡប់មកដល់កម្ពុជាវិញ អ្នកដែលទទួលបានការណ្តុះបណ្តាលនោះ បានជួយកសាងប្រទេសឡើងវិញ។ បន្ទាប់ពីបានឃើញភាពខ្ទេចខ្ទី ក្រោយពីរបបខ្មែរក្រហមបានកន្លងផុតទៅ នៅពេលនេះ ខ្ញុំមានអារម្មណ៍ថា ទីក្រុងមានព្រលឹងឡើងវិញហើយ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ បាននាំកម្ពុជាឈានទៅដល់ដំណាក់កាលអន្តរកាលមួយដ៏សំខាន់ ជាមួយនឹងការយាងត្រឡប់មកវិញរបស់ព្រះមហាក្សត្រ និងការបើកចំហទៅអន្តរជាតិ។ ចាប់តាំងពីពេលនោះមក ទីក្រុងបានផ្លាស់ប្តូរយ៉ាងច្រើន។ វាក៏ជាពេលដែលខ្មែរនៅបរទេសត្រឡប់មកវិញដែរ។ អ្នកដែលត្រឡប់មកវិញនេះនឹងជួយពង្រឹងសមត្ថភាពបណ្តុះបណ្តាល ដូចជានៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាដើម។ យើងក៏ចាប់ផ្តើមឃើញមានភាពខុសគ្នាខាងផ្នែកសង្គម និងភូមិសាស្ត្រនៅទីក្រុងភ្នំពេញ គឺដោយសារចំណាកស្រុកយ៉ាងច្រើន ប្រជាពលរដ្ឋចេញពីជនបទចូលមករស់នៅក្នុងទីក្រុងដោយសារមកធ្វើការងារនៅក្នុងរោងចក្រកាត់ដេរ។ ប្រជាជនថ្មីនេះមករស់នៅក្នុងទីក្រុង តាមទីតាំងដែលទំនេរនៅក្នុងទីក្រុង ឬនៅជាយក្រុង ហើយជាញឹកញាប់ បង្កើតបានជាតំបន់គ្មានសណ្តាប់ធ្នាប់។

សង្គ្រាមប្រល័យពូជសាសន៍នៃរបបខ្មែរក្រហម បានបណ្តាលឱ្យប្រទេសកម្ពុជាទទួលរងការខូចខាតយ៉ាងដំណំ ទាំងផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌។ នៅក្នុងប្រទេសនេះ ដែលកាលពីមុនគេតែងតែនិយាយថាជាប្រទេសនៃ "ស្នាមញញឹម" ដែលការរកឱ្យឃើញនូវអត្តសញ្ញាណរបស់ខ្លួនឡើងវិញនេះពិតជាត្រូវចំណាយពេលយូរណាស់។ បច្ចុប្បន្ននេះ ជាមួយអ្វីដែលសម្រេចបានកន្លងមក ដើម្បីធ្វើទំនើបកម្មទីក្រុង យើងបានតាមទាន់ពេលវេលាដែលបានបាត់បង់កន្លងមកនោះហើយ។

1. អតីតសាលាបឋមសិក្សាទួលស្លែងបានក្លាយទៅជាមន្ទីរឃុំឃាំង និងធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម។ នៅឆ្នាំ១៩៧៩ សាលានេះត្រូវបានប្រែក្លាយឱ្យទៅជាមជ្ឈមណ្ឌលនៃការចងចាំដែលគេអាចទៅទស្សនាបាន។ រូបថតរបស់អ្នកទោសជាច្រើនដែលត្រូវបានគេសម្លាប់ចោល គឺមានដាក់តាំងនៅក្នុងសារមន្ទីរនេះ។

Piloter la reconstruction au lendemain des Khmers rouges

Au cours des années 1980, le reconstruction de Phnom Penh est un véritable défi. L'inventivité et l'implication de la population, ainsi que l'appui de nombreux acteurs extérieurs ont permis de trouver des solutions au jour le jour et d'éviter une catastrophe humanitaire. **PAR S.E. THONG KHON**

© AKP

Dans la ville vide, seuls circulent les militaires, 1979.

In the empty city, nothing but soldiers, 1979.

នៅក្នុងទីក្រុងទទេស្អាត មានតែកងទ័ពប៉ុណ្ណោះដើរចល័ត ឆ្នាំ១៩៧៩

De 1970 à 1975, entre le coup d'Etat et la prise de pouvoir des Khmers rouges, Phnom Penh change radicalement. En raison des bombardements sur l'Est du pays, les réfugiés affluent et la ville passe de 700 000 à 2 millions d'habitants en quelques années.
La prise de pouvoir des Khmers rouges met un coup d'arrêt brutal à cette croissance urbaine incontrôlée, et Phnom Penh est désertée. Les habitants sont évacués de force vers les campagnes. Traités comme des prisonniers, nombre d'entre eux meurent d'épuisement et de faim sur les sites de travail forcé aux champs, et nombre d'autres sont exécutés. Pour les survivants qui reviennent en 1979, la situation est très précaire.

LES DÉFIS DE LA RECONSTRUCTION

Comment pouvait-on mettre en œuvre des chantiers gigantesques de reconstruction et, en même temps, gérer une marée humaine qui afflue à Phnom Penh ? Le grand nombre de réfugiés qui convergent vers Phnom Penh constitue un problème majeur. Le premier souci est de déterminer et de différencier les habitants ordinaires des forces Khmers rouges infiltrées. Au début, l'accès à la ville est donc interdit afin de mieux en contrôler les accès et de se protéger contre une éventuelle attaque Khmère rouge. Différentes stratégies étaient mises en œuvre pour identifier les Khmers rouges parmi le flot de réfugiés. Par exemple, pour les identifier parmi tous les gens armés, le jour, nous portions des AK-47 (Kalachnikov), et la nuit, nous les remplacions par des M-16.

Panneau de campagne d'éducation publique, 1990.

Public Education Campaign billboard, 1990.

ផ្ទាំងឃោសនា ឆ្នាំ១៩៩០

© JM Gallet

LES PRÉMISSES DE LA RECONSTRUCTION, LA MISE EN PLACE D'UNE ADMINISTRATION PUBLIQUE

En cette « année zéro », il faut non seulement reconstruire la capitale, mais aussi le pays tout entier, et ce, avec de très faibles moyens.
En février 1979, deux premières équipes de travail sont constituées : la première à Chrang Chamres (route nationale 5) et la deuxième à la Cité des 100 toits (route nationale 4). Leur mission est de recruter les intellectuels survivants, les anciens fonctionnaires et les anciens étudiants. Le premier groupe, dont je fais partie, est composé de 25 personnes venant du Nord de Phnom Penh, et de plus de 70 personnes venant de l'Ouest. Notre première action est de mettre en place l'école politique centrale dont les enseignements de la première promotion sont donnés par Samdech Techo Hun Sen, SE. Say Phouthorng, SE. Bou Thong et SE Y Yaun.
Après cette formation, plusieurs groupes de travail sont constitués. Leur principale tâche est de recruter et de former des personnels administratifs, officiers et employés pour gérer les différents lieux de Phnom Penh.
Le groupe initial de 60 personnes, dont je fais partie, parfait sa formation au Vietnam. À notre retour, 32 personnes, dont moi-même, sont affectées à la Municipalité de Phnom Penh. Les autres sont réparties dans les différents Ministères nouvellement créés.
La Municipalité de Phnom Penh a créé par ailleurs des écoles politiques et administratives, à différents niveaux, pour former des fonctionnaires dans tous les domaines. Phnom Penh est divisée en 4 régions centrales et 12 communes périphériques. En 1980, avant les élections, les régions sont divisées en quartiers. En 1983 puis en 1986, deux nouvelles réformes administratives permettent à Phnom Penh d'annexer une partie de la province de Kandal. La ville atteint alors 401 km². Entre 1979 et 1983, je suis nommé par le PRPK[1] officier et chef du Bureau du Personnel et de l'organisation administrative de la ville avec pour fonctions le recrutement des agents, ainsi que l'organisation et la structuration des services. De 1983 à 1985, je suis nommé Maire adjoint de Phnom Penh en charge de la santé, de l'éducation, de la culture et des affaires sociales.

LA RECONSTRUCTION FACE À L'URGENCE

De 1979 à 1990, environ 10 000 employés sont recrutés et formés pour travailler pour la municipalité de Phnom Penh. Pendant cette période, les priorités et les grands objectifs de la reconstruction et du développement de Phnom Penh sont tous définis pour faire face à l'urgence.

La défense de Phnom Penh

La priorité est tout d'abord la défense de la ville contre un éventuel retour des Khmers rouges. Ces derniers bombardent la ville depuis le Nord-Est (Mok Kampoul) et l'Ouest (Samrong Krom). Les alentours de Phnom Penh doivent être sécurisés pour prévenir les attaques contre les dépôts de pétrole de Russey Keo et l'aéroport de Pochentong.
Concrètement, nous travaillons dans la journée au service des citoyens et nous prenons les armes le soir pour effectuer des rondes autour de la capitale. Nous formons et motivons aussi les populations locales pour participer à la surveillance et à la défense de la ville. Par ailleurs, douze jeunes sont recrutés et formés pour devenir des officiers de police. Parmi eux, S.E. Neth Savoeun, qui occupe aujourd'hui le poste de Chef National de la Police et S.E. Thong Lim, Chef national adjoint.

Assurer les services médicaux et les soins

Aux premiers temps de la reconstruction, les conditions de santé restent très précaires. Par exemple en 1983, nous devons faire face à des épidémies de choléra et de dengue hémorragique qui sont jugulées grâce à l'intervention des associations de médecins de la ville de Hô Chi Minh.
Afin de répondre aux enjeux de santé publique, la Faculté de Médecine est rouverte début 1980 sous le nom de Faculté mixte de Médecine, Pharmacie, Odontostomatologie. Les anciens étudiants sont invités à reprendre leurs études afin d'achever leur formation. Les enseignants sont recrutés parmi les quelques médecins, pharmaciens et dentistes rescapés, tout cela avec l'assistance de médecins vietnamiens et de quelques médecins étrangers francophones en mission au Cambodge. Des ONG fournissent des livres, des équipements et du matériel médical de base. Grâce à cela, en 1987, il existe huit hôpitaux (2000 lits) gérés par le Ministère de la santé publique, ainsi que trois hôpitaux (400 lits), neuf infirmeries et sept dispensaires dans les arrondissements périphériques gérés par la Municipalité. Par ailleurs, un Centre national de protection des mères et des enfants et le Centre municipal de la santé maternelle et infantile sont en fonctionnement.
Pour répondre aux besoins urgents de santé publique, le Ministère de la Santé décide d'incorporer d'anciens infirmier(e)s ou sages-femmes à la formation pour devenir médecin.
La Radio, la télévision et l'affichage en ville sont utilisés pour lancer des campagnes d'hygiène publique. Notre slogan était « manger propre, loger propre, boire propre ! ».
Les soins aux enfants sont aussi une priorité. Un nombre important d'orphelins survivent dans les rues. La municipalité crée et gère trois orphelinats : Kolap1, Kolap2, Kolap 3, ainsi que Kolap 4 qui s'occupe plus spécifiquement d'handicapés et de femmes en difficultés sous le contrôle du Ministère des Affaires sociales

L'éducation

Pendant le Régime Khmer rouge, la plupart des intellectuels, y compris les enseignants et les professeurs, sont morts. Dans les premiers temps de la reconstruction, le Gouvernement s'est appuyé sur la méthode de l'éducation partagée pour reconstituer le corps éducatif. Le slogan était : « les personnes les plus éduquées enseignent aux personnes les moins instruites ; les personnes moins instruites enseignent aux non-éduqués » !

Réouverture de la Faculté de Médecine, 1982.

Reopening of the Medical Faculty, 1982.

មហាវិទ្យាល័យវេជ្ជសាស្ត្របើកទ្វារឡើងវិញ ឆ្នាំ១៩៨២

© AKP

© Fond Khieu Kanharith

Les cocotiers plantés par les khmers rouges autour du marché central, 1979.

The coconut trees which were planted by the Khmer Rouge around the central market, 1979.

ដើមត្នោតដែលពួកខ្មែរក្រហមដាំនៅជុំវិញផ្សារធំថ្មី ឆ្នាំ១៩៧៩

© AKP

Le pont nord détruit pendant la guerre.

The North bridge destroyed during the war.

ស្ពានជ្រោយចង្វារបំផ្លាញក្នុងសម័យសង្គ្រាម

1. Le PRPK, au pouvoir à partir de janvier 1979, est le Parti Révolutionnaire du Peuple Khmer. Il deviendra par la suite le Parti du Peuple Cambodgien (PPC).

La relance du commerce local

La relance des activités économiques est une autre priorité majeure. Le régime des Khmers rouges a totalement détruit le secteur économique national et local. À Phnom Penh, des cocotiers avaient été plantés autour du marché central par les Khmers rouges. En 1983, la municipalité les enlève pour les replanter dans l'enceinte de l'hôpital pédiatrique. Nous avons été surpris de découvrir des squelettes humains sous les racines. Ce n'est qu'en 1984 que les stands du Marché Central peuvent reprendre leurs activités.

L'Habitat et la reconstruction des infrastructures urbaines

Après le 7 Janvier 1979, le Gouvernement autorise la population à revenir dans la ville et à occuper les maisons.

L'insécurité régnante alimente les peurs des gens. Ils recherchent la sécurité en cohabitant à côté d'autres familles et des forces militaires vietnamiennes et cambodgiennes. Cette promiscuité des premiers temps a, aujourd'hui encore, des répercussions sur les façons d'habiter la ville.

Après 1979, les habitants ne sont plus les mêmes qu'avant 1975. Seulement 30% des anciens habitants ont pu revenir et 70 % des nouveaux arrivants sont originaires des provinces. La population occupe alors les appartements vacants, mais des problèmes de maintenance, d'hygiène et de propreté apparaissent vite.

Certains bâtiments, qui avaient été détournés de leurs usages premiers pendant les Khmers rouges, bénéficient de programmes de rénovation. Certains retrouvent leurs anciennes fonctions, d'autres en ont de nouvelles. Ce fut par exemple le cas de la Bibliothèque Nationale, qui avait été transformée en cuisine centrale par les Khmers rouges, mais qui est rouverte après 1979. Ou encore, le lycée de Chao Pogneayat (Tuol Svay Prey), qui fût transformé en centre de détention et de torture (S21) par les Khmers rouges, et qui devient dès 1979 le Musée National du Génocide. Le site de Choeung Ek, qui a servi de lieu d'exécution, est conservé tel quel pour devenir un lieu de mémoire du génocide.

La réparation des égouts fait aussi partie des priorités. Selon les témoignages de survivants, Phnom Penh avait été inondée lors de la crue de 1978. Les vannes qui évacuent l'eau vers le Tonlé Sap en saison sèche n'avaient pas été fermées au moment de l'évacuation des habitants de 1975. Ainsi, à chaque saison des pluies, l'eau et les alluvions du fleuve sont remontées dans les canalisations, créant de véritables bouchons qui se sont peu à peu solidifiés. C'est l'Ordre de Malte qui apporte les premières aides avec des hydrocureuses. Afin de commence à déboucher les canalisations.

Le problème de la propreté et de la gestion des déchets est tel que les personnels de la Municipalité et de tous les ministères sont mobilisés chaque samedi et dimanche pour nettoyer la ville avec des tracteurs et des remorques.

Le système d'eau potable est aussi inexistant. Des trois stations d'eau potable, seule celle de Phum Prek (près de la Faculté de médecine) est encore en état de fonctionner, mais avec seulement un moteur de pompage parmi les six disponibles. Avec l'aide vietnamienne et soviétique, nous avons remis en marche une partie de ce système de distribution.

L'électricité reste quant à elle un défi majeur pour la Municipalité en raison de l'abandon des trois centrales électriques.

Après la libération du pays, le 07 Janvier 1979, par le Front National de Solidarité pour le Sauvetage du Cambodge et avec le support et le soutien des troupes vietnamiennes, nous n'avons jamais perdu espoir malgré les énormes problèmes auxquels nous avons été confrontés. Notre rêve était de voir Phnom Penh rénovée et belle comme avant. Nous y sommes parvenus. Les stratégies et les plans d'action mis en place par le gouvernement dans la période la plus difficile y ont beaucoup contribué.

Carrying out and leading the reconstruction in the aftermath of the Khmer Rouge

During the 1980s, the reconstruction of Phnom Penh was a real challenge. The population's inventiveness and involvement, along with support from many foreign stakeholders, made it possible to find solutions one day at a time and avoid a humanitarian disaster. **BY S.E. THONG KHON**

From 1970 to 1975, between the coup d'état and the Khmer Rouge seizure of power, Phnom Penh underwent a dramatic change. The bombings in the eastern part of the country led to a population jump: the city population went from 700,000 to 2 million inhabitants in just a few years. The Khmer Rouge power seizure brutally stopped this uncontrolled urban growth. Phnom Penh was deserted. Its residents were forcibly evacuated to the countryside. Treated as prisoners, many of them died of exhaustion and starvation on the forced labor sites in the fields. Many others were executed. The survivors who returned in 1979 were in a very precarious situation.

THE CHALLENGES OF RECONSTRUCTION

How could huge reconstruction efforts be set up while managing the population influx in Phnom Penh? The large number of refugees moving to Phnom Penh was a major problem. The first concern was to differentiate regular city dwellers from Khmer Rouge infiltrators. In the early stages, access to the city was prohibited in order to better control who accessed it and provide protection against a possible Khmer Rouge attack. Different strategies were used to identify Khmer Rouge members among the flow of refugees. For example, in order to identify them among people bearing arms we carried AK-47s (Kalashnikov) in the daytime and we replaced them with M-16s at night.

THE STARTING POINT OF THE RECONSTRUCTION: SETTING UP A PUBLIC AUTHORITY

Early on, it was not just the capital that needed reconstruction but the entire country—with very limited resources.

In February 1979, the first two working groups were created: the first one at Chrang Chamres (National Highway 5) and the second one in the "City of 100 Roofs" (National Highway 4). Their responsibility was to recruit survivors who were intellectuals, former civil servants, and former students. The first group, which I was a part of, was made up of 25 people from northern Phnom Penh and over 70 persons from western Phnom Penh. Our first initiative was to set up a central school of politics. The first graduating class was taught by Samdech Techo Hun Sen, H.E. Say Phouthorng, H.E. Bou Thong, and H.E. Y Yaun.

After this creation, several working groups were set up. Their main task was to recruit and train administrative staff, officers, and workers to manage different sites in Phnom Penh.

The initial group of 60 people, which I was a part of, completed its training in Vietnam. At our return, 32 people, including me, were assigned to work in the Municipality of Phnom Penh. The others were distributed among the different newly established ministries.

The Municipality of Phnom Penh set up political and administrative schools at different levels to train civil servants in all areas. Phnom Penh was divided into four central regions and 12 surrounding communes. In 1980, prior to the elections, the regions were divided into wards. In 1983 and in 1986, two new administrative reforms enabled Phnom Penh to annex part of Kandal Province. The city then covered 401 km².

Between 1979 and 1983, the KPRP[1] appointed me as officer and chief of the office of personnel and administrative organization, with the responsibility of recruiting staff, as well as organizing and structuring services. From 1983 to 1985, I was deputy mayor of Phnom Penh, in charge of health, education, culture, and social affairs.

REBUILDING WHEN FACED WITH URGENCY

From 1979 to 1990, about 10,000 workers were recruited and trained to work for the Municipality of Phnom Penh. The priorities and main objectives of reconstruction and development in Phnom Penh all came under the umbrella of emergency.

Protecting Phnom Penh

Protecting the city against a possible return of the Khmer Rouge was a key priority. The Khmer Rouge were bombing the city from the northeast (Mok Kampoul) and west (Samrong Krom). The surroundings of Phnom Penh needed to be secured to prevent attacks on the oil depots in Russey Keo and Pochentong Airport.

In concrete terms, we worked in the daytime to serve citizens and took up arms at night to patrol around the capital. We provided training and motivation for the local communities to involve them in the surveillance and defense of the city. A dozen young officers were recruited and trained to become policemen. Among them were H.E. Neth Savoeun, now national chief of police, and H.E. Thong Lim, deputy national chief.

Providing medical services

Early on in the reconstruction, health conditions were very precarious. For example, in 1983, we were confronted with epidemics of cholera and dengue hemorrhagic fever that were successfully curbed with assistance from medical associations in Ho Chi Minh City.

To take on the challenges facing public health, the faculty of medicine was reopened in early 1980 as the Joint Faculty of Medicine, Pharmacy and Dental Surgery. Former students were invited to return to their studies in order to complete their training. Professors were recruited among the few doctors, pharmacists, and dentists who had survived, with the help of doctors from Vietnam and a number of French-speaking foreign doctors on mission in Cambodia. NGOs provided books, equipment, and basic medical equipment. The assistance led to the creation, in 1987, of eight hospitals (2,000 beds) managed by the Ministry of Public Health, along with three hospitals (400 beds), nine infirmaries and seven dispensaries in the surrounding districts managed by the Municipality. The National Center for Maternal and Child Protection and the Municipal Center for Maternal and Child Health were also operating.

To meet the public health sector's urgent needs, the Ministry of Health decided to include former nurses and midwives in the training to become doctors.

Public health campaigns were launched using radio, television, and outdoor ads in the city. Our slogan was "Clean eating, clean living, clean drinking!"

Childcare was also a priority. Many orphans were living on the streets. The municipality established and managed three orphanages: Kolap1, Kolap2 and Kolap3, as well as Kolap4 which focused more specifically on disabled people and women in difficulty, under the control of the Ministry of Social Affairs.

Education

Most intellectuals, including teachers and professors, lost their lives under the Khmer Rouge regime. In the early stages of reconstruction, the government used the shared education approach to rebuild the educational body. The slogan was: "the most educated teach the least educated; the least educated teach the uneducated"!

Reopening local businesses

Reviving economic activities was another major priority. The Khmer Rouge regime had utterly destroyed the national and local economic sector. In Phnom Penh, the Khmer Rouge had planted coconut trees around the Central Market. In 1983, the municipality had them removed and replanted within the Pediatric Hospital compound. We were surprised to discover human skeletons under their roots. The Central Market only reopened in 1984.

Habitat and urban infrastructure reconstruction

After January 7, 1979, the government authorized people to come back to the city and occupy the houses.

The prevailing insecurity fostered fear among the people. They found security by living next to other families and Vietnamese or Cambodian military forces. The early stages favored a closeness that still has repercussions on the way people dwell in the city today.

After 1979, inhabitants were not the same as those before 1975. Only 30% of former inhabitants were able to come back and 70% of new arrivals were from the provinces. People occupied vacant apartment buildings, but maintenance, hygiene, and cleanliness issues quickly arose.

Certain buildings whose original use had been lost during the Khmer Rouge period benefited from renovation programs. Some retrieved their former use, others were given new uses. For example, the National Library had been turned into a central kitchen by the Khmer Rouge but was reopened as a library after 1979. Chao Pogneayat High School (Tuol Svay Prey) had been converted into a detention and torture center (S21) by the Khmer Rouge and became the National Genocide Museum in 1979. The Choeung Ek site, an execution site, was preserved to become a memorial for the victims of the genocide.

Repairing the sewage system was another priority. According to survivors, Phnom Penh was flooded in 1978. The valves used to move water to the Tonle Sap during the dry season had not been closed during the city evacuation of 1975. So, wet season after wet season, water and river alluvia went up into the pipes, clogging them completely and gradually solidifying. The Order of Malta was the first agency to step in and provide assistance using hydro-cuire devices to start removing the blockage from the pipes.

Cleanliness and waste management issues were such that staff from the municipality and all ministries was called up every Saturday and Sunday to clean up the city with tractors and trailers.

There was also no drinking water system. Of the three water treatment plants, only the one at Phum Prek (near the Faculty of Medicine) was still operational, but with only one pump motor instead of six. With help from Vietnam and the USSR, we got part of this distribution system up and running.

Electricity is still a major challenge for the municipality because the three power generating plants were abandoned.

When the country was liberated on January 7, 1979 by the National Solidarity Front for the Rescue of Cambodia with the support and backing of Vietnamese troops, we never lost hope despite the enormous problems we faced. Our dream was to see Phnom Penh renovated and as beautiful as it used to be. We achieved it. The strategies and action plans implemented by the government during the harshest period did much to that end.

1. The KPRP is the Kampuchean People's Revolutionary Party, which began ruling in January 1979. It later became the Cambodian People's Party (CPP).

អនុវត្ត និងចាត់ចែងការកសាងឡើងវិញក្រោយសម័យខ្មែរក្រហម

ដូច្នេះសក្តានុពលសេដ្ឋកិច្ច និងជីវិតសង្គមរបស់មនុស្សមួយចំនួន ផ្តល់ផលប្រយោជន៍ដល់មនុស្សមួយចំនួនទៀត ហើយទីក្រុងជំងឺគួរជាទីគាប់ចិត្តមួយក្នុងការរស់នៅ អាចសាងសង់ឡើង ដែលមនុស្សគ្រប់រូបទទួលបានអត្ថប្រយោជន៍ ពីការសាងសង់នេះ។

ដោយ ឯកឧត្តម ចោង ខុន

នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ពោលគឺនៅចន្លោះឆ្នាំធ្វើរដ្ឋប្រហារ និងឆ្នាំពួកខ្មែរក្រហមដណ្តើមអំណាចបាន ក្រុងភ្នំពេញបានផ្លាស់ប្តូរទាំងស្រុង។ ដោយសារតែមានការទម្លាក់គ្រាប់បែកនៅភាគខាងកើតនៃប្រទេស ជនភៀសខ្លួនបានសម្រុកចូលមក ហើយទីក្រុងភ្នំពេញកើនប្រជាជនពី៧០ម៉ឺននាក់ ទៅ២លាននាក់ក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។

ការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហមធ្វើឱ្យការកើនឡើងនៃចំនួនប្រជាជនដែលគ្មានការត្រួតពិនិត្យនេះ ត្រូវបានបញ្ឈប់ជាបន្ទាន់ ក្រោយមកភ្នំពេញក៏ស្ថិតក្នុងភាពទទេរស្អាត។ ប្រជាជនត្រូវបានបង្ខំឱ្យចាកចេញទៅជនបទ។ ដោយត្រូវបានចាត់ទុកដូចជាអ្នកទោស ប្រជាជនមួយចំនួនធំបានស្លាប់ដោយការអស់កម្លាំង និងភាពអត់ឃ្លាននៅនឹងកន្លែង ត្រូវពួកខ្មែរក្រមបង្ខំធ្វើស្រែចម្ការ និងមួយចំនួនទៀតត្រូវបានគេយកទៅសម្លាប់ចោល។ សម្រាប់អ្នកដែលនៅរស់ត្រឡប់មកវិញនៅឆ្នាំ១៩៧៩ ស្ថានភាពរបស់ពួកគេពិតជាពិបាក និងមិនប្រាកដប្រជាឡើយ។

បញ្ហាប្រឈមនៃការកសាងឡើងវិញ

តើយើងត្រូវធ្វើយ៉ាងណាដើម្បីចាត់ចែងការរដ្ឋាននៃការកសាងឡើងវិញដ៏ធំយ៉ាងនេះ ហើយទន្ទឹមនឹងនោះ ត្រូវគ្រប់គ្រងប្រជាពលរដ្ឋដែលសម្រុកចូលមកទីក្រុងភ្នំពេញវិញដូចស្រមោចនោះ? ជនភៀសខ្លួនមួយចំនួនធំដែលធ្វើដំណើរសំដៅមកទីក្រុងភ្នំពេញ គឺជាបញ្ហាមួយដ៏ធំ។ ក្តីបារម្ភទីមួយគឺត្រូវធ្វើយ៉ាងណា កំណត់ និងបែងចែកឱ្យច្បាស់រវាងប្រជាជនធម្មតា និងកងកម្លាំងខ្មែរក្រហមដែលបង្កប់ខ្លួននៅក្នុងចំណោមជនភៀសខ្លួន។ ជាឧទាហរណ៍ ដើម្បីសម្គាល់ទាហានបង្កប់ខ្លួនក្នុងចំណោមកងទ័ពនោះ ពេលថ្ងៃយើងកាន់កាំភ្លើង AK-47 ហើយពេលយប់យើងជំនួសដោយ M-16 វិញ។

ពន្លកដំបូងនៃការកសាងឡើងវិញ ការបង្កើតរដ្ឋបាលសាធារណៈ

នៅឆ្នាំ"សូន្យ"នោះ យើងមិនត្រឹមតែត្រូវកសាងទីក្រុងឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែគឺត្រូវកសាងប្រទេសទាំងមូលឡើងវិញ ដោយប្រើមធ្យោបាយតិចតួចបំផុត។ នៅខែកុម្ភៈ ឆ្នាំ១៩៧៩ ក្រុមការងារចំនួនពីរក្រុមត្រូវបានបង្កើតឡើង នោះគឺក្រុមទី១នៅប្រាំងចំរេះ តាមបណ្តោយផ្លូវជាតិលេខ៥ និងក្រុមទី២នៅបុរីផ្ទះ១០០ខ្នង តាមបណ្តោយផ្លូវជាតិលេខ៤។ បេសកម្មរបស់ក្រុមការងារទាំងពីរ គឺជ្រើសរើសបញ្ញវន្តដែលនៅរស់ អតីតមន្ត្រីរាជការនិងអតីតនិស្សិត។ ក្រុមទី១ដែលខ្ញុំជាសមាជិកដែរនោះ មានមនុស្ស២៥នាក់មកពីប៉ែកខាងជើងទីក្រុងភ្នំពេញ និង៧០នាក់មកពីខាងពាយ័ព្យ។ ការងារដំបូងរបស់យើងគឺបង្កើតសាលានយោបាយមជ្ឈឹម សម្រាប់បណ្តុះបណ្តាលមន្ត្រីជំនាន់ទីមួយ។ វគ្គទីមួយត្រូវបានបណ្តុះបណ្តាលដោយសម្តេចតេជោ ហ៊ុន សែន ឯកឧត្តម សាយ ភូថង និង ឯកឧត្តម អ៊ី យូន ។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះទៅ យើងបានបង្កើតក្រុមការងារផ្សេងគ្នា។ ការងារសំខាន់របស់ក្រុមនេះគឺជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិករដ្ឋបាល និងមន្ត្រី ដើម្បីគ្រប់គ្រងទីតាំងផ្សេងៗនៅទីក្រុងភ្នំពេញ។ ក្រុមដំបូងដែលមានសមាជិក៦០នាក់ ហើយខ្ញុំក៏ជាសមាជិកមួយរូបដែរនោះ បានចេញទៅទទួលការបណ្តុះបណ្តាលនៅវៀតណាម។ ពេលត្រឡប់មកវិញ ចំនួន៣២នាក់ដែលមានខ្ញុំដែរនោះ ត្រូវបានបញ្ជូនទៅធ្វើការនៅសាលាក្រុងភ្នំពេញ។ អ្នកផ្សេងទៀតត្រូវបានបែងចែកទៅតាមក្រសួងមន្ទីរនានាដែលទើបត្រូវបានបង្កើតថ្មី។

ម្យ៉ាងវិញទៀត សាលាក្រុងភ្នំពេញបានបង្កើតសាលានយោបាយ និងរដ្ឋបាលនៅតាមថ្នាក់មជ្ឈឹមនិងថ្នាក់ខេត្ត ដើម្បីបណ្តុះបណ្តាលមន្ត្រីក្នុងគ្រប់វិស័យ។ ភ្នំពេញត្រូវបានបែងចែកជាតំបន់មជ្ឈឹមចំនួន៤ និងឃុំចំនួន១២។ នៅឆ្នាំ១៩៨០ មុនការបោះឆ្នោត តំបន់នានាត្រូវបានបែងចែកជាសង្កាត់។នៅឆ្នាំ១៩៨៣ បន្ទាប់មកឆ្នាំ១៩៨៦ កំណែទម្រង់រដ្ឋបាលថ្មីចំនួនពីរបានអនុញ្ញាតឱ្យភ្នំពេញកាត់យកដីមួយផ្នែកពីខេត្តកណ្តាល។ ពេលនោះ ទីក្រុងក៏មានផ្ទៃដីកើនរហូតដល់៤០១គីឡូម៉ែត្រក្រឡា។ នៅចន្លោះឆ្នាំ១៩៧៩ និងឆ្នាំ១៩៨៣ ខ្ញុំត្រូវបានតែតាំងដោយគណបក្សប្រជាជនបដិវត្តន៍កម្ពុជា[1] ជាមន្ត្រីនិងប្រធានការិយាល័យបុគ្គលិក និងរៀបចំរដ្ឋបាលទីក្រុង ដោយមានមុខងារជាអ្នកជ្រើសរើសភ្នាក់ងារ ព្រមទាំងរៀបចំ និងកសាងរចនាសម្ព័ន្ធនៃនាយកដ្ឋានផ្សេងៗ។ ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៥ ខ្ញុំត្រូវបានតែងតាំងជាអភិបាលរងក្រុងភ្នំពេញ ទទួលបន្ទុកខាងសុខាភិបាល អប់រំ វប្បធម៌ និងសង្គមកិច្ច។

ការកសាងឡើងវិញនៅក្នុងភាពបន្ទាន់

ពីចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩០ មន្ត្រីប្រមាណជាមួយម៉ឺននាក់ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលឱ្យធ្វើការនៅសាលាក្រុងភ្នំពេញ។ ក្នុងរយៈពេលនោះ អាទិភាពនានា និងគោលដៅនៃការកសាងឡើងវិញ និងការអភិវឌ្ឍក្រុងភ្នំពេញត្រូវបានគ្រោងឡើងទាំងអស់ ដើម្បីប្រឈមមុខនឹងភាពបន្ទាន់។

ការការពារក្រុងភ្នំពេញ

អាទិភាពដំបូងគឺការពារទីក្រុងកុំឱ្យពួកខ្មែរក្រហមអាចវិលត្រឡប់មកវិញបាន។ ពួកខ្មែរក្រហមបានបាញ់គ្រាប់ផ្លោងមកលើទីក្រុងភ្នំពេញពីខាងព្រៀសាន ពីម្តុំមុខកំពូល និងពីខាងបស្ចិម នៅម្តុំសំរោងក្រោម។ នៅជុំវិញទីក្រុងភ្នំពេញ យើងត្រូវការពារឱ្យមានសុវត្ថិភាពដើម្បីទប់ទល់នឹងការវាយប្រហារលើឃ្លាំងស្តុកប្រេងឬស្សីកែវ និងព្រលានយន្តហោះពោធិ៍ចិនតុង។ និយាយឱ្យចំទៅ ពេលថ្ងៃ យើងធ្វើការបម្រើប្រជាពលរដ្ឋ ហើយពេលយប់ យើងកាន់កាំភ្លើងដើរល្បាតនៅក្នុងទីក្រុង។ យើងបណ្តុះបណ្តាល និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋតាមមូលដ្ឋានចូលរួមក្នុងការឃ្លាំមើល និងការពារទីក្រុង។ ម្យ៉ាងវិញទៀតយុវជន១២រូប ត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលឱ្យក្លាយជាមន្ត្រីប៉ូលីស។ក្នុងចំណោមពួកគេមាន ឯកឧត្តម នេត សាវឿន ដែលសព្វថ្ងៃកាន់តំណែងជានាយឧត្តមសេនីយ៍សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម ចុង លីម អគ្គស្នងការរងនគរបាលជាតិ។

ធានាផ្តល់សេវាវេជ្ជសាស្ត្រ និងការថែទាំ

នៅក្នុងដំណាក់កាលដំបូងនៃការកសាងឡើងវិញ សមត្ថភាពសុខាភិបាលពិតជានៅទន់ខ្សោយណាស់។ ជាឧទាហរណ៍ នៅឆ្នាំ១៩៨៣ យើងត្រូវប្រឈមមុខនឹងការរាតត្បាតនៃជម្ងឺឆ្លង និងជម្ងឺគ្រុនឈាម ដែលត្រូវបានដោះស្រាយដោយសារមានអន្តរាគមន៍ជំនួយពីសមាគមគ្រូពេទ្យមកពីក្រុងហូជីមិញ។

Face au Palais Royal, le perré du quai du Tonlé Sap écroulé, 1979.
Opposite the Royal Palace, riprap of the collapsed Tonlé Sap dock, 1979.
នៅទល់មុខរាជវាំង ប្រាំងបេតុងមាត់ទន្លេសាបបាក់ ឆ្នាំ១៩៧៩

© AKP

© AKP

Principal lieu d'approvisionnement, la foule se presse au Marché O'Russey, 1982.
Crowd hurrying to the O'Russey Market, the main supply centre, 1982.
ជាកន្លែងលក់ដូរធំជាងគេ មនុស្សម្នាប្រញាប់ប្រញាល់ចូលផ្សារអូឫស្សី ឆ្នាំ១៩៨២

ដើម្បីឆ្លើយតបទៅនឹងបញ្ហាសុខភាពសាធារណៈ មហាវិទ្យាល័យវេជ្ជសាស្ត្រត្រូវបានបើកទ្វារឡើងវិញនៅដើមឆ្នាំ១៩៨០ ក្រោមឈ្មោះ មហាវិទ្យាល័យវេជ្ជសាស្ត្រចំរុះ ឱសថសាស្ត្រ និងទន្តសាស្ត្រ។ អតីតនិសិត្សត្រូវបានអញ្ជើញឱ្យបន្តការសិក្សារបស់ពួកគេទៀត ដើម្បីបញ្ចប់ការបណ្តុះបណ្តាលរបស់ពួកគេ។ ចំណែកគ្រូបង្រៀនត្រូវបានជ្រើសរើសក្នុងចំណោមគ្រូពេទ្យ ឱសថការី និងទន្តពេទ្យ ដែលនៅរស់រានមានជីវិតប៉ុន្មាននាក់ និងក្រោមជំនួយពីក្រុមគ្រូពេទ្យវៀតណាម និងគ្រូពេទ្យបរទេសនិយាយភាសាបារាំងខ្លះ ដែលកំពុងបំពេញបេសកម្មនៅកម្ពុជា។ កាលនោះ ភ្នំពេញមានមន្ទីរពេទ្យចំនួន៨ មានគ្រែសរុប ២០០០គ្រែ គ្រប់គ្រងដោយក្រសួងសុខាភិបាលសាធារណៈ និងមានមន្ទីរពេទ្យចំនួន៣ផ្សេងទៀត មានគ្រែសរុប ៤០០គ្រែ មន្ទីរគិលានុបដ្ឋាយិកាចំនួន៩ និងមណ្ឌលសុខភាពចំនួន៧ នៅក្នុងខ័ណ្ឌនានាតាមជាយក្រុងដែលគ្រប់គ្រងដោយសាលាក្រុងភ្នំពេញ។ ម្យ៉ាងវិញទៀត មានមជ្ឈមណ្ឌលជាតិមាតានិងកុមារមួយ រីឯមជ្ឈមណ្ឌលក្រុងសម្រាប់សុខភាពមាតា និងទារក ក៏ដំណើរការដែរ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ខាងផ្នែកសុខាភិបាលសាធារណៈ ក្រសួងសុខាភិបាលបានសម្រេចបញ្ជូនអតីតគិលានុបដ្ឋាយិកា ឬឆ្មបឱ្យទៅទទួលការបណ្តុះបណ្តាលដើម្បីក្លាយជាវេជ្ជបណ្ឌិត។ វិទ្យុ ទូរទស្សន៍ និងការបិទផ្សាយនៅតាមទីកន្លែងផ្សេងៗ នៅក្នុងទីក្រុងត្រូវបានប្រើប្រាស់ដើម្បីធ្វើយុទ្ធនាការអនាម័យសាធារណៈ។ ពាក្យស្លោករបស់យើងគឺ "ហូបស្អាត រស់នៅស្អាត ផឹកស្អាត!"។ ការថែទាំកុមារក៏ជាអាទិភាពមួយដែរ។ មានកុមារកំព្រាជាច្រើនបានដើរអនាថានៅតាមថ្នល់។ សាលាក្រុងបានបង្កើត និងគ្រប់គ្រងមណ្ឌលកុមារកំព្រាចំនួន៣ គឺមណ្ឌលកុមារកំព្រាកុលាប១ កុលាប២ កុលាប៣ និងកុលាប៤ ដែលទទួលថែទាំជាពិសេសជនពិការ និងស្ត្រីលំបាកតោកយ៉ាកក្រោមការត្រួតពិនិត្យរបស់ក្រសួងសង្គមកិច្ច។

ការអប់រំ

ក្នុងរបបខ្មែរក្រហម ភាគច្រើននៃបញ្ញវន្ត រួមទាំងសាស្ត្រាចារ្យ និងគ្រូបង្រៀន សុទ្ធតែបានស្លាប់។ នៅក្នុងពេលដំបូងនៃការកសាងឡើងវិញ រដ្ឋាភិបាលបានពឹងផ្អែកទៅលើវិធីសាស្ត្រនៃការអប់រំបន្តគ្នា ដើម្បីកសាងធនធានខាងផ្នែកអប់រំឡើងវិញ។ ពាក្យស្លោកនៅពេលនោះគឺ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ"។

ការបើកឡើងវិញនូវពាណិជ្ជកម្មក្នុងស្រុក

ការបើកឡើងវិញនូវសកម្មភាពសេដ្ឋកិច្ចគឺជាអាទិភាពចំបងមួយទៀត។ របបខ្មែរក្រហមបានបំបាត់ចោលទាំងស្រុងនូវវិស័យសេដ្ឋកិច្ចជាតិ និងមូលដ្ឋាន។ នៅទីក្រុងភ្នំពេញ ដើមដូងត្រូវបានដាំនៅជុំវិញផ្សារថ្មីដោយពួកខ្មែរក្រហម។ នៅឆ្នាំ១៩៨៣ សាលាក្រុងបានដកដើមដូងទាំងនោះយកទៅដាំនៅបរិវេណមន្ទីរពេទ្យកុមារ។ ពេលនោះ យើងពិតជាភ្ញាក់ផ្អើលខ្លាំងណាស់ដោយឃើញឆ្អឹងមនុស្សនៅខាងក្រោមឫសដូង។ មកដល់ឆ្នាំ១៩៨៤ ទើបតូបនៅក្នុងផ្សារបើកទ្វារលក់ដូរឡើងវិញ។

លំនៅដ្ឋាន និងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធក្រុង

បន្ទាប់ពីថ្ងៃ៧ មករា ១៩៧៩ រដ្ឋាភិបាលបានអនុញ្ញាតឱ្យប្រជាជនត្រឡប់ចូលក្នុងទីក្រុងវិញ និងរស់នៅតាមផ្ទះនានា។ អសុវត្ថិភាពដែលនៅតែមាននៅឡើយនោះ ធ្វើឱ្យមនុស្សម្នានៅតែមានការភ័យខ្លាច។ ពួកគេស្វែងរកកន្លែងដែលមានសុវត្ថិភាព ដោយនៅជិតៗគ្រួសារផ្សេងទៀត និងនៅជិតកងទ័ពវៀតណាម និងកងទ័ពកម្ពុជា។ ការរស់នៅជិតៗគ្នានាពេលដំបូងនោះបានបង្កជាផលលំបាកលើរបៀបនៃការរស់នៅក្នុងទីក្រុង រហូតមកដល់បច្ចុប្បន្ននេះទៀតសោត ក៏នៅតែជាបញ្ហាដូចគ្នាដែរ។

បន្ទាប់ពីឆ្នាំ១៩៧៩ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញមិនមែនដូចប្រជាជនមុនឆ្នាំ១៩៧៥នោះទេ។ អតីតប្រជាជនរស់នៅក្នុងទីក្រុង តែ៣០% ប៉ុណ្ណោះ ដែលអាចត្រឡប់មកវិញបាន ហើយ៧០%ទៀតគឺជាប្រជាជនថ្មីដែលមានកំណើតមកពីខេត្តផ្សេងៗ។ នៅពេលនោះ ប្រជាពលរដ្ឋចូលទៅរស់នៅតាមផ្ទះដែលនៅទំនេរ ប៉ុន្តែបញ្ហាថែរទាំ អនាម័យ ក៏ចាប់ផ្តើមលេចចេញឡើងយ៉ាងលឿន។ អគារខ្លះដែលពួកខ្មែរក្រហមបានយកទៅប្រើប្រាស់របៀបផ្សេងត្រូវបានជួសជុលកែលម្អថ្មី។ អគារខ្លះត្រូវបានយកមកប្រើប្រាស់ដូចពីមុន ប៉ុន្តែអគារខ្លះទៀតក៏មានមុខងារថ្មីដែរ។ ឧទាហរណ៍ ដូចជាករណីអគារបណ្ណាល័យជាតិ ដែលពួកខ្មែរក្រហមបានយកទៅធ្វើជារោងបាយមជ្ឈឹម បានបើកទ្វារឡើងវិញជាបណ្ណាល័យជាតិដដែល បន្ទាប់ពីឆ្នាំ១៩៧៩។ ឬក៏ឧទាហរណ៍មួយទៀតគឺសាលាមធ្យមសិក្សាចៅពញាយ៉ាត ឬហៅថាសាលាទួលស្វាយព្រៃ ដែលពួកខ្មែរក្រហមបានប្រែក្លាយឱ្យទៅជាមជ្ឈមណ្ឌលធ្វើទារុណកម្ម និងមន្ទីរឃុំឃាំង ក្រោយឆ្នាំ១៩៧៩ ក៏បានក្លាយជាសារមន្ទីរជាតិប្រល័យពូជសាសន៍។ រមណីយដ្ឋានជើងឯកដែលជាទីតាំងសម្លាប់រង្គាលត្រូវបានអភិរក្សទុកដដែលធ្វើជាទីតាំងនៃស្មារតីចងចាំប្រល័យពូជសាសន៍។

ការជួសជុលកែលម្អប្រព័ន្ធលូក៏ជាផ្នែកមួយនៃអាទិភាពដែរ។ យោងតាមការរៀបរាប់ដោយអ្នកនៅរស់ ភ្នំពេញបានលិចទឹកជំនន់នៅរដូវទឹកឡើងឆ្នាំ១៩៧៨។ នៅពេលដែលគេជម្លៀសប្រជាជនចេញនៅឆ្នាំ១៩៧៥ គេមិនបានបិទទ្វារទឹកដែលបញ្ចេញទឹកទៅក្នុងទន្លេរសាបនៅរដូវប្រាំងទេ។ ហេតុដូច្នេះហើយ នៅរៀងរាល់រដូវវស្សាទឹក និងដីល្បាប់ដែលហូរពីទន្លេសាបមកគឺហូរចូលក្នុងលូ ហើយបន្តិចម្តងៗ ដីល្បាប់នោះក៏ស្ងួតរឹង ធ្វើឱ្យលូស្ទះ។ គឺសមាគមមនុស្សធម៌កាតូលិក ដែលផ្តល់ជំនួយដំបូង មានម៉ាស៊ីនបូមលូ ហើយយើងក៏អាចចាប់ផ្តើមបូមកុំឱ្យលូស្ទះទៀត។

ទីក្រុងជួបបញ្ហាអនាម័យ និងបញ្ហាកកស្ទះសម្រាមច្រើនពេកទៅ រហូតដល់មន្ត្រីសាលាក្រុង និងមន្ត្រីគ្រប់ក្រសួងមន្ទីរ ត្រូវបានចាត់តាំងរៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ឱ្យទៅបោសសំអាតក្រុង ដោយប្រើត្រាក់ទ័រ និងរ៉ឺម៉ក។ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក៏គ្មានដែរនៅពេលនោះ។ ក្នុងចំណោមស្ថានីយផលិតទឹកស្អាតចំនួនបី មានតែស្ថានីយនៅភូមិព្រែក ជិតមហាវិទ្យាល័យវេជ្ជសាស្ត្រប៉ុណ្ណោះ ដែលនៅដំណើរការបាន ប៉ុន្តែស្ថានីយនោះអាចប្រើម៉ាស៊ីនបូមទឹកតែ១ប៉ុណ្ណោះ ក្នុងចំណោមម៉ាស៊ីនទាំងអស់ចំនួន៦។ ដោយទទួលបានជំនួយពីវៀតណាម និងពីសូវៀតយើងបានធ្វើឱ្យមួយផ្នែកនៃប្រព័ន្ធចែកចាយទឹកនេះដំណើរការឡើងវិញ។ ចំណែកឯអគ្គិសនី ក៏នៅតែជាបញ្ហាប្រឈមធំមួយសម្រាប់ទីក្រុងភ្នំពេញ ដោយសារតែការបោះបង់ចោលនូវរោងចក្រផលិតអគ្គិសនីចំនួន៣កន្លែង។

បន្ទាប់ពីប្រទេសត្រូវបានរំដោះនៅថ្ងៃ៧ មករា ១៩៧៩ ដោយរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងមានការជួយជ្រោមជ្រែង និងគាំទ្រពីក្រុមកងទ័ពវៀតណាម យើងមិនដែលអស់សង្ឃឹមនោះឡើយ ទោះបីជាយើងត្រូវប្រឈមនឹងបញ្ហាជាច្រើនក៏ដោយ។ ក្តីស្រមៃរបស់យើង គឺយើងចង់ឃើញភ្នំពេញត្រូវបានស្តារនិងកែលម្អឱ្យបានស្អាតឡើងវិញដូចពីមុន។ យើងធ្វើបានសម្រេចហើយ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលដាក់ចេញដោយរដ្ឋាភិបាលនៅក្នុងសម័យដ៏លំបាកបំផុតនោះ បានចូលរួមយ៉ាងច្រើនដល់ជោគជ័យនេះ។

© AKP

Un marché peu après sa réouverture, 1982.

A market shortly after its reopening, 1982.

ផ្សារមួយកន្លែង ក្រោយពីបើកលក់ដូរឡើងវិញបានបន្តិច ឆ្នាំ១៩៨២

Agir dans l'urgence, remettre la ville en marche

Les premiers temps de la reconstruction de Phnom Penh ont été des moments clés de la reconstruction urbaine. En témoigner, c'est permettre aux générations futures de mieux comprendre le chemin parcouru et les nombreuses difficultés auxquelles nous avons dû faire face.

PAR S.E. MOK MARETH

Le 7 Janvier 1979, à l'entrée des troupes de libération dans la capitale cambodgienne, Phnom Penh, jonchée d'immondices et de cadavres, est une ville fantôme. Seulement 60 habitants environ y sont recensés. La première tâche consiste à incinérer les morts. Les services publics n'existent plus. Les égouts sont bouchés. Les mots manquent pour décrire les épreuves des jours suivants. La nourriture est très rare. La ville que le peuple avait connue avant 1970 n'est plus la même. Beaucoup d'habitations ont été brûlées ou dégradées. Le souvenir des temps d'avant s'estompe. C'est un grand choc et un vrai traumatisme qu'il nous a fallu surmonter. Au quotidien, le temps est à la survie avec, en prime, la peur : la peur de la reprise de la guerre et de la proximité des Khmers rouges qui continuent leurs exactions. C'est ainsi que nous sommes allés couper la forêt autour de la ville pour qu'elle ne leur serve pas de refuge. Nous devions anticiper et nous défendre contre les embuscades menées par les Khmers rouges, tapis le long des trajets que nous empruntions. J'étais responsable adjoint des opérations Kor-5[1] et Kor-6[2] contre la résistance khmère rouge dans la ville de Phnom Penh. Sur le front du Kor-5, je menais un convoi qui acheminait du ravitaillement alimentaire et des fournitures médicales aux civils, mais aussi aux soldats et aux volontaires de l'armée vietnamienne qui étaient déployés sur le front à Takor, ainsi que dans les montagnes de Melai et de Phnom Proek. Kor-6 désignait la ligne de front qui entourait la ville de Phnom Penh. Ma mission était d'emmener les fonctionnaires et les civils dans les campagnes pour débroussailler les zones boisées et les maquis inondés de Mok Kampoul pour empêcher les rebelles Khmers rouges de prendre position dans ces lieux et de bombarder Phnom Penh avec leur artillerie.

L'État reconstruit alors, à partir de zéro, les services et les institutions publiques aux niveaux national, provincial et municipal. Ainsi, Phnom Penh est administrativement divisé en *sangkat* (communes) et *phum* (villages). Des services publics y sont créés dès 1979. Sous la conduite de *Samdech* Heng Samrin, président du Conseil d'État de la République populaire du Kampuchéa, je suis nommé adjoint du Comité révolutionnaire du peuple de la ville de Phnom Penh avec pour mission de gérer les opérations sur l'ensemble de la cité.

Les défis sont immenses et la ville doit faire face à une multitude d'urgences.

1-LES PÉNURIES ALIMENTAIRES :

Dès les premiers temps de la reconstruction, nous devons faire face à une sévère disette de riz. Les cadres mangent en général du riz cuit avec des céréales (maïs, manioc ou autres). On ne trouve pas de légumes ou de viande, ni aucun autre produit alimentaire. Afin de suppléer au manque de nourriture, nous organisons régulièrement des pêches au filet dans le Lac Tonlé Sap[3] avec le Directeur du Département de l'Agriculture, mon camarade Mann Choeun[4]. Les filets sont fournis par le gouvernement grâce au camarade Taing Sarim, alors ministre de l'Économie et des sources de revenus. Les employés du service nous accompagnent, ainsi que le responsable du *sangkat*, Mr. Chraing Chamreh, qui gére l'équipe de pêcheurs composée en majorité de Chams[5]. Ainsi, en 1979, nous avons pêché énormément de poissons pour les distribuer, d'abord aux cadres des ministères et des services, puis aux habitants de Phnom Penh et des provinces. La transformation des poissons frais en pâte de poisson (*Prahok*) ou en huile (*pha'ok*) permet leur conservation.

En 1979, nous ne comptons que sur nos propres forces car nous ne recevions aucune aide humanitaire extérieure.

Peu à peu, la population de Phnom Penh a augmenté pour atteindre 500 000 habitants en 1988, et ceci malgré une distribution alimentaire toujours difficile. Je suis aussi chargé de voyager dans les provinces pour acheter des denrées alimentaires (riz, haricots, maïs, porc et bœuf) afin d'approvisionner les marchés de la capitale. Tous les marchés existants sont remis en fonction : Psar Thmey, Psar Tuol Tom Pong, etc. On nomme des chefs de marchés, les stands sont alloués aux employés des ministères et aux fonctionnaires. Beaucoup de femmes de fonctionnaires sont ainsi devenues commerçantes.

Nous n'étions guidés par aucun schéma directeur. Des denrées de première nécessité, notamment importées, n'étaient accessibles qu'à ceux qui en avaient les moyens.

© Fonds Khieu Kanharith

Phnom penh vide en janvier 1979.

Phnom Penh empty in January, 1979.

ទីក្រុងភ្នំពេញទទេស្អាត ខែមករា ឆ្នាំ១៩៧៩

2-GESTION FINANCIÈRE, BANQUE, COMMERCE, INDUSTRIE, CONSTRUCTION ET URBANISATION :

La monnaie, le *riel*, est réintroduite le premier octobre 1979, mais ce n'est qu'à partir de 1990 que le gouvernement retrouve les moyens d'imprimer lui-même des billets. Au cours de la première moitié des années 1980, le ministère de l'Industrie gère un nombre croissant d'activités artisanales et industrielles, notamment la fabrication des groupes électrogènes, la création d'usines de cigarettes, la production d'alcool ou encore de pneus. Il existe à la municipalité de Phnom Penh un service de l'industrie et de l'artisanat qui donne les orientations pour aider à la croissance de ces entreprises d'État. Celles-ci fabriquent les produits de première nécessité tels que des marmites en aluminium en recyclant du métal, du riz séché pour pourvoir au ravitaillement des soldats sur le front, de la sauce soja, des bicyclettes, ou encore des pneus de vélo. En 1984, ce secteur artisanal a été privatisé. À partir de la fin des années 1980, les produits sont de meilleure qualité et deviennent plus compétitifs sur le marché régional.

Le gouvernement lance alors une campagne appelée « le cultivé enseigne le non-cultivé ».

L'attribution de logements aux fonctionnaires, aux travailleurs, aux membres des forces armées et à la population en général représente un autre défi. L'État, par l'intermédiaire de son service de l'urbanisme et de la construction, attribue les maisons vides aux cadres, aux officiels du gouvernement, quels que soient leurs échelons, ainsi qu'aux membres des forces armées et aux civils qui étaient venus s'installer à Phnom Penh dans les premiers temps.

3- LES RÉGIES, LA GESTION DES RÉSEAUX D'ÉGOUTS ET DES ORDURES

En 1979, l'approvisionnement en eau potable et en électricité est pratiquement inexistant. La municipalité remet rapidement en marche une usine de traitement d'eau potable. Cependant la qualité de l'eau est mauvaise car les canalisations d'eau sont très endommagées. La Régie des eaux entreprend, au début des années 1990, de vastes efforts pour les réparer afin d'approvisionner progressivement tous les habitants en eau potable. Le ministère de l'Industrie est responsable de la restauration du réseau électrique, même si sa capacité reste très faible. Il faut noter que l'anarchie des raccordements illégaux rend la tâche plus ardue. Pour remettre de l'ordre, le gouvernement met sur pied un comité responsable de l'éradication de ces pratiques. Je suis nommé président de ce comité et nous avons ainsi travaillé à l'élimination les raccordements électriques illégaux.

Le réseau des égouts est bouché et exige des travaux de rénovation à grande échelle. Je me souviens encore de l'aide apportée par le gouvernement français et la Ville de Paris, qui nous ont fourni deux véhicules, des hydrocureuses, pour déboucher les égouts, ainsi que des bennes à ordures. La Coopération Internationale pour le Développement et la Solidarité (CIDSE) a aussi apporté une assistance précieuse.

4-ÉDUCATION, CULTURE, SANTÉ ET AFFAIRES SOCIALES :
À partir de 1985, le poste de président adjoint du Comité du peuple de Phnom Penh responsable de l'éducation de la culture et des affaires sociales m'est également confié. Avec mon équipe, nous nous attelons à remettre en route le système éducatif dans tout le pays en utilisant les écoles qui étaient encore debout. Le gouvernement lance alors une campagne appelée « le cultivé enseigne le non-cultivé » où tous ceux qui avaient un minimum d'éducation rejoignent le maigre corps des enseignants et des professeurs survivants afin d'enseigner aux personnes non éduquées.
Le ministère de la Culture, quant à lui, insuffla un nouvel élan à la culture. Les artefacts et les biens culturels ont été récupérés et transférés au ministère de la Culture pour les mettre en sécurité. Des troupes artistiques et des groupes de musique ont été créés grâce à l'action de la municipalité.
Notre équipe œuvre aussi dans le secteur de la santé. Plusieurs bâtiments sont réquisitionnés pour être transformés en centres de soins et en maternités. Pendant une courte période, nous avons bénéficié du soutien de médecins vietnamiens volontaires qui nous assistent pour les soins généraux et les opérations chirurgicales.

5. LES AFFAIRES SOCIALES :
Les premières tâches du service des affaires sociales de la ville de Phnom Penh consistent, à partir de ??? à fournir une assistance aux sans-logis et à rapatrier, dans leurs provinces d'origines, des pilleurs venus en ville pour voler. L'administration municipale crée également un centre éducatif à Koh Kor, dans la province de Kandal, pour les femmes seules.
Toutes les personnes de cette génération qui ont vécu ces événements et qui ont réussi à survivre jusqu'à nos jours réalisent pleinement la chance qu'elles ont d'être toujours en vie.

1. Le plan Kor 5 a pour mission de protéger la ligne de front sur la frontière Thaïlandaise)
2. Le plan Kor 6 a pour mission de protéger la ligne de front autour de la ville de Phnom Penh
3. y compris la pèche au Day, Manh, Senne etc.
4. S.E. Mann Choeun est actuellement sénateur.
5. Les Chams ou « Khmer islam » sont majoritairement des populations musulmanes dont les ancêtres ont fui le Royaume du Champa au moment de son absorption par les Vietnamiens entre le XVIe et le XIXe siècle. Il faut aussi compter parmi eux des groupes originaires de l'archipel indonésien et de Malaisie.

Le boulevard Preah Monivong en 1982.
Boulevard Preah Monivong in 1982.
មហាវិថព្រះមុនីវង្សនៅឆ្នាំ១៩៨២

© AKP

Emergency Action: Getting the City Going Again

The early days of the reconstruction of Phnom Penh were key moments in the urban reconstruction process. Telling the story is a way to help future generations understand how far we have come and the many difficulties we faced. **BY H.E. MOK MARETH**

On January 7, 1979, when the liberation forces entered the Cambodian capital, Phnom Penh was a ghost city, strewn with refuse and corpses. There were no more than about 60 people living there. The first task was to incinerate the bodies. There were no public services. The sewers were blocked. There are no words to describe the challenges of the days that followed. There was very little food. The city that people had known before 1970 had gone. Many houses had been burnt or damaged. Little was left of earlier times. We had to overcome feelings of terrible shock and real trauma. The day-to-day priority was survival, against a backdrop of fear: fear of further war and of the nearby Khmer Rouge, whose atrocities continued. That is why we cut down the forest around the city, so that they could not hide in it. We had to anticipate and protect ourselves against ambushes perpetrated by the Khmer Rouge, who were concealed along the routes we took. I was second-in-command of the Kor-5[1] and Kor-6[2] operations against the Khmer Rouge in the city of Phnom Penh. On the Kor-5 front, I led a convoy that was carrying food and medical supplies to civilians, but also to the soldiers and volunteers of the Vietnamese army, who were deployed on the front at Takor, as well as in the mountains of Melai and Phnom Proek. Kor-6 was the name of the frontline that surrounded the city of Phnom Penh. My mission was to transport public servants and civilians into the countryside to clearly the wooded areas and flooded scrubland of Mokshelling Kampoul, to prevent the Khmer Rouge rebels occupying these places and shelling Phnom Penh with their artillery.
From nothing, the state began to rebuild public services and institutions at the national, provincial and municipal levels. Phnom Penh was divided administratively into *sangkat* (municipalities) and *phum* (villages). Public services were created in 1979. Under the leadership of *Samdech* Heng Samrin, President of the Council of State of the People's Republic of Kampuchea, I was appointed deputy head of the People's Revolutionary Committee for the city of Phnom Penh, with the task of managing operations across the whole city.
The challenges were huge, and the city faced a mass of urgent problems.

1- FOOD SHORTAGES:
From the early days of reconstruction, we suffered from a serious shortage of rice. The *cadres* generally ate cooked rice with cereals (maize, manioc, etc.). There were no vegetables or meat, or any other edible produce. To make up for the lack of food, along with the Director of the Department of Agriculture, my friend Mann Choeun,[3] we organised regular net fishing in Lake Tonlé Sap. The nets were supplied by the government through the good offices of Comrade Taing Sarim, who was then Minister of the Economy and of Revenue Sources. We were accompanied by staff from the Department, together with the head of the sangkat, Mr. Chraing Chamreh, who managed the fishing team, which consisted largely of Chams.[4] In 1979, we caught huge numbers of fish, which were distributed first to the cadres of the ministries and departments, then to the inhabitants of Phnom Penh and the provinces. The fresh fish were processed to make fish paste (*Prahok*) or oil (*pha'ok*), so that it could be stored. In 1979, we had to rely entirely on ourselves, since we were receiving no outside humanitarian aid.
The population of Phnom Penh gradually increased, reaching 500,000 in 1988, despite continuing food supply problems. I was also given the task of travelling to the provinces to buy produce (rice, beans, maize, pork and beef) to supply the capital's markets. All the former markets – like Psar Thmey, Psar Tuol Tom Pong, etc. – were reactivated. People were appointed to head the markets, and stalls were allocated to ministry employees and civil servants. As a result, the wives of many civil servants became shopkeepers.
We had no overarching master plan. Essential foodstuffs, particularly imported goods, were only available for those with the necessary resources.

© Fonds Khieu Kanharith

Nettoyage de la ville en 1979. / Cleaning of the city in 1979. / ការបោសសម្អាតទីក្រុង ឆ្នាំ១៩៧៩

2. FINANCIAL MANAGEMENT, BANKING, TRADE, INDUSTRY, CONSTRUCTION AND URBANISATION:
The currency, the riel, was reintroduced on October 1, 1979, but it was not until 1990 that the government regained the ability to print banknotes. In the first half of the 1980s, the Ministry of Industry oversaw a growing number of light and heavy industrial activities, in particular the manufacture of generators and of tyres, the creation of cigarette factories and the production of alcohol. Phnom Penh municipality had an industry and crafts department which provided guidelines to help these state enterprises grow. They made essential products like aluminium saucepans, by recycling metal, dried rice to feed the soldiers at the front, soya sauce, bicycles, or bicycle tyres. In 1984, this light industry sector was privatised. By the end of the 1980s, the quality of the products had improved and they had become more competitive on the regional market.
The allocation of housing to civil servants, to workers, to members of the armed forces and to the population in general was another challenge. The state, through its urban planning and construction department, allocated empty houses to the cadres, to government officials of all levels, and to members of the armed forces and civilians who came to settle in Phnom Penh in the early days.

3. UTILITIES: THE SEWAGE AND WASTE SYSTEMS
In 1979, there was practically no drinking water and no electricity supply. Though the municipality quickly recommissioned a water treatment plant, the quality of the drinking water was poor, because the water pipes were extensively damaged. In the early 1990s, the water authority undertook a major repair programme, with the aim of gradually bringing drinking water to everyone in the city. The Industry Ministry was responsible for restoring the power grid, although its capacity remained very low. The anarchy of illegal hookups made the task harder, so to restore order, the government set up a committee to eradicate these practices. I was appointed chairman of that committee, and we worked to eliminate illegal electricity connections.
The sewage network was blocked and needed large-scale renovation. I still remember the assistance provided by the French government and the City of Paris, which supplied us with two sewage-flusher vehicles to unblock the sewers, as well as garbage trucks. Coopération Internationale pour le Développement et la Solidarité (CIDSE – international cooperation for development and solidarity) also provided valuable help.

4. EDUCATION, CULTURE, HEALTH AND SOCIAL AFFAIRS
From 1985 onwards, I also held the position of deputy chairman of the Phnom Penh People's Committee for education, culture and social affairs. With my team, we worked to get the educational system up and running across the whole country, using the schools that were still standing. The government then launched a campaign called "the educated teach the uneducated", in which anyone who had a modicum of education joined the small band of surviving teachers and professors to teach people without education.
The Ministry of Culture, for its part, gave new impetus to national culture. Cultural artefacts and goods were recovered and transferred to the Ministry of Culture for safekeeping. Troupes of artists and musicians were created on the initiative of the municipality.
Our team also worked in the health sector. Several buildings were requisitioned and converted into health and maternity centres. For a short period, we received support from volunteer doctors from Vietnam, who helped us with general care and surgical operations.

6. SOCIAL AFFAIRS:
The first task of the city of Phnom Penh's Social Affairs Department, from 1980 onwards, was to provide support for the homeless and to send looters who came to the city to steal back to their home provinces. The municipal administration also created an educational centre in Koh Kor, in Kandal province, for lone women.
All the people of that generation who lived through those events and have succeeded in surviving until today know full well how lucky they are to still be alive.

1. The purpose of the Kor 5 plan was to protect the frontline on the Thai border.
2. The purpose of the Kor 6 plan was to protect the frontline around the city of Phnom Penh.
3. H.E. Mann Choeun is now a senator.
4. The Chams or "Khmer Islam" are mostly Muslim populations whose ancestors fled the Kingdom of Champa at the time of its absorption by the Vietnamese between the 16th and 17th centuries. They also include groups that originated from the Indonesian Archipelago and from Malaysia.

© AKP

Un des débarcadères de Phnom Penh qui assure les liaisons avec les provinces, 1982.

One of Phnom Penh's wharfs providing connections to the provinces, 1982.

កំពង់ដរមួយនៅទីក្រុងភ្នំពេញ ភ្ជាប់ចរាចរណ៍ទៅតាមខេត្តផ្សេងៗ ឆ្នាំ១៩៨២

ចាត់វិធានការក្នុងពេលបន្ទាន់ ធ្វើឱ្យទីក្រុងដំណើរការឡើងវិញ

ពេលដំបូងនៃការកសាងទីក្រុងភ្នំពេញឡើងវិញគឺជាពេលវេលាគន្លឹះនៅក្នុងការកសាងទីក្រុងឡើងវិញ។ ធ្វើជាសាក្សីផ្តល់សក្ខីកម្ម គឺអនុញ្ញាតឱ្យមនុស្សជំនាន់ក្រោយយល់ច្បាស់ជាងមុនពីផ្លូវដែលយើងបានដើរឆ្លងកន្លងមក និងយល់ពីការលំបាកជាច្រើនដែលយើងចាំបាច់ត្រូវប្រឈម និងដោះស្រាយ។

ដោយឯកឧត្តម ម៉ុក ម៉ារ៉េត

ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ ឬថ្ងៃដែលប្រជាជនខ្មែរយើងបានរស់ឡើងវិញ ទីក្រុងភ្នំពេញមានទិដ្ឋភាពប្រៀបដូចទីក្រុងខ្មោច ឬជាទីរហោស្ថាន។ ប្រជាជនដែលរស់នៅដំបូងបង្អស់មានប្រមាណ៦០នាក់ប៉ុណ្ណោះ។ កិច្ចការដំបូងដែលយើងត្រូវធ្វើ គឺបូជាខ្មោចទាំងអស់នោះ។ អត់មានសេវាសាធារណៈទៀតទេ។ លូបង្ហូរទឹកក៏ស្ទះគ្រប់ទីកន្លែង។ គ្មានពាក្យអ្វីអាចពិព័ណ៌នាបានពីទុក្ខលំបាកប្រចាំថ្ងៃរបស់អ្នកនៅរស់ឡើយ។ និយាយអំពីម្ហូបអាហារនោះគឺយើងពិតជាមានការខ្វះខាតខ្លាំងមែន។ ទីក្រុងដែលប្រជាជនធ្លាប់ស្គាល់មុនឆ្នាំ១៩៧០មិនដូចពីមុនទៀតទេ។ ផ្ទះសម្បែងជាច្រើនត្រូវបានភ្លើងឆេះ ឬខូចខាត។ អនុស្សាវរីយ៍កាលពីមុនបានរសាត់ទៅឆ្ងាយហើយ។ វាជារឿងខ្លោចផ្សារនិងគ្រាំគ្រាធ្ងន់ធ្ងរដែរយើងត្រូវជំនះឱ្យបាន។ រៀងរាល់ថ្ងៃយើងត្រូវត្រដរស់ទាំងក្នុងភាពភ័យខ្លាច គឺខ្លាចសង្គ្រាមត្រឡប់មកវិញ ហើយខ្មែរក្រហមនៅជិតៗយើងនៅឡើយ និងបន្តការកាប់សម្លាប់។ ហេតុដូច្នេះហើយបានជាយើងកាប់ព្រៃនៅជុំវិញក្រុងចោល ដើម្បីកុំឱ្យពួកខ្មែរក្រហមយកធ្វើជាជម្រក។ យើងត្រូវគិតទុកមុន ខ្លាចពួកខ្មែរក្រហមពួននៅតាមផ្លូវ វាយឆ្មក់។ ខ្ញុំជាអនុប្រធានគណកម្មការ ក៥[1] និង ក៦[2] ក្រុងភ្នំពេញ ប្រឆាំងនឹងការតស៊ូរបស់ខ្មែរក្រហមនៅក្រុងភ្នំពេញ។ ការបញ្ជូនពលករ កងទ័ព នគរបាល ទៅបំពេញកាតព្វកិច្ចការពារជាតិនៅសមរភូមិ ក៥ តំបន់តាគរ ភ្នំម៉ាលៃ ភ្នំព្រឹក ទាមទារឱ្យខ្ញុំដឹកនាំប្រតិភូដឹកនាំប្រតិភូរៀងរាល់ខែដឹកស្បៀង ថ្នាំពេទ្យ និងចុះជួបសួរសុខទុក្ខប្រជាពលករ កងទ័ពកម្ពុជា កងទ័ពស្ម័គ្រចិត្តវៀតណាមកងកម្លាំងនគរបាលរដ្ឋធានី។ ចំពោះសមរភូមិជុំវិញក្រុងភ្នំពេញ ខ្ញុំត្រូវបានទទួលបន្ទុកជាអនុប្រធាន ក៦ ដឹកនាំមន្ត្រីរដ្ឋការ និងប្រជាពលរដ្ឋកាប់ឆ្ការសំអាតព្រៃលិចទឹកមុខកំពូលទាំងមូល ការពារការបោះទីតាំងបាញ់ផ្លោងផ្តក់ដាក់ក្រុងភ្នំពេញពីសំណាក់ខ្មែរក្រហម។

រដ្ឋចាប់ផ្តើមកសាងក្បាលម៉ាស៊ីនរដ្ឋ ស្ថាប័នរដ្ឋាភិបាល ពីថ្នាក់ក្រុងដល់ខេត្ត ចាប់ពីចំណុចសូន្យ។ ទីក្រុងភ្នំពេញបែងចែកថ្នាក់គ្រប់គ្រងដល់សង្កាត់ និងភូមិនានា និងចាត់តាំងមន្ទីរជំនាញនានាក្នុងឆ្នាំ១៩៧៩។ស្ថិតក្រោមការដឹកនាំរបស់រដ្ឋាភិបាលដែលពេលនោះ សម្តេច ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ខ្ញុំបានត្រូវបានចាត់តាំងជាអនុប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៨០ ដើម្បីគ្រប់គ្រងប្រតិបត្តិការក្នុងទីក្រុងទាំងមូល។

បញ្ហាប្រឈមពិតជាច្រើនអនេក ហើយទីក្រុងត្រូវប្រឈមមុខនឹងបញ្ហាបន្ទាន់ជាច្រើន។

បញ្ហាធំៗដែលទីក្រុងភ្នំពេញត្រូវប្រឈម និងត្រូវដោះស្រាយមានដូចខាងក្រោម៖

១-បញ្ហាស្បៀង

យើងពិតជាមិនមានអង្ករហូបចុកគ្រប់គ្រាន់ទេ។ កម្មាភិបាលយើងច្រើនហូបបាយអង្ករលាយពោត លាយមី ឬដំឡូងមី ឬគ្រាប់ធញ្ញជាតិផ្សេងៗទៀត។ ត្រីសាច់បន្លែបង្ការក៏ខ្វះខាតផងដែរ។ តាំងពីចុងឆ្នាំ១៩៧៩ ខ្ញុំរួមជាមួយមន្ត្រីមន្ទីរកសិកម្មក្រុងភ្នំពេញដឹកនាំប្រជានេសាទចាប់ត្រីតាមដងទន្លេសាបដោយប្រើ ដាយ ម៉ាញ់ ឬបង់សំណាញ់ជាដើម។ ខ្ញុំទទួលបានសាច់អួននិងមងពីរដ្ឋាភិបាលតាមរយៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងជីវភាព (លោក តាំង សារឹម) ដោយមិនគិតថ្លៃ ដើម្បីចែកជូនបងប្អូនអ្នកនេសាទ។ ខ្ញុំរួមជាមួយនឹងកម្មាភិបាលមន្ទីរកសិកម្មក្រុងភ្នំពេញ និងប្រធានសង្កាត់ច្រាំងចម្រេះដឹកនាំបងប្អូនអ្នកនេសាទដែលភាគច្រើនជាបងប្អូនខ្មែរអ៊ីស្លាមនៅច្រាំងចម្រេះ ដើម្បីចលនាបងប្អូនចាប់ផ្តើមនេសាទដោយប្រើឧបករណ៍ ដាយ មង ម៉ាញ់ និងអួន។ យើងចាប់បានត្រីច្រើនមែនទែននៅចុងឆ្នាំ១៩៧៩។ ត្រីដែលចាប់បានមិនគ្រាន់តែចែកជូនកម្មាភិបាលបុគ្គលិកតាមក្រសួងមន្ទីរនោះទេគឺ យើងបានចែកជូនប្រជាពលរដ្ឋក្នុងក្រុងភ្នំពេញក៏ដូចជាប្រជាពលរដ្ឋយើងដែលមកពីខេត្តដើម្បីទទួលយកត្រីធ្វើជាអាហារ ឬប្រហុកផ្អក។

ការងារចិញ្ចឹមត្រីមន្ទីរកសិកម្មបានស្តារស្រះត្រីជាច្រើន ផលិតនិងចែកកូនត្រីជូនបងប្អូនអ្នកចញ្ចឹមត្រីទូទាំងក្រុង។ ការងារដាំបន្លែនិងដំណាំ ក្រុងបានរៀបចំជាក្រុមសាមគ្គីបង្កបង្កើនផល ព្រោះប្រជាពលរដ្ឋមិនមានមធ្យោបាយផលិតកម្មគ្រប់គ្នាទេ។ អ្នកខ្លះមានគោ អ្នកខ្លះមាននង្គ័លជាដើម ទាមទារឱ្យបងប្អូនរួមគ្នាបង្កបង្កើនផលនិងចែកផលរួម។ ឆ្នាំ១៩៧៩ ជាឆ្នាំដែលយើងមិនដែលបានទទួលអង្ករ ឬស្រូវសាលីពីអង្គការមនុស្សធម៌ឡើយ។

ឆ្នាំបន្តបន្ទាប់ ប្រជាពលរដ្ឋចាប់ចូលមករស់នៅកើនឡើងរហូតដល់ឆ្នាំ១៩៨៨ ប្រមាណ៥០ម៉ឺននាក់។ ក្រុងភ្នំពេញចាប់ផ្តើមខ្វះស្បៀងនិងសាច់។ ខ្ញុំចាំបាច់ធ្វើដំណើរតាមខេត្តសំខាន់ៗដើម្បីប្រមូលទិញអង្ករ សណ្តែក ពោត ជ្រូក គោ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងក្រុង។ ការធ្វើដំណើរត្រូវឆ្លងកាត់ការបាញ់ស្ទាត់តាមដងផ្លូវពីពួកឧទ្ទាមទ័ពព្រៃ។ តែអស្ចារ្យណាស់ជីវិតខ្ញុំពិតជាថ្លៃអាចរស់មកដល់សព្វថ្ងៃនេះ។

២-ការគ្រប់គ្រងហិរញ្ញវត្ថុ ធនាគារពាណិជ្ជកម្ម ឧស្សាហកម្ម សំណង់ នគរូបនីយកម្ម

យើងមានប្រាក់រៀលចាយពីថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ គឺកាលពី៤០ឆ្នាំមុន។ នៅទស្សវត្សរ៍៩០ ទើបរដ្ឋបានបោះពុម្ពក្រដាសប្រាក់រៀលដោយខ្លួនឯង។ វិស័យសិប្បកម្មត្រូវបានគ្រប់គ្រងជាលក្ខណៈឯកជនក្នុងឆ្នាំ១៩៨៤ បានធ្វើឱ្យវិស័យនេះចម្រើនជានាបានផលិតផលមានគុណភាពប្រកួតតម្លៃទីផ្សារតំបន់បាន។ ការចែកផ្ទះជូនកម្មាភិបាលបុគ្គលិកកម្មករ និងប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធជាការងារលំបាកមួយទៀត។

វិស័យកសិកម្ម ឧស្សាហកម្ម ក្រសួងឧស្សាហកម្មបានដាក់ឱ្យដំណើរការ រោងចក្រមួយចំនួនដែលអាចដំណើរការបានមានរោងចក្រអគ្គិសនី រោងចក្រ បារី ស្រា សំបកកង់រថយន្ត សំបកកង់ជិះជាដើម។ នៅក្នុងក្រុងភ្នំពេញយើងមានមន្ទីរឧស្សាហកម្ម សិប្បកម្មដឹកនាំការកសាងវិស័យសិប្បកម្មសមូហភាព។ យើងមានសិប្បកម្មធ្វើឆ្នាំងបាយ ខ្ទះពីសំណល់លោហធាតុចាស់ៗ សិប្បកម្មផលិត មី ឬបាយសម្ងួត បំរើឱ្យកង ទ័ពសមរភូមិមុខ សិប្បកម្មផលិតស៊ីអ៊ីវ សៀង និងសិប្បកម្មផលិតសំបកកង់ជិះ។ល។ វិស័យសិប្បកម្មត្រូវបានធ្វើឯកជននីយកម្មក្នុងឆ្នាំ១៩៨៤ បានធ្វើឱ្យវិស័យនេះ រីកចម្រើនជានាបានផលិតផលគុណភាពប្រកួតប្រជែងទីផ្សារតំបន់បាន។ ក្រោមការគ្រប់គ្រងរបស់មន្ទីររៀបចំដែនដី និងគ្រប់គ្រងរបស់មន្ទីររៀបចំដែនដីនិងគ្រប់គ្រងសំណង់រដ្ឋបានបែងចែកផ្ទះសម្បែងជូនកម្មាភិបាល មន្ត្រីរដ្ឋការគ្រប់ជាន់ថ្នាក់រួមទាំងកងកម្លាំង ប្រដាប់អាវុធ និងប្រជាពលរដ្ឋដែលត្រឡប់មករស់នៅក្នុងក្រុងភ្នំពេញ។

៣-អគ្គិសនី ទឹក ការគ្រប់គ្រងលូទឹក សំណល់សំរាម

បញ្ហាទឹកស្អាត អគ្គិសនី ពិតជាមានការខ្វះខាតដោយអន្លើ ក្រុងបានដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាត ឡើងវិញតែគុណភាពទឹកគ្មានអនាម័យដោយបណ្តាញទឹកខូចខាតដោយអន្លើ។ រដ្ឋាករទឹកក្រុងបានពុះពារជួសជុលប្រព័ន្ធទឹកស្អាត បានចែកចាយទឹកស្អាតប្រើប្រាស់ជាបន្តបន្ទាប់។ អគ្គិសនីកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ត្រូវបានស្តារឡើងវិញ។ តែការប្រើប្រាស់មិនបានគ្រប់គ្រាន់ទេ។ ភាពអាណាធិបតេយ្យក្នុងការប្រើប្រាស់អគ្គិសនី បានកើតឡើងដោយអន្លើ។ តែការប្រើប្រាស់មិនបានគ្រប់គ្រាន់ទេ។ ភាពអាណាធិបតេយ្យក្នុងការប្រើប្រាស់អគ្គិសនី បានកើតឡើងដោយអន្លើ។ រដ្ឋាភិបាលបង្កើតគណកម្មការបង្ក្រាបការប្រើប្រាស់អគ្គិសនីដោយភាពអាណាធិតេយ្យ ដោយបានចាត់តាំងរូបខ្ញុំជាប្រធាន បង្ក្រាបអាណាធិបតេយ្យក្នុងការប្រើប្រាស់អគ្គីសនីបានជោគជ័យរយៈពេល២ឆ្នាំ។ បណ្តាញលូទឹកស្ទះគ្រប់ទីកន្លែងដែលទាមទារការស្តារ និងជួសជុលឡើងវិញ។ យើងនៅចាំបានថា សាធារណរដ្ឋបារាំងបានជួយឧបត្ថមរថយន្តបូមលូទឹក២គ្រឿង និងដោយឡែក អង្គការ CIDSE របស់លោកស្រី Eva ក៏បានជួយជ្រោមជ្រែងការងារលូទឹកដែរ។

៤-វិស័យអប់រំ វប្បធម៌ សុខាភិបាល និងសង្គមកិច្ច

នៅពេលអវត្តមានសមអនុប្រធាន (ទទួលបន្ទុកអប់រំ វប្បធម៌ សង្គមកិច្ច) គណៈកម្មាធិការប្រជាជនទីក្រុងភ្នំពេញរាប់ឆ្នាំ ខ្ញុំត្រូវបានចាត់តាំងឱ្យទទួលបន្ទុកបន្ថែមវិស័យនេះ។ វិស័យអប់រំសិក្សាត្រូវបានរស់ឡើងវិញទូទាំងប្រទេស។ ប្រើប្រាស់អគារសិក្សាចាស់ៗដែលនៅសេសសល់ពីការបំផ្លិចបំផ្លាញក្នុងសង្គ្រាម និងរបបប្រល័យពូជសាសន៍ប៉ុលពត។ រដ្ឋបានអនុវត្តទ្រឹស្តី "អ្នកចេះបង្រៀនអ្នកមិនចេះ" រួមជាមួយលោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យដែលនៅរស់មួយចំនួនតូចសល់ពីការកាប់សម្លាប់ និងស្លាប់ដោយអត់អាហារក្នុងរបបខ្មែរក្រហម។

វិស័យវប្បធម៌ក៏ត្រូវបានស្តារឱ្យរស់ឡើងវិញ មន្ទីរវប្បធម៌ក្រោមការដឹកនាំខ្សែរបណ្តោយរបស់ក្រសួងវប្បធម៌ បានដាក់ឱ្យដំណើរការបានយ៉ាងសកម្ម។ យើងបានប្រមែប្រមូលវត្ថុបុរាណ សិល្បៈ មករក្សាទុកមុននឹងបញ្ជូនទៅក្រសួងវប្បធម៌រក្សាទុក។ យើងបានរៀបចំក្រុមសិល្បៈរដ្ឋធានី ក្រុមតន្ត្រីរដ្ឋធានី ។ល។

វិស័យសុខភិបាល មន្ទីរសុខាភិបាលរដ្ឋធានី បានរៀបចំឱ្យមានអគារសម្រាកព្យាបាល និងឆ្លងទន្លេ (លំហែរមាតុភាព) បានសមរម្យ ។ យើងមានការជួយឧបត្ថម្ភពីគ្រូពេទ្យស្ម័គ្រចិត្តវៀតណាមរយៈកាលខ្លីលើផ្នែកជម្ងឺទូទៅនិងវះកាត់ស្រាល។

៥-វិស័យសង្គមកិច្ច

ចាប់ពីឆ្នាំ១៩៨០មក មន្ទីរសង្គមកិច្ចរដ្ឋធានីបានដំណើរការដំបូងជួយសង្គ្រោះជនអនាថាអត់ទីពឹង ឬក៏បញ្ជូនបងប្អូនទៅជនបទ ចាញ់បោកឧបាយកលឃោសនារបស់ពួកអមិត្ររត់ចូលមកក្រុងភ្នំពេញយកជ័យភ័ណ្ឌជាដើម។ ក្រុងបានរៀបចំមណ្ឌលអប់រំស្ត្រីដែលអត់ទីពឹងមួយកន្លែងនៅកោះគរខេត្តកណ្តាល។ មនុស្សគ្រប់គ្នានៅជំនាន់នោះពិតជាមានសំណាងណាស់ដែលបាននៅរស់រហូតដល់សព្វថ្ងៃនេះ។

1. ផែនការក៥គឺមានបេសកកម្មការពារខ្សែបន្ទាត់សមរភូមិនៅតាមព្រំដែនថៃ។
2. ផែនការក៦គឺមានបេសកកម្មការពារខ្សែបន្ទាត់សមរភូមិនៅជុំវិញទីក្រុងភ្នំពេញ។

យើងឃើញមានរបៀបរស់នៅថ្មីក្នុងទីក្រុង។ សំណង់បុរីបានរីកច្រើនដូចផ្សិត។ នៅក្នុងបុរីតូចធំទាំងនេះ មានផ្ទះវីឡាទោល វីឡាភ្លោះ ផ្ទះល្វែងសម្រាប់ប្រជាពលរដ្ឋរស់នៅ និងមានរបងព័ទ្ធជុំវិញបុរី មានសេវាមូលដ្ឋាន ដូចជា ផ្សារ សាលារៀន ហើយពេលខ្លះ មានតែម្ចាស់ផ្ទះនៅក្នុងបុរីប៉ុណ្ណោះដែលមានសិទ្ធិចេញចូលបាន។ បច្ចុប្បន្ននេះ ទីក្រុងភ្នំពេញមានសំណង់បុរី ១៣៤កន្លែងជាពិសេស គឺនៅតាមតំបន់ជាយក្រុង។ ម៉្យាងវិញទៀត មានការអភិវឌ្ឍទីក្រុងរណបមួយចំនួននៅជាយរាជធានីផងដែរ។ ថ្វីត្បិតថា សំណង់បុរីថ្មីៗទាំងនេះបង្កើតលំហសម្រាប់គេហដ្ឋានរស់នៅតាមបែបថ្មីមួយ ប៉ុន្តែសមាហរណកម្មបុរីទៅក្នុងទីក្រុងពិតជាមានភាពស្មុគស្មាញក្នុងការគ្រប់គ្រង បើនិយាយពីចរាចរណ៍ និងការភ្ជាប់បុរីទៅទីក្រុងចាស់។ បញ្ហាមួយទៀងនោះ គឺគេហាមឃាត់មួយភាគនៃប្រជាពលរដ្ឋមិនឲ្យចូលទៅក្នុងទីតាំងមួយចំនួនក្នុងបុរីឡើយ។ នៅក្នុងបរិបទនេះ កម្មវិធីសហប្រតិបត្តិការរវាងស្ថាប័ន APUR (អង្គភាពនគរូបនីយកម្មក្រុងប៉ារីស) និងសាលារាជធានីភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៦មក បានជួយប្រឹក្សាដល់គម្រោង ING City នៅក្នុងការអភិវឌ្ឍតំបន់មួយដែលមានផ្ទៃដី២៥០០ហិចតា នៅប៉ែកខាងត្បូងទីក្រុង ម្តុំបឹងជើងឯក។ គោលការណ៍រៀបចំក្រុងមួយសម្រាប់ធានាឲ្យមានសមាហរណ កម្មល្អនៃគម្រោងទាំងនេះទៅក្នុងការអភិវឌ្ឍក្រុងត្រូវបានដាក់ចេញ។ អនុសាសន៍ទាំងនេះផ្តោតជាអាទិ៍ទៅលើសារៈសំខាន់នៃទីតាំងសាធារណៈ: ការរក្សាផ្ទៃបឹងមួយផ្នែក លូនៅក្នុងដីរដ្ឋ និងទីតាំងសម្រាប់ការប្រើប្រាស់រួម ព្រមទាំងសមាហរណកម្មសង្កាត់ប្រជាពលរដ្ឋក្រីក្រនៅក្នុងតំបន់អភិវឌ្ឍន៍ថ្មីនោះ និងការគិតគូរពីភូមិទាំងឡាយដែលមានស្រាប់ក្នុងតំបន់នៃគម្រោង។

ម៉្យាងវិញទៀត សាលារាជធានីភ្នំពេញក៏ធ្វើការផងដែរលើសមាហរណកម្មនៃប្រជាពលរដ្ឋក្រីក្រជាងគេនៅក្នុងទីក្រុង។ គម្រោងដែលយើងទើបចាប់ផ្តើមអនុវត្តនៅឆ្នាំនេះ ដោយសហការដៃគូជាមួយសមាគម AIMF (សមាគមអន្តរជាតិនៃអភិបាលក្រុងនិយាយភាសាបារាំង) និងសមាគមអ្នកតំណាងនៅតាមមូលដ្ឋានក្នុងប្រទេសកម្ពុជា សំដៅជាអាទិ៍ទៅធ្វើសមាហរណកម្មចូលក្នុងសង្កាត់ដែលមានការរៀបចំថ្មី នូវប្រជាពលរដ្ឋ ដែលបច្ចុប្បន្ននេះរស់នៅក្នុងផ្ទះសម្បែងមិនសូវមាំទាំ តាមបណ្តោយលូស្ទឹងមានជ័យ នៅប៉ែកខាងត្បូងឆៀងខាងកើតនៃរាជធានី។

ដោយសារសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានមានការកើនឡើង និងមានការផ្តល់ជាជំនួយបច្ចេកទេសពីសាលារាជធានីភ្នំពេញ លក្ខខណ្ឌស្ថាបត្យកម្មអប្បបរមាមួយនៃសំណង់ថ្មីៗទាំងនេះត្រូវបានដាក់ចេញ ហើយការរៀបចំទីតាំងសាធារណៈត្រូវបានធ្វើឡើង ដើម្បីធានាថា សង្កាត់ទាំងនេះមានលក្ខណៈដូចសង្កាត់ផ្សេងទៀតដែរ នោះគឺដើម្បីឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់ថ្មីៗទាំងនេះមានអារម្មណ៍ថា ពួកគាត់ក៏ដូចប្រជាពលរដ្ឋក្នុងសង្កាត់ផ្សេងទៀតដែរ ដោយទទួលបាននូវក្របខណ្ឌនៃការរស់នៅមួយសមរម្យ ព្រមទាំងទទួលបានការគិតគូរដូចប្រជាពលរដ្ឋផ្សេងទៀតនៅក្នុងរាជធានីភ្នំពេញដែរ។

បញ្ហាប្រឈមចំនួន៣ សម្រាប់អនាគត

ភ្នំពេញនឹងត្រូវដោះស្រាយបញ្ហាប្រឈមធំៗចំនួន៣ នៅក្នុងទសវត្សរ៍ខាងមុខនេះហើយសុទ្ធតែជាបញ្ហាប្រឈមជុំវិញប្រធានបទធំមួយ គឺនិរន្តរភាពនៃការអភិវឌ្ឍក្រុង។

គ្រប់គ្រងការប្រើប្រាស់ថាមពលនៅក្នុងទីក្រុង

នៅក្នុងរដូវប្រាំងកន្លងទៅនេះ សីតុណ្ហភាពនៅក្នុងទីក្រុងបានកើនឡើងយ៉ាងខ្លាំង និងបណ្តាលឲ្យមានភាពរាំងស្ងួតមួយយ៉ាងធំ ដូចនៅគ្រប់ទីកន្លែងផ្សេងទៀតលើភពផែនដីដែរ។ ភាគច្រើននៃថាមពលប្រើប្រាស់ក្នុងទីក្រុងពឹងផ្អែកទៅលើរោងចក្រវារីអគ្គិសនីនៅតាមដងទន្លេមេគង្គ ខណៈដែលកម្រិតទឹកទន្លេកាលពីឆ្នាំកន្លងទៅនេះ ទាបយ៉ាងខ្លាំង មិនធ្លាប់មានពីមុនមក។ នៅក្នុងរាជធានីទាំងមូល ក្នុងរយៈពេលជិត៣សប្តាហ៍ ភ្លើងបានដាច់រៀងរាល់ថ្ងៃ ពី៣ ទៅ៤ម៉ោងដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងទៅលើសេដ្ឋកិច្ច។ បាតុភូតធ្ងន់ធ្ងរបែបនេះ នាំឲ្យយើងលើកជាសំណួរច្រើនអំពីភាពធន់នៃរាជធានីភ្នំពេញចំពោះបម្រែបម្រួលអាកាសធាតុ។ ពិតមែនហើយ សំណួរគឺថា តើត្រូវធ្វើយ៉ាងណាដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលក្នុងទីក្រុង ដើម្បីធានាឲ្យទីក្រុងមានស្វ័យភាពខាងផ្នែកថាមពល ទោះបីជាមួយផ្នែកក៏ដោយនោះ? តើត្រូវធ្វើបែបណាដើម្បីកាត់បន្ថយកំដៅនៅក្នុងតំបន់ក្រុង និងរក្សាសីតុណ្ហភាពធម្មជាតិដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចរស់នៅបាន?

ទីក្រុងភ្នំពេញបានចាប់ផ្តើមពិចារណាទៅលើសំណួរទាំងនេះហើយ។ ជាអាទិ៍ យើងបានធ្វើការជាមួយក្រុង Kitakyūshū របស់ជប៉ុន ដែលចងសម្ព័ន្ធមេត្រីភាពជាមួយទីក្រុងភ្នំពេញ ព្រមទាំងជាមួយអង្គការ GGGI (វិទ្យាស្ថានកំណើនបៃតងពិភពលោក)។ ភាពជាដៃគូទាំងនេះ បានអនុញ្ញាតឲ្យយើងបង្កើតយុទ្ធសាស្ត្រទីក្រុងបៃតង ព្រមទាំងបង្កើតយុទ្ធសាស្ត្រក្រុងដើម្បីប្រែក្លាយរាជធានីភ្នំពេញ ឲ្យក្លាយជាទីក្រុងមួយមាននិរន្តរភាព។ លំហបៃតងគឺជាអ្វីដែលទីក្រុងភ្នំពេញខិតខំកសាងអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកហើយ ដោយបង្កើតសួន និងឧទ្យានសាធារណៈនៅក្នុងទីក្រុង ឧទាហរណ៍ ដូចជាការជួសជុលឧទ្យានវត្តភ្នំជាដើម។ គម្រោងជាច្រើនផ្សេងទៀតអាចនឹងលេចចេញជារូបរាងឡើងដើម្បីអនុញ្ញាតឲ្យទីក្រុងភ្នំពេញលើកសំណើដំណោះស្រាយជាក់ស្តែង។

ជាទ្រង់ទ្រាយធំទៅថ្ងៃអនាគត កិច្ចការដែលយើងត្រូវធ្វើ គឺយើងនឹងបង្កើតទីតាំងសាធារណៈឲ្យបានច្រើន ដើម្បីជាប្រយោជន៍របស់ប្រជាពលរដ្ឋ និងជម្រុញពួកគាត់ឲ្យចូលរួមកាន់តែច្រើនថែមទៀតនៅក្នុងជីវិតរស់នៅក្នុងទីក្រុង។ ទីកន្លែងនិងសួនសាធារណៈបច្ចុប្បន្ននេះ ត្រូវបានប្រជាពលរដ្ឋប្រើប្រាស់ដើម្បីធ្វើលំហាត់ប្រាណ និងដើរកំសាន្ត ដូច្នេះតាមរបៀបនេះ ប្រជាពលរដ្ឋពិតជាចូលរួមក្នុងការកសាង ក៏ដូចជាការសាងឡើងវិញនូវអារម្មណ៍ថា ភ្នំពេញជាទីក្រុងរបស់ពួកគាត់ ហើយពួកគាត់នឹងចូលរួមក្នុងការអភិវឌ្ឍអត្តសញ្ញាណប្រជាពលរដ្ឋមួយ។

គ្រប់គ្រងនិងកែលម្អចរាចរណ៍ផ្លូវគោក

ជាធម្មតា ប្រធានបទពាក់ព័ន្ធនឹងលំហសាធារណៈពិតជានាំយើងទៅគិតដល់ការធ្វើយ៉ាងណាឱ្យចរាចរណ៍មានភាពរលូន។ ការធ្វើដំណើរដោយថ្មើរជើងនៅក្នុងទីក្រុងបច្ចុប្បន្ននេះ គឺជារឿងលំបាកបំផុត។ ចិញ្ចើមផ្លូវមួយភាគធំត្រូវបានប្រជាពលរដ្ឋដែលរស់នៅជាន់ផ្ទាល់ដីយកទៅប្រើប្រាស់ជាលក្ខណៈឯកជន ដូចជាធ្វើចំណតយានយន្ត ធ្វើជាទីតាំងរកស៊ី ឬជាកន្លែងជួសជុលផ្សេងៗ។ ដូច្នេះក្នុងនាមសាលារាជធានីភ្នំពេញយើងត្រូវធ្វើការជាមួយរដ្ឋអំណាចមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីយកចិញ្ចើមផ្លូវទាំងនេះមកជូនប្រជាពលរដ្ឋគ្រប់គ្នាប្រើប្រាស់ជាសាធារណៈ ធ្វើបែបនេះបាន គឺយើងនឹងកែលម្អចរាចរណ៍ថ្មើជើង។ ប៉ុន្តែ យើងប្រឈមមុខនឹងបញ្ហាដែលគ្មានទីបញ្ចប់មួយ នោះគឺប្រជាពលរដ្ឋមិនធ្វើដំណើរថ្មើជើងទេ ដោយសារតែចិញ្ចើមផ្លូវមិនស្រឡះ និងបែរទៅជិះម៉ូតូ ឬជិះរថយន្តវិញ ទោះបីក្នុងចម្ងាយផ្លូវខ្លីក៏ដោយ។

នៅក្នុងទីក្រុងមួយដែលយានយន្តចុះបញ្ជីមានចំនួនរហូតទៅដល់ជាង២លានគ្រឿងទៅហើយនោះ (អត្រាកំណើនមានរហូតដល់១១%ក្នុងមួយឆ្នាំ) បញ្ហាចរាចរណ៍គឺជាក្តីបារម្ភមួយកាន់តែខ្លាំងឡើងសម្រាប់អាជ្ញាធរសាធារណៈ។ ការបង្កើតរដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងនៅឆ្នាំ២០១៨ បានអនុញ្ញាតឲ្យសាលារាជធានីភ្នំពេញដាក់ឲ្យដំណើរការរថយន្តក្រុងចំនួន១៥ខ្សែ ដើម្បីជួយសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋគ្រប់រូបជាពិសេស ប្រជាពលរដ្ឋដែលមានជីវភាពលំបាកជាងគេ។ ជាការពិត កម្មករកម្មការនី សិស្ស និស្សិត មន្ត្រីរាជការ អាចជិះរថយន្តក្រុងដោយឥតគិតថ្លៃ។ ចំពោះអ្នកត្រង់បង់ថ្លៃ សំបុត្រមានតម្លៃតែមួយគត់ គឺជិះម្តងអស់ថ្លៃ១០០០រៀល។ ទីក្រុងក៏ធ្វើការយ៉ាងសកម្មផងដែរលើការអភិវឌ្ឍនិងកែលម្អខ្សែបណ្តាញផ្លូវថ្នល់របស់ខ្លួន ហើយផ្លូវរវាងថ្មីៗជាច្រើនខ្សែនឹងលេចចេញជារូបរាងឡើង ពីពេលនេះដល់ឆ្នាំ២០៣០។

គ្រប់គ្រងកាកសំណល់

បញ្ហាប្រឈមចុងក្រោយដែលសាលារាជធានីភ្នំពេញត្រូវដោះស្រាយគឺការគ្រប់គ្រងកាកសំណល់។ នៅឆ្នាំ២០១៨ ទីក្រុងបានផលិតសំណល់រឹងចំនួន២៧០០តោនក្នុងមួយថ្ងៃ នេះគឺជាបរិមាណមួយដែលកើនឡើង១៣%ក្នុងមួយឆ្នាំ អស់រយៈពេល១០ឆ្នាំមកហើយ។ កន្លែងចាក់សម្រាមបច្ចុប្បន្ននេះ ដែលយើងបានបើកកាលពី៦ឆ្នាំមុន ត្រូវបានគិតគូរសម្រាប់ចាក់សម្រាមរយៈពេល១០ឆ្នាំ ប៉ុន្តែកន្លែងនេះនឹងត្រូវបិទនៅចុងឆ្នាំនេះ ពីព្រោះសម្រាមពេញទៅហើយ។ ដៃគូជាប្រវត្តិសាស្ត្ររវាងអង្គការ ចៃកា និងសាលារាជធានីភ្នំពេញ លើបញ្ហាលូបង្ហូរទឹក និងការគ្រប់គ្រងទឹកនៅក្នុងទីក្រុង បានអនុញ្ញាតឲ្យយើងបង្កើតគម្រោងសាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់មួយ ហើយការដ្ឋានសាងសង់នឹងចាប់ផ្តើមនៅឆ្នាំក្រោយនេះ។ ចំណុចចុងក្រោយគឺដោយមានការជួយជ្រោមជ្រែងពីសមាគម AIMF សាលាក្រុងបានធ្វើការពិចារណាទៅលើបញ្ហាភក់បង្គន់ និងទៅលើរបៀបលើកតម្លៃផលិតផលធ្វើចេញពីភក់បង្គន់នេះនៅនឹងកន្លែង ដូច្នេះគឺអាចជួយជម្រុញឲ្យមានថាមភាពសេដ្ឋកិច្ចមួយផ្នែកក្នុងស្រុក។ គឺនៅក្នុងវិស័យទាំងនេះហើយដែលយើងត្រូវរកឱ្យឃើញនូវដំណោះស្រាយប្រកបដោយនវានុវត្តន៍។

សេចក្តីសន្និដ្ឋាន

ភ្នំពេញគឺជាទីក្រុងមួយដែលមានភាពធន់ និងបានរស់រានមានជីវិតឡើងវិញក្រោយឆ្នាំ១៩៧៩ ដោយសារសមត្ថភាពសម្របខ្លួនរបស់ប្រជាពលរដ្ឋនិងសមត្ថភាពរកដំណោះស្រាយតាមបរិបទក្នុងស្រុកផ្ទាល់ ព្រមទាំងដោយសារការធ្វើសមាហរណកម្ម ទម្លាប់ប្រើប្រាស់ និងច្នៃប្រឌិតយន្តការ ដែលគេធ្លាប់អនុវត្តមានប្រសិទ្ធភាពនៅទីក្រុងផ្សេងទៀតរួចមកហើយ។ សាលារាជធានីភ្នំពេញតែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការងារជាខ្សែបណ្តាញ ដោយពឹងផ្អែកទៅលើសមត្ថភាពផ្សេងៗជាច្រើន។ ដូច្នេះ សាលារាជធានីបានបើកចំហដល់កិច្ចសហប្រតិបត្តិការមួយយ៉ាងសកម្មជាមួយដៃគូ ដែលជាសង្គមស៊ីវិលដើម្បីរួមគ្នាត្រៀមខ្លួនឲ្យបានកាន់តែប្រសើរសម្រាប់ថ្ងៃអនាគត។ សាលារាជធានីភ្នំពេញសង្ឃឹមយ៉ាងមុតមាំទៅលើការប្តេជ្ញាចូលរួមក្នុងគម្រោងទីក្រុងឆ្លាតវៃ ដែលផ្តួចផ្តើមឡើង និងអភិវឌ្ឍដោយអាស៊ាន ហើយគម្រោងនេះនឹងអនុញ្ញាតឲ្យទីក្រុងភ្នំពេញដោះស្រាយរាល់បញ្ហាទាំងឡាយដូចបានលើកឡើងខាងលើ ដោយបញ្ចូលលទ្ធភាពប្រើបច្ចេកវិទ្យាថ្មីៗ។

Les économies urbaines dynamiques : un vecteur de progrès social dans les villes cambodgiennes

Quel est le premier marqueur du développement d'un pays ? La croissance de ses villes. L'expansion d'une ville, ses infrastructures et la transformation de ses services urbains sont les principaux indicateurs d'une économie croissante, alimentée par les investissements locaux et internationaux.

PAR NATHAROUN NGO

© Cambodge Nouveau

Sur le chantier de la tour Canadia, 2007.

On the Canadia Tower construction site, 2007.

ការដ្ឋានសំណង់អគារកាណាឌីយ៉ា ឆ្នាំ២០០៧

Les économies sont souvent uniquement analysées à l'échelle d'un pays (avec le PIB, la stabilité macroéconomique et fiduciaire, les flux commerciaux, les politiques de migration, etc.). Ce niveau d'analyse a dominé les analyses politiques et économiques dans les quatre dernières décennies. Récemment, dans les cinq à dix dernières années, des travaux d'analyse politique et de recherche académique ont utilisé les villes comme indicateurs mesurant la performance économique. Ce changement peut s'expliquer par la capacité grandissante de récolte et d'analyse de données ventilées au niveau local, combinée avec l'attention croissante portée aux villes. La croissance des taux d'urbanisation à l'échelle mondiale est devenue une force de transformation majeure qui doit être bien gérée par les gouvernements locaux. Ceci est d'autant plus important pour des économies en développement que ce sont dans les villes que cette croissance se concentre. Ceci a un effet direct sur les sources de revenu des habitants tout en déterminant la qualité de leurs conditions de vie.

Au Cambodge, la transformation et la croissance de Phnom Penh dans la dernière décennie sont comparables à celles des pays qui, dans le monde, connaissent la croissance économique la plus rapide. Le concept de villes comme moteur de croissance[1,2] est maintenant répandu puisque les gouvernements locaux essayent de maximiser les opportunités offertes par la croissance urbaine.

L'intensification du phénomène de départ des usines (à forte intensité de main-d'œuvre) de Chine et d'autres pays asiatiques à cause de salaires plus élevés et la restructuration de chaînes d'approvisionnement régionales ont accéléré l'industrialisation, ce qui a ensuite accéléré le processus d'urbanisation de la région de Phnom Penh. Avec des capacités de fabrication à moindre coût et une main d'œuvre jeune, le Cambodge est devenu un des lieux de relocalisation privilégié de la région.[4]

Le Cambodge suit la voie d'un développement économique classique : la part de la contribution au PIB du secteur agricole s'est réduite alors que l'industrie manufacturière et les services sont maintenant au cœur de la croissance de l'économie. La distribution spatiale de l'infrastructure économique du Cambodge tend à se concentrer dans des zones urbaines et péri-urbaines et le capital productif et la croissance des actifs est plus lente dans les zones rurales. Le concept d'économies d'agglomération[5] explique cette préférence géographique pour les villes : les biens et les services sont produits plus efficacement dans les zones les plus densément peuplées qui offrent un réservoir de main-d'œuvre qualifiée et un réseau d'entreprises aux activités complémentaires. Ces entreprises sont à la fois des producteurs et des créateurs d'une masse importante de clients. Leur concentration favorise aussi une compétition saine, engendrant une meilleure qualité et diversité de services, à des prix plus équilibrés.

Au niveau mondial, les chiffres révèlent également que les zones urbaines génèrent 55% du produit national brut dans les pays à faible revenu et 73% dans les pays à revenu intermédiaire.[6]

Phnom Penh est certainement l'une des villes qui contribue majoritairement au PIB national. Trois des quatre piliers de la croissance qui ont alimenté l'économie cambodgienne au cours des vingt dernières années (le bâtiment, la confection et l'industrie manufacturière, les services et le tourisme) concentrent la majorité de leurs activités à Phnom Penh et dans d'autres grandes villes secondaires.

LES VILLES, LA TECHNOLOGIE ET LA TRANSFORMATION DES DONNÉES

La technologie permet une meilleure gestion du développement urbain. Les données générées par des individus et captées par de nouveaux moyens technologiques, tels que les réseaux d'infrastructures numériques, transforment la manière dont les villes sont gérées dans les économies en développement. Cette « révolution des données » a principalement lieu dans les centres urbains. A Phnom Penh, on remarque l'émergence de centres de données (il s'agit principalement d'entités privées qui collectent, directement ou indirectement et à des fins privées, les données de leur base de clients/consommateurs) gérés par des sociétés locales ou internationales. Peu de grandes entreprises d'analyse des données ont pénétré le marché cambodgien au cours des dernières années. Jusqu'à maintenant, le « big data » ne sert qu'à des fins commerciales, principalement pour mieux comprendre le comportement des clients dans des secteurs spécifiques (la banque, la finance, la téléphonie, les transports, etc.). Il est peut-être prématuré de parler d'une révolution des données au Cambodge[7] : la collecte et l'analyse des données en sont encore à leurs débuts puisque les infrastructures existantes restent limitées et que les systèmes de législation et de gouvernance sont en train d'émerger. Le potentiel des mégadonnées ne peut être exploité sans intelligence artificielle et la capacité d'exploitation des données combinées avec les dernières infrastructures de technologies numériques (l'IdO). Mais le concept de « villes intelligentes » deviendra vite une réalité omniprésente.

Des innovations technologiques majeures ont déjà été déployées et ont développé de nouveaux services urbains. Prenons l'exemple de Grab, une entreprise en Asie du Sud-Est qui a modifié le marché par l'apport d'une technologie nouvelle. L'entreprise a rapidement transformé l'accès des résidents de Phnom Penh aux services de transport. Avant Grab, peu d'acteurs-pionniers avaient pénétré le marché (il y avait notamment PassApp, l'entreprise cambodgienne de mise en contact d'utilisateurs avec des conducteurs) et leur accès au financement, aux technologies et à l'expertise était local et donc plus restreint.

De nouvelles plateformes d'échange soutenues par Facebook ont généré des réseaux additionnels de vente et de distribution à Phnom Penh.[8] Toutes ces innovations technologiques transforment les économies urbaines et les comportements sociaux en créant de nouveaux marchés et en devenant des solutions grand public accessibles à un large éventail de la population urbaine.

Des entreprises technologiques locales qui associent l'entreprenariat social aux innovations technologiques ont aussi fait leur apparition à Phnom Penh. Ces acteurs cherchent à résoudre des problèmes générés par la ville en améliorant l'efficacité d'un service déjà fourni (tel que la récupération des déchets ou les systèmes de transport en commun) ou en créant des services qui répondent à de nouveaux problèmes (tel qu'améliorer

Phnom Penh : des transports collectifs informels à l'utilisation d'une application de son smartphone « PassApp » ou « Grab » pour commander son chauffeur.

Phnom Penh: informal public transport based on a "PassApp" or "Grab" application to book a ride.

ភ្នំពេញ៖ មធ្យោបាយដឹកជញ្ជូនសាធារណៈឯកជន ប្រើកម្មវិធីទូរស័ព្ទដៃ ដើម្បីហៅកង់បី ឬតាក់ស៊ី "PassApp" ឬ "Grab"

Chantier de construction d'un *borey* sur la presqu'ile de Chrui Changvar.

Borey construction site on the Chrui Changvar peninsula.

ការដ្ឋានដំណង់បុរីមួយ កន្លែងនៅជ្រោយចង្វារ

l'accessibilité pour les personnes en situation de handicap). Leur objectif n'est pas de remplacer le service public ou de concurrencer des exploitants privés. Ils opèrent dans des niches de marché pour résoudre des problèmes urbains spécifiques à un coût abordable en accord avec les principes de fonctionnement des entreprises sociales.
La technologie et les données sont en mesure d'avoir un effet sur les opportunités économiques et l'amélioration des services sociaux, contribuant ainsi directement aux économies urbaines dynamiques.
Si des nouvelles formes de vulnérabilité urbaine menacent le modèle de croissance économique de Phnom Penh, il faut présenter les grandes tendances qui résultent de cette transformation urbaine en cours.

LES TENDANCES DE TRANSFORMATION URBAINE

La construction des *borey* est une des forces motrices de l'expansion urbaine[9] de Phnom Penh depuis la fin des années 1990. Il s'agit de nouvelles formes de résidences péri-urbaines construites par des promoteurs privés, majoritairement cambodgiens. Certains *borey* permettent une nouvelle mixité sociale à l'intérieur de la ville. La densité de population et l'augmentation du prix des terrains associées au développement d'une réelle classe moyenne urbaine engendrent la multiplication des résidences fermées, particulièrement à la périphérie de Phnom Penh. Certains de ces projets deviennent des mégaprojets, s'étendant sur de très vastes surfaces. Ces résidences fermées et privées construites dans des pays en développement sont souvent accusées de créer des «élites» et de rassembler les ménages les plus riches, menant ainsi à l'existence de «ghettos pour les riches». A Phnom Penh, les résidences privées ont certaines de ces caractéristiques. Leur plan masse est celui d'un lotissement de maisons standardisées encloses de murs qui délimitent le terrain de la communauté, leur accès est sécurisé et contrôlé et les services sont privés et gérés par une administration centrale privée. Mais les résidences privées cambodgiennes ne rassemblent pas forcément que l'élite.
Le groupe Peng Huoth, promoteur immobilier, leader du marché, s'est attaché à la qualité des espaces de vie, de l'architecture intérieure des maisons et de leur environnement, des espaces extérieurs et de loisirs. Le plan initial prenait exemple sur des modèles réussis de résidences fermées en Asie du Sud-Est mais en les adaptant aux besoins sociaux et culturels cambodgiens. La diversité des types et des tailles de logements proposés aux résidents a permis de réunir dans un même espace géographique des classes socio-économiques différentes, allant de familles très aisées à des foyers de la classe moyenne. La diversité de profils, de métiers, de niveaux de revenu, d'âges, d'ethnicités et de types de ménage est unique et se doit d'être analysée et comprise davantage. Certains peuvent arguer que les disparités de revenu et de richesse perdurent dans la résidence fermée, mais la réussite de ses créateurs, dont l'intention et la vision étaient de garantir une meilleure diversité sociale et un environnement agréable avec une densité élevée d'espaces verts pour répondre aux besoins des cambodgiens, a été démontrée par l'expansion de leurs projets et de leurs résidences. La qualité des services fournis aux résidents est également différente, avec plus d'égalité d'accès et des prestations de meilleure qualité pour tous, quelles que soient la classe sociale et le statut. Les règles internes qui sont imposées ont une influence sur les comportements individuels et collectifs des membres de la résidence, ce qui a permis de définir ce qu'est une communauté respectueuse et sûre. Cela a peut-être permis de mieux comprendre collectivement ce que peut être un quartier cambodgien. Alors que des comportements de plus en plus individualistes se remarquent dans le centre-ville, tels que l'usage abusif de l'espace public pour satisfaire des besoins privés et la résolution de conflits via le pouvoir social et l'autorité), un véritable civisme émerge dans ces communautés.[10] Le défi sera de maintenir ou d'accroître la diversité sociale et la qualité des services dans le temps.
La deuxième tendance démontre que les économies urbaines des villes cambodgiennes peuvent accélérer l'égalité des genres. Puisque le premier facteur de migration des zones rurales vers les zones urbaines est l'emploi, la capitale cambodgienne et plusieurs villes primaires ou secondaires attirent telles des aimants une large population rurale d'hommes et de femmes. Une étude récente[11] énumère différents facteurs explicatifs. La vie urbaine, en comparaison de la vie en zone rurale, impose des dépenses plus élevées (coût du logement, du transport) et de nombreux coûts masqués (énergie, santé, etc.). En même temps, les revenus possibles sont eux aussi plus élevés, à la fois en terme d'opportunités et de paie journalière et mensuelle. Les coûts d'opportunités économiques pour les femmes vivant dans une zone urbaine et qui ne visent pas les activités les plus génératrices de revenus sont bien plus élevées que dans les zones rurales. Ceci mène à un changement lié à des divisions du travail genrées plus claires, ce qui attribue aux femmes un rôle de création de revenus encore plus important. Un deuxième constat concerne la façon dont le contexte urbain façonne différemment les modèles sociaux et culturels de comportement entre femmes et hommes. Les femmes sont plus sollicitées par des opportunités professionnelles variées, ce qui leur permet de démontrer qu'elles ont des compétences et qu'elles peuvent rivaliser avec les hommes dans plusieurs secteurs économiques (comme l'industrie du vêtement ou du service). Ceci a permis un changement dans les perceptions, les statuts et les normes liés au genre. Phnom Penh a aussi rendu possible une évolution chez les jeunes cambodgiens dans leur perception des communautés LGBTQ+[12] et les obstacles auxquelles ces groupes font face. Malgré certains progrès, de forts préjugés et stéréotypes demeurent: les communautés LGBTQ+ sont encore écartées des services sociaux et de santé, de l'éducation et du monde du travail formel.[13]
Une recherche de terrain approfondie permettrait de déterminer comment la ville peut jouer un rôle plus actif en offrant à tous des lieux plus sûrs et vivables.

Les *boreys* du groupe Peng Huoth ont fait le choix de donner une grande place à la nature.

Boreys built by the Peng Huoth group include extensive space for nature.

បុរីក្រុមហ៊ុន ប៉េង ហួត ផ្តល់សារៈសំខាន់ដល់ការធ្វើសួននិងដាំដើមឈើ

© Lim Bunhok

1. *Cities: Engines of Growth and Prosperity for Developing Countries?*, Gilles Duranton, 2008.
2. La Banque mondiale a également analysé ce concept en 1998.
3. *Relocating labour-intensive manufacturing firms from China to Southeast Asia a preliminary investigation.* Chun Yang, 2016.
4. Les systèmes de préférences commerciales tels que le SGP aux Etats-Unis, les accords multifibres ou «Tout sauf les armes» dans l'Union européenne ont créé des conditions économiques très favorables pour les investisseurs qui ciblent des grands marchés d'exportation.
5. *Agglomeration economies and evolving urban form.* Genevieve Giuliano, Sanggkyun Kang, Quan Yuan, The Annals of Regional Science, 2019.
6. Nations Unies, Département des affaires économiques et sociales et Programme des Nations unies pour le développement, Rapport du forum mondial de la gouvernance locale et des services sociaux pour tous, 2000.
7. En décembre 2019
8. *Infrastructure as Creative Action: Online Buying, Selling, and Delivery in Phnom Penh.* Margaret Jack, Jay Chen, Steven J. Jackson. May 2017
9. *The Production of Urban Spaces in Phnom Penh.* Gabriel Fauveaud, 2015.
10. Ce paragraphe se réfère au projet Borey Peng Huoth Boeung Snour project sur la route nationale 1. Les données ont été récoltées lors d'entretiens réalisés par le Centre pour les études Khmer en 2019 auprès de résidents locaux de *borey* (échantillon d'environ 70 personnes sur une période de neuf mois) et avec l'un des fondateurs du groupe Peng Huoth.
11. *How Cities Erode Gender Inequality: A New Theory and Evidence from Cambodia,* Alice Evans, CID Faculty Working Paper No. 356, July 2019
12. Cet acronyme désigne les personnes lesbiennes, gays, bisexuelles, transgenres, et queer. Le plus (+) se réfère notamment aux individus qui interrogent leur identité sexuelle actuelle ainsi qu'aux personnes intersexes et asexuelles.
13. Salas V & Srun S. *An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping.* 2014 Social Protection Coordination Unit, SPCU-CARD, Phnom Penh.

How much can dynamic urban economies be a vector for social progress in Cambodian Cities?

What is the first noticeable aspect that demonstrates the development of a country? Its cities' growth. The expansion of a city, its infrastructure and the transformation of urban services are prime visible aspects of a growing economy, fueled by incoming domestic and international investments.

BY NATHAROUN NGO

WHY CITIES ARE DYNAMIC ENGINES OF GROWTH

The economic opportunities offered by globalization are much greater in cities, and this is particularly true in the context of developing countries such as Cambodia and cities such as Phnom Penh.
Economies are often analyzed at country-level only (GDP and business performance, macroeconomic and fiduciary stability, trade flows, migration policies, etc.). This level of analysis was dominant in most policy and economic analysis over the last 4 decades. It is only recently (past 5-10 years) that policy analysis and academic research has used cities as indicators to measure economic performances. Increasing capacity to collect and analyze disaggregated data at local level, combined with the growing importance given to cities may have paved the way. Increasing urbanization rates at global level have become a major transformative force that must be well managed by local government. This is even more critical in graduating economies, as cities in developing countries are places where growth concentrates. This directly impacts the livelihood opportunities of its inhabitants, while also predetermining the quality of their living conditions.
In Cambodia, transformation and growth in Phnom Penh over the past 10 years has clearly reflected one of the fastest growing economies in the world. The concept of cities as engines of growth[1, 2] is now a recognized part of mainstream knowledge, as local governments try to maximize opportunities offered by urban growth.
The intensification of manufacturing facilities (using labor intensive production) relocating out of China and other Asian countries due to higher wages, and the restructuring of regional supply chains have further accelerated industrialization[3], which has in turn accelerated urbanization processes in the Phnom Penh region. With low-cost manufacturing capacities and the presence of a young labor force, Cambodia is still among the preferred relocation sites in the region .
Cambodia follows a classic economic development path: the share of its agricultural sector's contribution to GDP decreased, while manufacturing and services are now central to economic

1. C13. Cities: Engines of Growth and Prosperity for Developing Countries? Gilles Duranton, 2008.
2. The World Bank also studied the concept in 1998.
3. Relocating labour-intensive manufacturing firms from China to Southeast Asia a preliminary investigation. Chun Yang, 2016

growth. The spatial distribution of Cambodia's economic infrastructure tends to concentrate within urban and peri-urban areas, and physical capital and asset growth is less rapid in rural areas. This geographical preference toward cities is well explained by the concept of "agglomeration economies[5]": goods and services are produced most efficiently in densely populated areas which offer access to a pool of skilled labor, and a network of firms with activities that complement each other. Those firms can act as suppliers, while contributing to create a critical mass of customers. The concentration of businesses also stimulates positive competition, improving the quality of services, diversity and price affordability. Zooming out to global scale, figures also show that urban areas generate 55% of gross national product in low-income countries, and 73% in middle-income countries[6]. Phnom Penh is certainly one of the main contributing cities to national GDP figures. Three of the four growth drivers that have fueled Cambodia's economy over the last 20 years (construction; garment, manufacturing and services; tourism) have most of their activities concentrated in Phnom Penh and major secondary cities.

CITIES, TECHNOLOGY AND DATA TRANSFORMATION

Technology is leading to better management of urban development. Data generated by individuals and captured by new technological means, such as digital infrastructure networks, is transforming the way cities are managed in developing economies. This "data revolution" mainly occurs in urban centers. In Phnom Penh, we are witnessing the emergence of data centers (mostly private entities that directly or indirectly collect data from its customer/consumer base for private purposes) managed by local and international companies. Only a few big data analytical companies have entered the Cambodian market in recent years. At present, "big data" only serves business purposes, mainly to better understand customer behaviors in specific sectors (banking and finance, telcos, transport etc.). It may be premature to speak of a data revolution in Cambodia[7], as data collection and analysis is still in its infancy stage due to limited existing infrastructure and nascent legislation/governance systems. The potential of big data can't be unlocked without AI and data mining capabilities, combined with the latest digital technologies infrastructure (IoT). But it is only a matter of time before the "smart cities" concept turns into a pervasive reality.

Powerful urban tech innovators have already deployed and scaled-up new urban technology services. Grab, for instance, a well-known company in Southeast Asia, has been both a market and technology disruptor. The company has rapidly transformed the way Phnom Penh's residents access transportation services. A few other pioneer-actors entered the market before Grab (such as Cambodian ride hailing company Pass'App), but their access to funding, technologies, and expertise was local and therefore more restricted.

Facebook supported new online trading platforms have created additional sales and distribution networks in Phnom Penh[8]. All these new technological innovations are transforming urban economies and social behaviors, by creating new markets and becoming mainstream solutions accessible to a wide range of urban populations.

Phnom Penh has also seen the emergence of a local "tech scene" that combines social entrepreneurship and technological innovations. Those actors seek to address urban generated issues by either improving the efficiency of an existing service (e.g. solid waste collection, public transport systems), or by creating new services that address emerging issues (better access for disabled people). Their aim is not to replace public service capacities or compete with private operators. They operate in niche markets to help solve specific urban issues, while delivering a service with an affordable fee, in line with the operating principles of social enterprises.

Technology and data have demonstrated capacity to serve both economic opportunities and social service improvement, thereby directly contributing to dynamic urban economies.

While new forms of urban vulnerabilities may threaten Phnom Penh's long-term economic growth model, it is important to mention some major trends that result from the ongoing urban transformation.

URBAN TRANSFORMATION TRENDS.

One major driving force of urban expansion[9] in Phnom Penh since the end of the 1990s is the construction of *borey*, i.e. new form of peri-urban housing community projects built by private developers, mainly Cambodian. Some of those *borey* are producing a new social mix within the city. Increasing population density and land prices, associated with the development of a solid urban middle class, is leading to the proliferation of gated communities particularly on the periphery of Phnom Penh. Some of those projects are becoming mega-projects, spreading across large areas of land. Theses gated communities in developed countries are often depicted negatively as creating a class of wealthy elites, living a segregated existence in "ghettos for the rich". However, Cambodian gated communities possess some of these characteristics in Phnom Penh. In design, they consist of clusters of "standardized" houses surrounded by walls that form the boundary of the community with controlled security access and private services regulated by a central private authority. Cambodian gated communities do not all consist of similar clusters of social "elites".

A Cambodian real estate developer, one of the market leaders, Peng Huoth Group, has managed this concept differently. It has focused on places that offer high quality, both in terms of interior architecture and the exterior environment and recreation areas. The initial master plan emulated successful gated community models in the Southeast Asia region but adapted them to Cambodian social and cultural needs. By offering residents diversity in both the type and size of housing, it has brought together within the same geographical space, different socio-economic classes, ranging from high net worth families to middle-income households. The variety of profiles, occupations, revenue levels, age groups, ethnicities, and household types is quite unique and merits further research. One can argue that income and wealth disparities remain within the gated community, but the intention and vision of its creators to ensure greater social diversity and a pleasant living environment, and to meet the needs of local people with more generous green spaces, have been successfully demonstrated by the growth of their projects and communities. The quality of services provided to community residents, with more equal access and better-quality provision for all, and to meet the needs of local people with more generous green spaces, social classes and status, is also different. The enforcement of internal rules and regulations influences individual and collective behaviour in the community, leading to a stronger sense of what a respectful and safe community is. It may have given rise to a new collective understanding of what a Cambodian neighborhood could look like. By contrast with the prevalence of increasingly individualistic behaviours in the city centre, measured by the sometimes disruptive use of public spaces for private purposes and the use of social power on the authority to resolve conflict, genuinely civic attitudes are emerging[10]. The challenge will be to maintain or increase this social diversity and service quality over time.

From another perspective, urban economies in Cambodian cities can be seen as a catalytic force for gender equality. As the first driver of rural to urban migration is employment, the capital city and several primary or secondary cities act as magnets and attract large rural male and female populations. A recent study[11] identifies some interesting factors associated with this trend. By comparison with rural life, urban living undoubtedly demands greater household expenditure to cover accommodation and transportation costs, as well as hidden factors (energy, health, etc.). At the same time, the work opportunities are also greater, and therefore the potential for higher incomes. The economic opportunity costs for women not seeking the best income generating activities while living in an urban area are much higher than in rural areas. This has produced a shift in traditional gender divisions of labour, and given women and even more important role in income generation. The second factor concerns the way in which urban conditions shape social and cultural models relating to the relations between women and men. The increased exposure to various working opportunities enables women to clearly demonstrate that they have skillsets and professional competencies and that they can easily compete with men in several economic sectors (such as in garment or services sector). This has directly contributed to a shift in gender -related perceptions of status and norms. Phnom Penh has also enabled young Cambodians to become increasingly aware of LGBTQ+[12] communities and the challenges they face. Despite progress, strong negative biases and stereotypes remain; LGBTQ+ communities still experience exclusion from social and health services, education and the formal workforce[13]. More in-depth field research is needed to define how a city can play a more active role in providing all with safer and more livable spaces.

4. Preferential economic cooperation and trade schemes such as the US Generalized System of Preference and Multi-Fiber agreement, and the EU Everything But Arms (EBA) have created very favorable economic conditions for investors targeting large export markets.

5. Agglomeration economies and evolving urban form. Genevieve Giuliano, Sanggkyun Kang, Quan Yuan, The Annals of Regional Science, 2019.

6. United Nations, Department for economic and social affairs and the United Nations Development Program, Report of the United Nations Global Forum on Local Governance and Social Services for All, 2000.

7. As of December 2019

8. Infrastructure as Creative Action: Online Buying, Selling, and Delivery in Phnom Penh. Margaret Jack, Jay Chen, Steven J. Jackson. May 2017

9. The Production of Urban Spaces in Phnom Penh. Gabriel Fauveaud, 2015.

10. Reference is made within this paragraph to Borey Peng Huoth Boeung Snour project, located on National Road Number 1. The data derives from direct short interviews made by the Center for Khmer Studies in 2019 with local borey residents (sample size of around 70 people over a period of 9 months) and with one of the founders of the Peng Huoth Group.

11. How Cities Erode Gender Inequality: A New Theory and Evidence from Cambodia, Alice Evans, CID Faculty Working Paper No. 356, July 2019

12. LGBTQ+ is an acronym that designates lesbian, gay, bisexual, transgender, and queer. Plus (+) refers to individual questioning their current sexual identity, intersex, and asexual people.

13. Salas V & Srun S. An Exploration of Social Exclusion of Lesbians, Gay and Transgender Persons in Families and Communities and their ways of coping. 2014 Social Protection Coordination Unit, SPCU-CARD, Phnom Penh.

© Phnom Penh Post

Phnom Penh : transport collectif informel des ouvriers en camion.

Phnom Penh: informal truck transport for workers.

ភ្នំពេញ៖ មធ្យោបាយដឹកជញ្ជូនសាធារណៈឯកជន ឡានទ្រុងដឹកកម្មករ

កម្លាំងសេដ្ឋកិច្ចក្រុង៖ តើជាកត្តាមួយនៃភាពចម្រុងចម្រើនសង្គមនៅក្នុងទីក្រុងកម្ពុជាឬទេ ?

តើអ្វីទៅជាសញ្ញាសំគាល់ដំបូងគេនៃការអភិវឌ្ឍរបស់ប្រទេសមួយ ? គឺកំណើននៅក្នុងទីក្រុង។ ការពង្រីកទីក្រុង ហេដ្ឋារចនាសម្ព័ន្ធក្រុង និងរូបបរិវត្តន៍នៃសេវាកម្មក្រុង ទាំងអស់នេះសុទ្ធតែជាសូចនាករសំខាន់ៗ សម្រាប់វាស់វែងកំណើនសេដ្ឋកិច្ចមួយ ដែលអាចមានទៅបាន ដោយការវិនិយោគក្នុងស្រុក និងការវិនិយោគអន្តរជាតិ។

ដោយលោក ង៉ោ ណត្តរុន

នៅក្នុងរយៈពេល១៥ឆ្នាំ ទីក្រុងភ្នំពេញបានផ្លាស់ប្តូរទ្រង់ទ្រាយ

ហេតុអ្វីបានជាទីក្រុងគឺជាកម្លាំងចលករនៃកំណើន ? កាលានុវត្តភាពសេដ្ឋកិច្ចដែលអាចកើតមានឡើងបានដោយសារសាកលភាវូបនីយកម្ម ពិតជាមានច្រើននៅក្នុងទីក្រុង ហើយរឿងបែបនេះរឹតតែត្រឹមត្រូវថែមទៀត ជាពិសេស នៅក្នុងបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា និងក្នុងទីក្រុងនានា ដូចជាទីក្រុងភ្នំពេញនេះជាដើម។

ជាទូទៅ សេដ្ឋកិច្ចត្រូវបានវិភាគតែក្នុងកម្រិតប្រទេសតែប៉ុណ្ណោះ ដោយពិនិត្យមើលផលិតផលក្នុងស្រុកសរុប ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពធនប័ត្រ រំហូរពាណិជ្ជកម្ម និងនយោបាយទេសន្តរប្រវេសន៍ជាដើម។ គេច្រើនធ្វើការវិភាគបែបនេះ ជាជាងការវិភាគនយោបាយសេដ្ឋកិច្ច នៅក្នុងរយៈពេល៤ទសវត្សរ៍ចុងក្រោយនេះ។ កាលពីពេលថ្មីៗ ពោលគឺក្នុងរយៈពេលពី៥ទៅ១០ឆ្នាំចុងក្រោយនេះ ការងារវិភាគនយោបាយ និងការងារសិក្សាស្រាវជ្រាវ បានយកទីក្រុងជាសូចនាករសម្រាប់វាស់វែងគុណវុឌ្ឍិសេដ្ឋកិច្ច។ ការផ្លាស់ប្តូរវិធីសាស្រ្តនេះអាចពន្យល់បានដោយសមត្ថភាពកាន់តែខ្លាំងឡើងនៃការប្រមូល និងវិភាគទិន្នន័យបាន តាំងពីកម្រិតមូលដ្ឋានឡើងទៅ បូកផ្សំនឹងការផ្តោតការចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើទីក្រុង។ កំណើនអត្រានគរូបនីយកម្មក្នុងកម្រិតពិភពលោក បានក្លាយទៅជាកម្លាំងនៃរូបបរិវត្តន៍ចំបងមួយ ដែលរដ្ឋាភិបាលត្រូវតែគ្រប់គ្រងឲ្យបានល្អ។ ចំណុចនេះរឹតតែសំខាន់ ថែមទៀត

សម្រាប់សេដ្ឋកិច្ចដែលកំពុងអភិវឌ្ឍន៍ ដោយសារថា កំណើននេះ ភាគច្រើន គឺមានតែនៅក្នុងទីក្រុងប៉ុណ្ណោះ។ កំណើននេះផ្តល់ផលជះផ្ទាល់ទៅលើប្រភពចំណូលរបស់ប្រជាពលរដ្ឋ និងថែមទាំងជាកត្តាកំណត់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទៀតផង។

នៅកម្ពុជា រូបបរិវត្តន៍ និងកំណើនរបស់រាជធានីភ្នំពេញ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ គឺអាចប្រៀបធៀបបានទៅនឹងរូបបរិវត្តន៍នៅតាមបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក ដែលធ្លាប់មានកំណើនសេដ្ឋកិច្ចលឿនបំផុត។ ទស្សនាទានដែលយកទីក្រុងជាក្បាលម៉ាស៊ីននៃកំណើន[1,2] បច្ចុប្បន្ននេះ ត្រូវបានគេប្រើប្រាស់ជាទូទៅយ៉ាងទូលំទូលាយ ពីព្រោះថា រដ្ឋាភិបាលខិតខំបង្កើនឲ្យបានអប្បបរមានូវកុលានុវត្តភាពដែលផ្តល់ដោយកំណើនទីក្រុង។

បាតុភូតិដែលរោងចក្រ (ជាវិស័យប្រើកម្លាំងពលកម្មច្រើន) ចាកចេញកាន់តែច្រើនពីប្រទេសចិន និងពីបណ្តាប្រទេសអាស៊ីផ្សេងទៀតដោយសារតែប្រាក់ខែកម្មករនៅប្រទេសទាំងនោះកាន់តែខ្ពស់ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញនូវខ្សែបណ្តាញផ្គត់ផ្គង់ថ្នាក់តំបន់ បានពន្លឿនឧស្សាហកម្មភាវូបនីយកម្ម[3] ហើយបន្ទាប់មក បានពន្លឿនដំណើរការនគរូបនីយកម្មក្នុងតំបន់ជាយទីក្រុងភ្នំពេញ។ ដោយមានសមត្ថភាពផលិតក្នុងតម្លៃថោក និងមានកម្លាំងពលកម្មវ័យក្មេង ប្រទេសកម្ពុជាបានក្លាយជាគោលដៅនៃការប្តូរមកបង្កើតរោងចក្រវិនិយោគ ដែលគេចូលចិត្តជាងគេនៅក្នុងតំបន់[4] ។

ប្រទេសកម្ពុជាដើរតាមផ្លូវអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរបៀបធម្មតា មានន័យថា ភាគនៃការរួមចំណែកដល់ការបង្កើតផលិតផលក្នុងស្រុកនៃ វិស័យកសិកម្មត្រូវបានកាត់បន្ថយ ខណៈឧស្សាហកម្មកែច្នៃ និងវិស័យសេវាកម្មបច្ចុប្បន្ននេះ ស្ថិតនៅចំបេះដូងនៃកំណើនសេដ្ឋកិច្ច។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ច្រើនតែផ្តោតទៅលើតំបន់ក្រុង និងតំបន់ជាយក្រុង រីឯមូលធនផលិតកម្ម និងកំណើនទ្រព្យសកម្ម[6] នៅតាមតំបន់ជនបទមិនសូវលឿនទេ។ ទស្សនាទានសេដ្ឋកិច្ចតំបន់ទីប្រជុំជនគឺជាកត្តាពន្យល់អំពីចំណង់ចំណូលចិត្តនៃការវិនិយោគនៅក្នុងទីក្រុង មានន័យថា ផលិតកម្មទ្រព្យសម្បត្តិ និងសេវាកម្មនៅទីក្រុង គឺមានប្រសិទ្ធភាពជាងនៅ ជនបទ ហើយកន្លែងដែលមានប្រជាជនរស់នៅច្រើន គឺជាឃ្លាំងផ្តល់កម្លាំងពលកម្មប្រកបដោយគុណភាព និងខ្សែបណ្តាញសហគ្រាស ដែលប្រកបអាជីវកម្មបំពេញគ្នាទៅវិញទៅមក។ សហគ្រាសទាំងនេះ អាចដើរតួនាទី ជាអ្នកផ្គត់ផ្គង់ផង ជាប្រភពបង្កើតអតិថិជនចំនួនដ៏ច្រើនផង។ ការប្រមូលផ្តុំយ៉ាងច្រើននៃសហគ្រាសទាំងអស់នៅក្នុងតំបន់តែមួយ ក៏ជួយជម្រុញផងដែរឲ្យមានការប្រកួតប្រជែងត្រឹមត្រូវ នាំមកនូវសេវាកម្មប្រកបដោយគុណភាពនិង សម្បូរបែប ក្នុងតម្លៃកាន់តែមានតុល្យភាពថែមទៀត។

នៅក្នុងកម្រិតពិភពលោក តួលេខបង្ហាញផងដែរថា តំបន់ក្រុងបង្កើត៥៥%នៃផលិតផលជាតិសរុប នៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និង៧៣%នៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម[5]។ ភ្នំពេញប្រាកដជាទីក្រុងមួយក្នុងចំណោមបណ្តាទីក្រុង ដែលរួមចំណែកភាគច្រើនទៅក្នុងផលិតផលជាតិសរុប។ សសរស្តម្ភបីក្នុងចំណោមសសរស្តម្ភទាំងបួននៃកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ គឺមានវិស័យសំណង់ វិស័យកាត់ដេរនិងឧស្សាហកម្មកែច្នៃ វិស័យសេវាកម្ម និងវិស័យទេសចរណ៍។ វិស័យផ្តល់កំណើនទាំងនេះផ្តោតភាគច្រើនទៅលើសកម្មភាពធុរកិច្ចនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាទីក្រុងធំៗបន្ទាប់ផ្សេងទៀត។

ទីក្រុង បច្ចេកវិទ្យា និងរូបបរិវត្តន៍នៃទិន្នន័យ

បច្ចេកវិទ្យាអនុញ្ញាតឲ្យការគ្រប់គ្រងការអភិវឌ្ឍក្រុងប្រព្រឹត្តិទៅបានប្រសើរជាងមុន។ ទិន្នន័យដែលបង្កើតឡើងដោយបុគ្គល និងប្រមូលបានដោយមធ្យោបាយបច្ចេកវិទ្យាថ្មីៗ ដូចជាបណ្តាញហេដ្ឋារចនាសម្ព័ន្ធឌីជីថល ធ្វើឲ្យមានការផ្លាស់ប្តូររបៀបនៃការគ្រប់គ្រងទីក្រុង នៅក្នុងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ "បដិវត្តន៍ទិន្នន័យ" នេះ កើតឡើងជាពិសេស នៅក្នុងតំបន់ទីប្រជុំជន។ នៅភ្នំពេញ គេសង្កេតឃើញមានមជ្ឈមណ្ឌលទិន្នន័យ (ភាគច្រើនគឺជាក្រុមហ៊ុនឯកជន ដែលប្រមូលយកដោយផ្ទាល់ ឬដោយប្រយោល ឬសម្រាប់ប្រយោជន៍ឯកជន នូវទិន្នន័យពាក់ព័ន្ធនឹងអតិថិជន ឬអ្នកប្រើប្រាស់របស់ខ្លួន) ដែលគ្រប់គ្រងដោយក្រុមហ៊ុនក្នុងស្រុក ឬក្រុមហ៊ុនអន្តរជាតិ។ មានក្រុមហ៊ុនវិភាគទិន្នន័យធំៗតិចណាស់ ដែលបានជ្រៀតចូលក្នុងទីផ្សារកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ រហូតដល់បច្ចុប្បន្ននេះ "ទិន្នន័យធំ" ត្រូវបានគេប្រើប្រាស់សម្រាប់តែប្រយោជន៍ពាណិជ្ជកម្មប៉ុណ្ណោះ ភាគច្រើន គឺដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរជាងមុន អំពីឥរិយាបទរបស់អតិថិជន នៅក្នុងវិស័យពិសេសៗ ដូចជា វិស័យធនាគារ ហិរញ្ញវត្ថុ ទូរស័ព្ទ និងវិស័យដឹកជញ្ជូនជាងដើម។ ពេលនេះ ប្រហែលជាឆាប់ពេក ប្រសិនបើយើងនិយាយអំពីបដិវត្តន៍ទិន្នន័យនៅកម្ពុជា[7] ពីព្រោះថា ការប្រមូលនិងវិភាគទិន្នន័យ ទើបតែចាប់ផ្តើមប៉ុណ្ណោះ ហើយហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅមានកម្រិតនៅឡើយ។ ម្យ៉ាងទៀត ប្រព័ន្ធច្បាប់និងអភិបាលកិច្ច ទើបតែចាប់ផ្តើមមានប៉ុណ្ណោះ។ សក្តានុពលភាពនៃ "ទិន្នន័យធំ" មិនអាចត្រូវបានយកទៅប្រើប្រាស់ដោយគ្មានភាពឆ្លាតវៃសិប្បនិម្មិត និងដោយគ្មានសមត្ថភាពប្រើប្រាស់ទិន្នន័យ ផ្សារភ្ជាប់នឹងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថលចុងក្រោយឡើយ។ ប៉ុន្តែ វាគ្រាន់តែជារឿងពេលវេលាប៉ុណ្ណោះ មុននឹងទស្សនាទាន "ទីក្រុងឆ្លាតវៃ" ក្លាយជារឿងពិតគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

នវានុវត្តភាពបច្ចេកវិទ្យាធំៗ ត្រូវបានប្រើប្រាស់រួចហើយ និងបានបង្កើតសេវាកម្មក្រុងថ្មីៗទៀតផង។ ជាឧទាហរណ៍ ក្រុមហ៊ុន Grab គឺជាក្រុមហ៊ុនមួយនៅអាស៊ីអាគ្នេយ៍ ដែលបានធ្វើឲ្យទីផ្សារដឹកជញ្ជូនមានការប្រែប្រួល តាមរយៈការនាំចូលនូវបច្ចេកវិទ្យាថ្មីមួយ។ ក្រុមហ៊ុននេះបានធ្វើឲ្យរបៀបទទួលបានសេវាកម្មដឹកជញ្ជូនរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញ បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់។ មុនក្រុមហ៊ុន Grab ចូលមកដល់ មានក្រុមហ៊ុនចាប់ផ្តើមរកស៊ីនៅកម្ពុជាក្នុងវិស័យនេះតិចតួចណាស់ (មានជាអាទិ៍ ក្រុមហ៊ុន PassApp ជាក្រុមហ៊ុនខ្មែរមួយ ដែលភ្ជាប់ទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងអ្នកបើកបរ) ហើយការទទួលបានហិរញ្ញប្បទាន បច្ចេកវិទ្យា និងជំនាញ របស់ក្រុមហ៊ុន PassApp នេះ មានកម្រិតត្រឹមក្នុងស្រុក ដូច្នេះក៏នៅមានកម្រិតដែរ។

ថ្នាលបណ្តុះថ្មីៗ ដែលគាំទ្រដោយ Facebook បានបង្កើតខ្សែរបណ្តាញលក់ដូរនិងចែកចាយបន្ថែមទៀតនៅទីក្រុងភ្នំពេញ[8]។ រាល់នវានុវត្តន៍បច្ចេកវិទ្យានេះ បាននាំមកនូវរូបបរិវត្តន៍សេដ្ឋកិច្ចទីក្រុង និងឥរិយាបទសង្គមដោយបង្កើតទីផ្សារថ្មី និងបានក្លាយទៅជាដំណោះស្រាយសម្រាប់មហាជនទូទៅ ដែលភាគច្រើននៃប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងងាយនឹងទទួលបាន។ ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុកដែលបូកបញ្ចូលសហគ្រិនភាពសង្គម និងនវានុវត្តភាពបច្ចេកវិទ្យា ក៏លេចមុខឡើងនៅក្នុងទីក្រុងភ្នំពេញដែរ។ ក្រុមហ៊ុនទាំងនេះខិតខំដោះស្រាយបញ្ហាដែលបង្កឡើងដោយសារទីក្រុង តាមរយៈការកែលម្អប្រសិទ្ធភាពនៃសេវាកម្ម ដែលត្រូវបានផ្តល់ជូនហើយ ដូចជាការប្រមូលសំរាម ឬប្រព័ន្ធដឹកជញ្ជូនរួម ឬក៏ការបង្កើតសេវាកម្ម ដែលឆ្លើយតបទៅនឹងបញ្ហាថ្មីៗ ដូចជា កែលម្អសេវាដែលធ្វើឲ្យជនពិការក៏ងាយនឹងទទួលបានដូចគ្នា។ គោលដៅរបស់ក្រុមហ៊ុនទាំងនេះ មិនមែនជំនួសឲ្យសេវាសាធារណៈ ឬក៏ប្រកួតប្រជែងជាមួយក្រុមហ៊ុនឯកជននោះទេ ប៉ុន្តែក្រុមហ៊ុនទាំងនេះ ប្រតិបត្តិការនៅក្នុងចំណែកណាមួយនៃទីផ្សារ ដើម្បីដោះស្រាយបញ្ហាពិសេសៗនៅក្នុងក្រុងក្នុងតម្លៃមួយសមរម្យ ដោយអនុលោមទៅតាមគោលការណ៍នៃក្រុមហ៊ុនមានទំនួលខុសត្រូវសង្គម។

បច្ចេកវិទ្យានិងទិន្នន័យកំពុងតែអាចផ្តល់ផលជះទៅលើកាលានុវត្តភាពសេដ្ឋកិច្ច និងការកែលម្អសេវាកម្មសង្គម ដូច្នេះ ក៏រួមចំណែកដោយផ្ទាល់ទៅក្នុងសេដ្ឋកិច្ចក្រុងប្រកបដោយថាមភាពផងដែរ។ ប្រសិនបើទម្រង់ថ្មីៗនៃភេទនីយភាពក្រុង គំរាមកំហែងដល់គំរូកំណើនសេដ្ឋកិច្ចទីក្រុងភ្នំពេញ គេត្រូវលើកឡើងអំពីទំនោរធំៗ ដែលកំពុងតែកើតចេញពីរូបបរិវត្តន៍ក្រុងនេះវិញ។

ទំនោរ និងរូបបរិវត្តន៍ក្រុង

ការសាងសង់បុរីគឺជាកម្លាំងចលករមួយនៃការពង្រីកទីក្រុងភ្នំពេញ[9] ចាប់តាំងពីដំណាច់ទសវត្សរ៍ឆ្នាំ១៩៩០មក។ បុរីគឺជាទម្រង់ថ្មីមួយនៃតំបន់រស់នៅជាយក្រុង កសាងឡើងដោយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន ភាគច្រើនជាក្រុមហ៊ុនខ្មែរ។ បុរីខ្លះអនុញ្ញាតឲ្យមានការរស់នៅលាយឡំគ្នាក្នុងទីក្រុង។ ដង់ស៊ីតេប្រជាពលរដ្ឋ និងកំណើនតម្លៃដីធ្លី បូកផ្សំនឹងកំណើនអ្នកដែលមានធនធានមធ្យមក្នុងក្រុង បណ្តាលឲ្យមានការសាងសង់លំនៅដ្ឋានសម្រាប់ការរស់នៅបែបថ្មីមួយ ជាបុរីដែលមានរបងបិទជិត ហើយបុរីមានចំនួនកាន់តែច្រើនឡើង ជាពិសេស នៅតំបន់ជាយក្រុងភ្នំពេញ។ បុរីខ្លះបានក្លាយជាគម្រោងដ៏ធំ អភិវឌ្ឍលើផ្ទៃដីមួយយ៉ាងធំដែរ។ លំនៅដ្ឋានក្នុងបុរី ដែលមានរបងបិទជិតជាលក្ខណៈឯកជនទាំងនេះ ត្រូវបានគេសង្កេតឃើញមាននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ហើយជាទូទៅ ត្រូវបានគេចោទថា ជាការបង្កើត "ក្រុងអ្នកមាន" និងប្រមូលផ្តុំក្រុមគ្រួសារអ្នកមានជាងគេឲ្យរស់នៅជាមួយគ្នា ដូច្នេះ ក៏បង្កើតជាទីប្រជុំជនសម្រាប់ពួកអ្នកមាន។ នៅទីក្រុងភ្នំពេញ ក៏មានលំនៅដ្ឋានឯកជនមានលក្ខណៈបែបនេះខ្លះដែរ។ បុរីឌីហ្សាញសំណង់ផ្ទះដែលមានស្តង់ដារ មានរបងបិទជិត និងកំណត់ព្រំដីរបស់ម្ចាស់ផ្ទះនៅក្នុងសហគមន៍ មានអ្នកយាមត្រួតពិនិត្យការចេញចូល រីឯសេវាកម្មក៏មានលក្ខណៈឯកជនដែរ គ្រប់គ្រងដោយរដ្ឋបាលកណ្តាលឯកជនដែលជារបស់ម្ចាស់បុរី។ ប៉ុន្តែ បុរីខ្មែរមិនប្រាកដថាមានតែគ្រួសារអ្នកមានសុទ្ធសាធរស់នៅទេ។

ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ប៉េង ហួត ដែលនាំមុខគេនៅក្នុងទីផ្សារ បានផ្តោតសំខាន់ទៅលើគុណភាពនៃលំហសម្រាប់ការរស់នៅ ស្ថាបត្យកម្មក្នុងផ្ទះ និងបរិស្ថានជុំវិញ ព្រមទាំងលំហខាងក្រៅនិងសួនកំសាន្តទៀតផង។ ប្លង់ដើមគឺយកតាមគម្រូដែលទទួលបានជោគជ័យនៅក្នុង ការសាងសង់បុរីមានរបងបិទជិត នៅកន្លែងផ្សេងទៀត នៅអាស៊ីអាគ្នេយ៍ ប៉ុន្តែដោយសម្របទៅតាមតម្រូវការសង្គមនិងវប្បធម៌ខ្មែរ។ ភាពខុស ៗគ្នានៃប្រភេទ និងទំហំផ្ទះ ដែលផ្តល់ជូនអតិថិជន បានអនុញ្ញាតឲ្យអ្នកដែលស្ថិតនៅក្នុងវណ្ណៈ សង្គម និងមានជីវភាពខុសៗគ្នា អាចរស់នៅក្នុងទីតាំងតែមួយបាន មានន័យថា នៅក្នុងបុរីមួយមានទាំងគ្រួសារអ្នកមានខ្លាំង រហូតដល់គ្រួសារអ្នកមានធនធានមធ្យម។ ភាពខុសគ្នានៃមុខមាត់ក្នុងសង្គមរបស់ម្ចាស់ផ្ទះ មុខរបរ កម្រិតចំណូល អាយុ ជាតិសាសន៍ និងប្រភេទគ្រួសារ គឺមិនដូចគ្នាទេ ពីបុរីមួយទៅបុរីមួយ ហើយលក្ខណៈនេះ តម្រូវឲ្យមានការវិភាគ និងស្វែងយល់ឲ្យបានស៊ីជម្រៅជាងមុន។

អ្នកខ្លះអាចផ្តល់អំណះអំណាងថា ភាពខុសគ្នានៃប្រាក់ចំណូល និងទ្រព្យសម្បត្តិ គេនៅតែឃើញមាននៅក្នុងចំណោមគ្រួសាររស់នៅក្នុងបុរី ប៉ុន្តែជោគជ័យរបស់ក្រុមហ៊ុនដែលអភិវឌ្ឍបុរីទាំងនេះ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈការពង្រីកគម្រោង និងលំនៅដ្ឋានជាបន្តបន្ទាប់។ បុរីទាំងនេះ មានចេតនា និងចក្ខុវិស័យ ជានាឲ្យមានភាពចម្រុះសង្គមគ្រួសារកាន់តែប្រសើរឡើង និងផ្តល់បរិស្ថានប្រកបដោយផាសុកភាព រួមនឹងលំហបៃតងច្រើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនកម្ពុជា។ គុណភាពសេវាកម្មដែលផ្តល់ជូនម្ចាស់ផ្ទះក៏មិនដូចនៅក្នុងទីក្រុងដែរ ពោលគឺ នៅក្នុងបុរី មានភាពស្មើគ្នាជាង សេវាកម្មក៏ល្អជាង ប្រកបដោយគុណភាពសម្រាប់គ្រប់គ្រួសារ ទោះបីជាម្ចាស់ផ្ទះមានឋានៈអ្វីក្នុងសង្គមក៏ដោយ។ ច្បាប់ទម្លាប់ផ្ទៃក្នុងដែលតម្រូវឲ្យម្ចាស់ផ្ទះគោរពតាម ពិតជាជះឥទ្ធិពលទៅលើឥរិយាបទបុគ្គល និងឥរិយាបទរបស់ម្ចាស់ផ្ទះជារួម នោះគឺជាអ្វីដែលអនុញ្ញាតឲ្យគេកត់សម្គាល់ឃើញថា អ្នករស់នៅក្នុងបុរីគឺជាសហគមន៍ដែលមានការគោរពគ្នាទៅវិញទៅមក និងមានសុវត្ថិភាព។

លក្ខណៈនេះប្រហែលជាបានអនុញ្ញាតឲ្យគេយល់កាន់តែច្បាស់ជាងមុនអំពីអ្វីដែលជាសង្កាត់ខ្មែរ។ ខណៈដែលនៅក្នុងទីក្រុង គេសង្កេតឃើញកាន់តែច្រើនឡើងនូវឥរិយាបទបែបអត្តទត្តបុគ្គល ដូចជាការប្រើប្រាស់និងរំលោភលើទីតាំងសាធារណៈដើម្បីជាប្រយោជន៍ឯកជន និងការដោះស្រាយជម្លោះដោយប្រើអំណាច និងបុណ្យស័ក្តិ ផ្ទុយទៅវិញ នៅក្នុងបុរី គេបែរជាសង្កេតឃើញលេចឡើងនូវឥរិយាបទយោគយល់ទៅវិញទៅមក គិតប្រយោជន៍សាធារណៈនៅក្នុងសហគមន៍ទៅវិញ[10] ។ បញ្ហាប្រឈម គឺការរក្សា ឬបង្កើនភាពចម្រុះនៃសង្គមគ្រួសារ និងគុណភាពសេវាកម្មទៅថ្ងៃអនាគត។

Le risque majeur est d'observer, comme cela fut présenté pour Port-au-Prince, qu'une partie de la population n'ait pas droit « de cité ». Le risque est grand alors que naisse une résistance à l'exclusion. Et que la ville réelle se développe contre la ville institutionnelle, sans infrastructure.

Distribution de matériel aux sinistrés.

Distribution of equipment to victims by Phnom Penh municipality.

ការចែកចាយសម្ភារ ដល់ជនរងគ្រោះ ដោយសាលារាជធានីភ្នំពេញ

Affiche PNUD du programme de réduction de la pauvreté.

UNDP poster, support for the poverty reduction programme.

ស្លាកសញ្ញារបស់អង្គការ UNDP គាំទ្រដល់កម្មវិធីកាត់បន្ថយភាពក្រីក្រ

7
Nous ne sommes plus isolés dans le monde…

C'est sans doute le dernier enseignement : les expériences présentées nous ont montré l'importance du soutien international : bailleurs, soutien de pays tiers. L'aide internationale permet l'investissement dans les infrastructures et le démarrage de leur fonctionnement.
Dans chacun de nos exemples favorables, ce sont les partenariats qui ont permis les meilleurs progrès. Pour Christiane Blancot, c'est bien l'association de toutes les échelles, le partenariat international, local et la place accordée aux habitants qui a été la condition pour régler en grande partie le problème du logement.

concretely: the right to security, the right to do business, the right to have a home and the right to services, which require something in return. The service needs to be supplied but one's payment must also be accepted.
That was very concretely illustrated by Ek Sonn Chan who mentioned:
-- the prevention of illegal hookups,
-- a focus on the consistency of bill payments,
--the use of software tools to improve knowledge of the situation.
By the late 1990s, the situation had improved greatly: all bills were now paid.
All forms of equality must be respected, particularly gender equality, which we discussed throughout the afternoon.
Another challenge is to guarantee the poorest families access to services which requires, according to the experience shared by His Excellency Mann Choeun, proper relations between the population and administration.
As highlighted in the Port-au-Prince account, the major risk is that people could be deprived of the "right to a homeland." This brings about the risk of resistance to exclusion which could lead to development of a real city, with no infrastructures, in parallel to the institutional city.

7
We're no longer off on our own in the world

Our last lesson, without a doubt: the experiences presented show how important international support is (backers, support from other countries). International aid makes investment in infrastructure possible, getting it up and running.
In all of our positive examples, partnerships have led to progress. For Christiane Blancot, it is the combination of multiple scales (international and local partnerships and the role assigned to the people) that was the condition for settling much of the issue around housing.

8
Et demain ?

Aurons-nous besoin d'une nouvelle résilience ? À Phnom Penh, malgré la croissance, différentes questions commencent à se poser : la ville jardin se transforme en une ville dense et minérale, le remblaiement des lacs permet d'étendre la ville mais réduit les zones naturelles. De fait, en compensation, le dispositif naturel de régulation doit trouver réponse dans des solutions technologiques.
Partout dans le monde, les défis qui se posent à nous exigent des réponses inédites et une capacité d'adaptation, une lutte contre notre fragilité. Et l'échelle urbaine pourrait bien être la bonne échelle d'action, nous enseigne Natharoun Ngo.
Ne nous y trompons pas, la ville de demain, c'est d'abord la ville d'hier et celle d'aujourd'hui qui sera laissée en héritage. Elle constitue notre patrimoine qui nous interroge sur les solutions que nous mettons en avant.
La ville de demain doit être celle qui saura prendre la mesure des problèmes d'approvisionnement et de gestion des déchets, de sobriété, de confort mais aussi de cohésion et de solidarité.
Comment accueillir toutes les populations tout en offrant un bon cadre de vie, respectueux de la planète ?
Il ne suffit plus seulement de rendre des services, ni de satisfaire ponctuellement des besoins, il s'agit aussi de redonner sens, de refaire citoyenneté pour les habitants, de mobiliser leurs capabilités : participer à la ville, y vivre et s'y investir, comme l'a déclaré M. Vannak Seng, il y a quelques instants.

Nouvelles technologies, et grands équipements à Kigali.

New technologies and large amenities in Kigali.

បច្ចេកវិទ្យាថ្មីៗ និងគ្រឿងបរិក្ខាធំៗនៅទីក្រុង Kigali

Un tel agenda implique non seulement une prise de conscience mais aussi une transformation des pratiques… dont nous devons mesurer davantage les implications globales.
Quelles que soient les formes, publiques, privées, l'inclusion sociale et solidaire, les initiatives impliquent de pouvoir mieux discuter de leur but et de leurs impacts.
Les villes doivent apprendre à appréhender simultanément les problèmes et leurs effets présents et futurs. Elles ont donc intérêt à imaginer de nouvelles gouvernances, à expérimenter les moyens de leur transformation, mais aussi (peut-être surtout) à les partager.

Application mobile pour se déplacer en moto-taxis.

Mobile app for moto-taxi rides .

កម្មវិធីទូរស័ព្ទដៃសម្រាប់ហៅកង់បីជិះ

8
And tomorrow?

Is a new resilience needed? In Phnom Penh, despite the city's growth, different questions are coming to the fore: the garden city is changing into a dense, mineral city. Filling in the lakes makes it possible to expand the city but cuts down on natural areas. Indeed, to make up for that, the natural regulation system has to find its answers in technological solutions.
Around the world, the challenges before us require new answers and the capacity to adapt and overcome our own fragility. And Natharoun Ngo feels that the urban scale could well be the proper scale of action.
Let no mistake be made. Tomorrow's city is first and foremost yesterday's city. Today's city is the legacy that will be passed on. It is our heritage that is raising questions about the solutions we are putting forward.
Tomorrow's city will have to resolve issues of supply, waste management, design simplicity and comfort as well as cohesion and solidarity.
How can the city be the home of all peoples, offering a good, sustainable quality of life?
It is not simply a matter of providing services nor meeting needs as they arise. It is also a matter of restoring meaning, of rebuilding citizenship for the people, of mobilizing their abilities: getting involved in the city, living in it, and investing in it, as Vannak Seng stated a moment ago.
Such an agenda implies not only an awareness but also a transformation of practices whose global implications we will have to consider.
Whatever form they take—public, private, solidarity-based social inclusion—initiatives imply the need to discuss their purpose and impacts more holistically.
Cities must learn to simultaneously address problems and their present and future effects. They must imagine new forms of governance, experiment ways of transforming them, and (perhaps most importantly) share them.

យើងត្រូវរៀនសូត្រឲ្យក្លាយជាអ្នកមានភាពធន់

ជាសេចក្តីសន្និដ្ឋាននៃកិច្ចពិភាក្សានៅក្នុងសន្និសីទ សេចក្តីសំយោគនេះត្រឡប់មកនិយាយអំពីរបៀបដែលយើងអាចធ្វើអ្វីៗបាននៅក្នុងពិភពពមិនប្រាកដប្រជា ដើម្បីកសាងបរិស្ថានមួយដែលមានសុវត្ថិភាពជាងមុន និងផ្តល់អត្ថន័យឡើងវិញជូនប្រជាពលរដ្ឋ បន្ទាប់ពីជួបគ្រោះមហន្តរាយហើយ។

ដោយលោក Lionel Prigent

១.

យើងរស់នៅក្នុងភាពមិនប្រាកដប្រជាមួយ

ទីក្រុងន័រសុត ទីក្រុងព័រអូប្រាំងស៍ ទីក្រុងគីហ្គាលី ហើយទីក្រុងភ្នំពេញក៏ដូចគ្នាដែរ ទីក្រុងទាំងអស់នេះសុទ្ធតែបានឆ្លងកាត់វិបត្តិធំៗ តាមបែបខុសគ្នា ក្នុងកាលវេលាខុសគ្នា នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ពោលគឺវិបត្តិបណ្តាលមកពីទឹកជំនន់ រញ្ជួយដី ការសម្លាប់រង្គាលជាទ្រង់ទ្រាយធំ ឬអំពើប្រល័យពូជសាសន៍ជាដើម។

ប៉ុន្តែបច្ចុប្បន្ន ទីក្រុងទាំងនេះក៏មានសមត្ថភាពផ្តល់ជាសក្ខីកម្មអំពីស្ថានភាពដែលខ្លួនបានចាប់ផ្តើមសរសេរទំព័រថ្មីនៃប្រវត្តិសាស្ត្ររបស់ខ្លួនដែរ អំពីអ្វីដែលខ្លួនបានរៀនសូត្រពីគ្រោះមហន្តរាយទាំងនោះ។ បទពិសោធន៍ទាំងនេះបានជួយឱ្យយើង នៅក្នុងរយៈពេលពេញមួយថ្ងៃនេះពិចារណាអំពី “ទីក្រុងមានភាពធន់ ដើម្បីគិតអំពីបញ្ហាប្រឈមនៃការកសាងក្រុងឡើងវិញ”។

ប្រធានបទនេះពិតជាមានសារៈសំខាន់ណាស់។

ពិតមែនហើយ ទោះបីជាចំណេះដឹងយើងកាន់តែខ្ពស់ ទោះបីជាកិច្ចខិតខំប្រឹងប្រែងបានផ្តោតលើការអភិវឌ្ឍយ៉ាងណាក្តី ប៉ុន្តែ នៅគ្រប់ទីកន្លែងក្នុងពិភពលោក វិបត្តិអាចកើតមានឡើងនៅចំពោះមុខយើងគ្រប់ពេល៖

- វិបត្តិបរិស្ថាន វាប្រាកដណាស់ គឺពាក់ព័ន្ធនឹងអាកាសធាតុ ជីវចម្រុះ និងការគ្រប់គ្រងទឹក។
- វិបត្តិសង្គម និងការគម្រាមកំហែងសេដ្ឋកិច្ច
- និងចុងក្រោយ គឺវិបត្តិបច្ចេកវិទ្យា...ជុំវិញបញ្ហាចរាចរណ៍ទិន្នន័យ...

បច្ចុប្បន្ននេះ គ្មានប្រទេសណាមួយអាចប្រាកដថា ខ្លួនអាចជៀសផុតពីវិបត្តិមួយក្នុងចំណោមវិបត្តិទាំងនេះឡើយ។ យើងបានឮការរំឮកកាលពីព្រឹកមិញនេះហើយថា ប្រជាជន ១,៥ពាន់លាននាក់ ធ្លាប់បានឆ្លងកាត់ហានិភ័យនៃគ្រោះធម្មជាតិធំមួយរួចទៅហើយ។

យើងត្រូវរៀនឱ្យក្លាយជាអ្នកមានភាពធន់!

២.

តើអ្វីទៅជាភាពធន់?

នៅក្នុងសេចក្តីផ្តើមរបស់គាត់ លោកសាស្ត្រាចារ្យ Gabriel Fauveaud បានផ្តល់និយមន័យថា ភាពធន់គឺសមត្ថភាពរបស់ទីក្រុង និងប្រជាពលរដ្ឋដែលចេះងើបឈរឡើងវិញ បន្ទាប់ពីបានជួបប្រទះព្រឹត្តិការណ៍មហន្តរាយ។ មហន្តរាយដែលកើតឡើងពិតជាមានវិសាលភាពខ្លាំង និងបន្សល់ស្លាកស្នាមអស់រយៈពេលយ៉ាងយូរ។ ប្រជាជនដែលក្រីក្រជាងគេទទួលរងគ្រោះធំគេជាង ប៉ុន្តែគឺប្រជាជនក្រីក្រជាងគេទាំងនេះហើយដែលត្រូវខិតខំបង្ហាញថាខ្លួនមានភាពធន់ជាងគេដែរ។ ហេតុដូច្នេះហើយ នេះគឺជាលក្ខណៈសម្បត្តិមួយដែលប្រជាជនក្រីក្រត្រូវតែមាន ពីព្រោះបន្ទាប់ពីមានគ្រោះមហន្តរាយហើយ គេត្រូវមានសង្វាក់ជីវិតធម្មតាឡើងវិញ នោះគឺការកសាងឡើងវិញ។

“ធ្វើឱ្យទីក្រុងមួយដែលស្លាប់រស់ឡើងវិញ” ដូចដែលឯកឧត្តម ប៉ា សុជាតិវង្ស បានចង្អុលបង្ហាញស្រាប់។ ភាពធន់គឺជាកម្លាំងមួយនៃជីវិត គឺជាកម្លាំងដែលអនុញ្ញាតឱ្យយើងជំនះបាននូវរាល់ឧបសគ្គបង្កឡើងដោយគ្រោះមហន្តរាយដើម្បីផ្តល់ក្តីសង្ឃឹមឱ្យខ្លួនឯងឡើងវិញ ដើម្បីរស់ឡើងវិញ ប៉ុន្តែមិនមែនរស់ដូចមុនសុទ្ធសាធនោះទេ។ ភាពធន់មិនមែនជាការវិលត្រលប់ទៅរកស្ថានភាពដើមនោះទេ។ វាជាការឈានចូលទៅក្នុងស្ថានភាពថ្មីមួយ ជាការចាប់ផ្តើមថ្មីមួយ ដែលកំណត់បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលមិនធ្លាប់មានពីមុនមក។

លោកស្រី ហ្វាប៊ីយែន លុយកូ បានផ្តល់ជាឧទាហរណ៍ឆ្លុះបញ្ចាំងពីស្ថានភាពនៅរាជធានីភ្នំពេញ។ ក្រោយមហន្តរាយ នៅមានសំណង់អគារទាំងឡាយក្នុងទីក្រុងនៅឡើយ ប៉ុន្តែ ការប្រើប្រាស់សំណង់អគារទាំងនោះបានផ្លាស់ប្តូរទៅហើយ៖ វិហារកាតូលិក អតីតមណ្ឌលកុមារកំព្រា សុទ្ធតែបានក្លាយជាលំនៅដ្ឋានមានគ្រួសារច្រើនរស់នៅរួមគ្នា។

ដូច្នេះ សមត្ថភាពនេះនឹងអនុញ្ញាតឱ្យយើងគ្រប់គ្រងហានិភ័យបានល្អជាងមុន និងរៀនសូត្រពីបទពិសោធន៍អតីតកាល ដើម្បីប្រមើលមើលឱ្យបានប្រសើរជាងមុន ដល់សញ្ញាទាំងឡាយដែលប្រាប់ថាបញ្ហានឹងកើតឡើង នោះគឺសុទ្ធតែជាបញ្ហាដែលមិនធ្លាប់កើតមានឡើយ។ វាជារឿងដែលយើងត្រូវការពារខ្លួនយើងដោយយកចិត្តទុកដាក់ទៅលើការរក្សាសមត្ថភាពសម្របខ្លួន និងគិតដល់ការកសាងឡើងវិញ សំដៅទៅកាត់បន្ថយហានិភ័យឱ្យនៅតិចជាងមុន...

ហេតុដូច្នេះហើយ ការគ្រប់គ្រងហានិភ័យគឺត្រូវមានលក្ខណៈនយោបាយសង្គម និងសេដ្ឋកិច្ច ក្នុងនោះ គោលដៅចំបងគឺកាត់បន្ថយភាពទន់ខ្សោយ និងគិតទុកជាមុនពីសមត្ថភាពនៃភាពធន់...

៣.

ក្រោយគ្រោះមហន្តរាយគឺរឿងជីវិតមនុស្ស

អ្វីដែលយើងចងចាំពីសក្ខីកម្មស្តីពីមហន្តរាយដែលកើតមានឡើងនៅទីក្រុងភ្នំពេញ គឺថា មហន្តរាយពិតមានវិសាលភាពធំធេង មិនអាចវាស់វែងបាន។ ខណៈដែលភ្នំពេញមានប្រជាពលរដ្ឋ ២លាននាក់ នៅឆ្នាំ១៩៧៥ នៅសល់តែប្រជាពលរដ្ឋ ៦០នាក់ប៉ុណ្ណោះនៅក្នុងទីក្រុងខ្មោច នៅដំណាច់ឆ្នាំ១៩៧៨។ ប៉ុន្តែចាប់ពីខែមករា ឆ្នាំ១៩៧៩មក ប្រជាជនបានត្រលប់មកវិញជាបណ្តើរៗ។

លោកស្រី ហ្វាប៊ីយែន លុយកូ បានត្រលប់មកទីក្រុងភ្នំពេញក្នុងនាមជានរវិទូសិក្សាអំពីការវិលត្រលប់មកវិញរបស់ប្រជាពលរដ្ឋ និងអំពីលក្ខខណ្ឌនៃការវិលត្រលប់របស់ពួកគេនោះ។ ភាពធន់គឺជារឿងពាក់ព័ន្ធនឹងប្រជាជនដែលបានតាំងទីលំនៅដ្ឋាន ចាត់ចែងបញ្ហានៅក្នុងស្ថានភាពដែលខ្លួនជួបប្រទះ ដើម្បីរកជម្រកឱ្យមានសុវត្ថិភាព និងប្រមែប្រមូលកម្លាំងឡើងវិញ។

អ្នកម្នាង ស៊ីសុវត្ថិ ម៉ែន ច័ន្ទទេវី បានរៀបរាប់ប្រកបដោយភាពក្តុកក្តួលអំពីអនុស្សាវរីយ៍របស់អ្នកម្នាង ថា “ជាក្មេងស្រីម្នាក់នៅទីក្រុងភ្នំពេញក្នុងទសវត្សរ៍ឆ្នាំ១៩៨០” មិនដូចការរស់នៅកន្លែងផ្សេងទៀតទេ។ អ្នកម្នាងបានរៀបរាប់ប្រាប់យើងអំពីការរស់នៅប្រចាំថ្ងៃ ដើម្បីត្រដររស់ និងការត្រលប់ចូលមកភ្នំពេញវិញក្នុងស្ថានភាពដ៏លំបាកលំបិន អ្នកម្នាងនៅចងចាំនៅឡើយអំពីជម្លោះ និងពីទុក្ខលោកដែលជម្លោះនោះបានបង្កឡើងចំពោះគ្រប់ក្រុមគ្រួសារទាំងអស់។ ការលំបាកក៏ពាក់ព័ន្ធផងដែរទៅនឹងកង្វះខាតចំណីអាហារ ការលំបាកក្នុងស្វែងរកទិញចំណីអាហារ និងការលំបាកក្នុងការកៀរគរមនុស្សម្នាដើម្បីរៀបចំធ្វើការឡើងវិញ។ និយាយឱ្យចំទៅ ចាប់ពីពេលគ្រោះមហន្តរាយបានបញ្ចប់ទៅ ការកសាងឡើងវិញមុនដំបូងបង្អស់គឺជារឿងរបស់ប្រជាពលរដ្ឋទាំងស្រីទាំងប្រុស។

៤.

ជីវិត ហើយគ្មានអ្វីផ្សេងទេឬ?

ជីវិតតែងតែចាប់ផ្តើមសារជាថ្មី!!! ប្រវត្តិសាស្ត្ររបស់មនុស្សជាតិតែងតែប្រាប់យើងអំពីការកសាងឡើងវិញមិនអាចអាក់ខានបាន បន្ទាប់ពីបានឆ្លងកាត់គ្រោះមហន្តរាយហើយ។ ប៉ុន្តែភាពធន់មិនមែនមានន័យថា ធានាឱ្យមានលក្ខខណ្ឌរស់នៅប្រសើរជាងមុនទេនៅក្នុងអនាគត។

នៅក្នុងកិច្ចប្រជុំក្រុមទី១ ផ្តើមចេញពីបទពិសោធន៍របស់លោកនៅទីក្រុងព័រអូប្រាំងស៍ លោក ហ្សង់ម៉ារី តេអូដា បានរំឭកឡើងវិញឱ្យយើងដឹងអំពីការគម្រាមកំហែងជាច្រើនដែលនៅតែជាទម្ងន់នៅឡើយ បន្ទាប់ពីគ្រោះមហន្តរាយ។

ចំណែកឯលោកស្រី ហ្វាប៊ីយែន លុយកូ វិញ លោកស្រីបានពន្យល់ពីការលំបាកក្នុងការរស់នៅសារជាថ្មីក្នុងជីវភាពប្រចាំថ្ងៃ ក្នុងការគ្រប់គ្រងផ្នែករួមនៅក្នុងអគារ ក៏ដូចជាការគ្រប់គ្រងទីតាំងសាធារណៈ ដែលគេតែងតែបំពានយកជាញឹកញាប់។ គេត្រូវខិតខំប្រឹងប្រែងក្នុងការងាររៀបចំ ដើម្បីឆ្លងឱ្យផុតពីដំណាក់កាលត្រដររស់... នៅពេលនោះហើយទើបតួនាទីរបស់ស្ថាប័នានាទោះនៅក្នុងទម្រង់មួយណាក្តី ក្លាយជារឿងចាំបាច់ ដើម្បីរៀបចំក្នុងរយៈពេលវែង...

លោកសាស្ត្រាចារ្យ ហ្សង់ម៉ារី តេអូដា បានបង្ហាញពីភាពចម្រូងចម្រាស់ជាមួយរដ្ឋពិតជាខ្លាំងដល់កម្រិតណា ពីអវត្តមានសមត្ថភាពនិយ័តកម្មធ្វើឱ្យប៉ះពាល់យ៉ាងណាដល់លទ្ធភាពឆ្លងឱ្យផុតពីដំណាក់កាលបន្ទាប់ពីមានវិបត្តិ។

៥.

លក្ខខណ្ឌចាំបាច់សម្រាប់ការកសាងឡើងវិញមួយពិតប្រាកដ

ដូច្នេះ ត្រូវមានកិច្ចខិតខំប្រឹងប្រែងពីប្រជាពលរដ្ឋ ទាំងប្រុស ទាំងស្រីគ្រប់រូបហើយក៏ត្រូវមានពេលវេលាផងដែរ។ លោកស្រី គ្រីស្សាន ប្លង់កូ បានរំឭកឡើងវិញដូច្នេះថា៖ ភ្នំពេញបានរង់ចាំអស់រយៈពេល២០ឆ្នាំ ទើបជួបលក្ខខណ្ឌល្អក្នុងការកសាងឡើងវិញ។ ការណ៍នោះធ្វើឱ្យអគារទាំងឡាយធ្លាក់ក្នុងសភាពកាន់តែធ្ងន់ធ្ងរខ្លាំងឡើង ដោយសារការរង់ចាំអស់រយៈពេល ២០ឆ្នាំកន្លងទៅបន្ទាប់ពីពួកខ្មែរក្រហមបានដួលរលំ។ គេត្រូវរង់ចាំដល់មានមនុស្សជំនាន់ថ្មីមួយទៀត ទើបមានការលេចឡើងនៅទីក្រុងភ្នំពេញ នូវវប្បធម៌នៃការរស់នៅបែបក្រុង។

ការកសាងទីក្រុងមួយឡើងវិញ គឺត្រូវផ្តល់ជូនទីក្រុងនោះ រាល់មុខងារទាំងឡាយណា ដែលជាមុខងាររបស់ទីក្រុង តាមរយៈសេដ្ឋកិច្ចទីក្រុង នេះគឺជាពាក្យសេដ្ឋកិច្ចដែលប្រើដោយលោក ង៉ោ ណាត្តរុន៖

- ជាទីកន្លែងបដិសណ្ឋារកិច្ចមួយ ដែលនៅក្នុងនោះ ប្រជាពលរដ្ឋមករក ការការពារ លំនៅដ្ឋាន ការងារ និងអនាគត
- ជាកន្លែងមួយមានផ្សារ ដែលនៅក្នុងនោះ ប្រជាពលរដ្ឋ និង ក្រុមហ៊ុននានាអាចរកបាននូវធនធាន និងសេវាកម្មដែលគេចង់បាន
- ជាកន្លែងមួយដែលមានចរាចរណ៍ មានន័យថា តម្រូវឱ្យមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- ជាកន្លែងមួយផលិតទ្រព្យសម្បត្តិ និងផ្តល់សេវាកម្មពាណិជ្ជកម្ម
- ចុងក្រោយ គឺជាកន្លែងមួយដែលធានាឱ្យមានការអប់រំ សុខាភិបាល វប្បធម៌។ល។

ដើម្បីធានាឱ្យមានការកសាងឡើងវិញពិតប្រាកដ ទិដ្ឋភាពរចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម គឺជារឿងចាំបាច់។

ទិដ្ឋភាពរចនាសម្ព័ន្ធ

ខណៈដែលឯកឧត្តម ម៉ុក ម៉ារ៉េត បានលើកឡើងអំពីកិច្ចការត្រូវធ្វើបន្ទាន់ភ្លាមបន្ទាប់ពីមានវិបត្តិ ឯកឧត្តម កែប ជុតិម៉ា បានបកស្រាយអំពីភាពចាំបាច់ដែលត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធនានាឡើងវិញ។ “ទីក្រុងមួយដែលគ្មានទឹក គ្មានភ្លើង គឺប្រៀបដូចជាជីវិតមួយដែលគ្មានស្នេហា”។ នៅក្នុងឧទាហរណ៍ជាក់ស្តែងមួយ ឯកឧត្តម ឯក ស៊ុនចាន់ បានសង្កត់ធ្ងន់ទៅលើស្ថានភាពនៃការស្តារឡើងវិញនូវប្រព័ន្ធទឹកស្អាត។ ប៉ុន្តែឯកឧត្តមក៏បានគូសបញ្ជាក់ផងដែរថា តើការខិតខំប្រឹងប្រែងកសាងឡើងវិញនោះបានជួបប្រទះបញ្ហាអ្វីខ្លះ ដោយសារតែការលួចតទឹកខុសច្បាប់កាន់តែច្រើនឡើង... ប្រាក់ចំណូលក៏ជាបញ្ហាមួយដែរ ពីព្រោះ វិក្កយបត្រមួយចំនួនមិនត្រូវបានបង់នោះទេ ដោយសារតែកំហុសបញ្ជីឈ្មោះ និងបញ្ហាពុករលួយ។ល។ នៅត្រង់ចំណុចនេះ គឺមានភាពប្រទាញប្រទង់គ្នារវាងការខិតខំរបស់ស្ថាប័ន ដែលត្រូវតែមានទ្រង់ទ្រាយធំក្នុងការផ្តល់សេវាកម្មបម្រើប្រជាពលរដ្ឋទាំងអស់គ្នា និងការស្វែងរកផលប្រយោជន៍របស់បុគ្គល ដែលក្នុងនោះ បុគ្គលម្នាក់ដូចជាគ្មានផលប៉ះពាល់អ្វីធំដុំនោះទេប៉ុន្តែ បើបុគ្គលច្រើនបញ្ចូលគ្នានឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងទាំងមូលនៃការកសាងឡើងវិញ...

ទិដ្ឋភាពសេដ្ឋកិច្ច

ទិដ្ឋភាពសេដ្ឋកិច្ចក៏មិនត្រូវធ្វេសប្រហែសនោះដែរ។ នៅក្នុងភាពធន់សេដ្ឋកិច្ចក៏ជាកត្តាហានិភ័យមួយដែរ។ យើងបានឮតាមបែបខុសៗគ្នាប្រើ ននៅក្នុងពេលពេញមួយថ្ងៃនេះថា៖ទិដ្ឋភាពនេះគឺមានន័យថា តម្រូវឱ្យមានឧបករណ៍ផលិតកម្ម ដែលអាចឱ្យមនុស្សធ្វើការបាននៅក្នុងវិស័យផលិតកម្ម មិនមែនត្រឹមតែធ្វើតែពាណិជ្ជកម្មនោះទេ! នេះគឺជាអ្វីដែលត្រូវបានរាយការណ៍កាលពីព្រឹកមិញថែមទាំងរំឭកឡើងវិញថា កម្ពុជាបានក្លាយជាប្រទេសមួយទទួលបានការអនុគ្រោះពាណិជ្ជកម្មពីដៃគូររបស់ខ្លួន ដែលអនុញ្ញាតឱ្យកម្ពុជាចូលរួមក្នុងការផ្លាស់ប្តូរពាណិជ្ជកម្មពិភពលោក និងចូលរួមក្នុងខ្សែរសង្វាក់ផលិតកម្មទ្រព្យសម្បត្តិ។

នៅពេលដែលជនភៀសខ្លួនបានត្រលប់មកវិញជាបណ្តើរៗ អាជ្ញាធរត្រូវរកការងារឱ្យពួកគេធ្វើ ដើម្បីឱ្យពួកគេមានលទ្ធភាពចិញ្ចឹមជីវិត។

នៅឆ្នាំ២០០៤ មានរោងចក្រជាង៣០០កន្លែងត្រូវបានសាងសង់ឡើងនៅទីក្រុងភ្នំពេញ និងមានកម្មករ កម្មការនីធ្វើការក្នុងរោងចក្រជាង២០ម៉ឺននាក់។ ហើយបើនិយាយដល់កម្រិតប្រទេសវិញ កិច្ចសន្យានៃការអនុវត្តល្អៗចុះហត្ថលេខាជាមួយអង្គការពលកម្មអន្តរជាតិ គឺជាសន្យាចាំបាច់ ដើម្បីធានាឱ្យមានការគោរពស្តង់ដារនៃលក្ខខណ្ឌការងារ និងស្តង់ដារផ្តល់ប្រាក់កម្រៃដល់កម្មករកម្មការនី។

ប៉ុន្តែ ទម្រង់ផ្សេងទៀតនៃសេដ្ឋកិច្ចដែលមានលក្ខណៈនវានុវត្តន៍ ត្រូវបានលើកឡើងជុំវិញសេដ្ឋកិច្ចបៃតង និយាយពីក្រុមហ៊ុនតូចៗដែលចាប់ផ្តើមថ្មី និងពីវិនិយោគិនសង្គម ។
ទាំងនេះហើយគឺជាបទពិសោធន៍ដែលបានលើកឡើងដោយលោក Hassan Hajam។

៦.

ទិដ្ឋភាពសង្គម

គេត្រូវប្តូរវប្បធម៌ និងមានការយោគយល់អំពីក្តីរំពឹងទុក រួមគ្នា។ ធ្វើឱ្យមានភាពស៊ីសង្វាក់គ្នា... នោះគឺជាអ្វីដែលលោកស្រី Nadine Umunoti Gatsinzi បានរំឭកយើងឡើងវិញពីអ្វីដែលពាក់ព័ន្ធនឹងទីក្រុងគីហ្គាលី។ ដើម្បីធ្វើការកសាងឡើងវិញឱ្យបានត្រឹមត្រូវ គេត្រូវកសាងសន្តិភាពជាមួយអតីតកាល។ហើយបទពិសោធន៍ទាំងឡាយពិតជាមានប្រយោជន៍។ បទពិសោធន៍ប្រទេសអង់ហ្គោឡា ពិតជាមានប្រយោជន៍ដើម្បីជាភ្លើងបំភ្លឺអំពីលក្ខខណ្ឌនៃការកសាងសន្តិភាព និងបង្រួបបង្រួមជាតិ ដែលប្រទេស រ៉ូវ៉ាន់ដាបានអនុវត្តនៅទូទាំងប្រទេស។

កសាងសន្តិភាព បង្រួបបង្រួមជាតិ ប្តេជ្ញាឱ្យមានបរិយាកាសមួយស្ងប់ស្ងាត់ជាងមុន រក្សាស្ថិរភាព ទាំងនេះសុទ្ធតែជាលក្ខខណ្ឌចាំបាច់នានាដែលតម្រូវឱ្យមានសកម្មភាពជាក់ស្តែង ពោលគឺសិទ្ធិមានសុវត្ថិភាព សិទ្ធិធ្វើពាណិជ្ជកម្មសិទ្ធិទទួលបានលំនៅដ្ឋាន...និងសិទ្ធិទទួលបានសេវាកម្ម ប៉ុន្តែក៏មិនអាចខ្វះការយល់ព្រមផ្តល់ជូនវិញដែរនោះទេ មានន័យថា ពេលទទួលបានសេវាកម្ម គឺត្រូវព្រមបង់ថ្លៃសេវាកម្មនោះផង។

នេះគឺជាអ្វីដែលឯកឧត្តម ឯក ស៊ុនចាន់ បានរំឭកឡើងវិញក្រោមទម្រង់រឿងរ៉ាវជាក់ស្តែងដូចខាងក្រោម៖

- ការប្រយុទ្ធប្រឆាំងនឹងការតទឹកខុសច្បាប់
- ធ្វើឱ្យប្រជាពលរដ្ឋបង់វិក្កយបត្រឱ្យបានត្រឹមត្រូវ
- ប្រើប្រាស់ឧបករណ៍ពត៌មានវិទ្យាដើម្បីកែលម្អចំណេះដឹងអំពីស្ថានភាព

ចាប់តាំងពីដំណាច់ឆ្នាំ១៩៩០មក ស្ថានភាពមានភាពប្រសើរឡើង ពោលគឺវិក្កយបត្រទាំងអស់ត្រូវបានបង់យ៉ាងត្រឹមត្រូវ។

ប៉ុន្តែយើងក៏ត្រូវយកចិត្តទុកដាក់ផងដែរ លើការគោរពរាល់ទម្រង់នៃសមភាពជាពិសេសគឺ សមភាពយែនឌ័រ ដែលជាចំណុចមួយត្រូវបានលើកឡើងពេញមួយរសៀលនេះតែម្តង។ បញ្ហាមួយទៀតគឺធ្វើយ៉ាងណាធានាឱ្យគ្រួសារក្រីក្រជាងគេទទួលបានសេវាកម្មផ្សេងៗផងដែរ... ធ្វើយ៉ាងណាឱ្យមានទំនាក់ទំនងរវាងប្រជាជន និងរដ្ឋាភិបាល នេះបើតាមបទពិសោធន៍ដែលផ្តល់ជូនដោយឯកឧត្តម ម៉ាន់ ឈឿន ។

ហានិភ័យធំ គឺនៅពេលគេសង្កេតឃើញ ដូចឧទាហរណ៍បង្ហាញជូនអំពីក្រុង ព័រអូប្រាំងស៍ ស្រាប់ថា មួយផ្នែកនៃប្រជាជនគ្មានសិទ្ធិរស់នៅក្នុងទីក្រុង។ហានិភ័យពិតជាធំ នៅពេលដែលមានការមិនព្រមទទួលយកនូវការផាត់ចេញណាមួយនោះ និងនៅពេលដែលទីក្រុងជាក់ស្តែងត្រូវបានអភិវឌ្ឍផ្ទុយពីទីក្រុងស្ថាប័ន ដោយគ្មានហេដ្ឋារចនាសម្ព័ន្ធ។

៧.

យើងមិននៅឯកោក្នុងពិភពលោកទៀតទេ...

នេះប្រហែលជាចំណុចចុងក្រោយដែលយើងបានរៀនសូត្រ៖ បទពិសោធន៍ដែលត្រូវបានចែករំលែក បានបង្ហាញអំពីសារៈសំខាន់នៃការជួយជ្រោមជ្រែងពីអន្តរជាតិ រួមមានស្ថាប័ន និងប្រទេសផ្តល់ជំនួយ ការជួយជ្រោមជ្រែងពីប្រទេសទីបី។ ជំនួយអន្តរជាតិអនុញ្ញាតឱ្យប្រទេសមួយធ្វើការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឱ្យប្រទេសចាប់ផ្តើមដំណើរការឡើងវិញ។ នៅក្នុងឧទាហរណ៍ដែលយើងពេញចិត្តនីមួយៗ គឺភាពជាដៃគូរទាំងឡាយដែលអនុញ្ញាតឱ្យមានការរីកចម្រើនខ្លាំង។ សម្រាប់លោកស្រី គ្រីស្សាន ប្លង់កូ គឺការពួតដៃគ្នានៅក្នុងគ្រប់កម្រិតទាំងអស់ រួមមានដៃគូអន្តរជាតិ ដៃគូមូលដ្ឋាន និងការផ្តល់តម្លៃដល់ប្រជាពលរដ្ឋ សុទ្ធតែជាលក្ខខណ្ឌសមប្រកបសម្រាប់ការដោះស្រាយបញ្ហាធំៗមួយចំនួនពាក់ព័ន្ធនឹងលំនៅដ្ឋាន។

៨.

ហើយចុះអនាគត?

តើយើងនឹងត្រូវការភាពធន់ថ្មីមួយឬទេ ? នៅភ្នំពេញ ទោះបីជាមានកំណើនក្តី សំណួរជាច្រើនចាប់ផ្តើមចោទឡើងហើយ៖ ទីក្រុងមានសួនច្រើនបានប្រែក្លាយជាទីក្រុងដែលមានមនុស្សរស់នៅកកកុញ និងមានសំណង់អគារច្រើនការលុបបឹងអនុញ្ញាតឱ្យគេពង្រីកទីក្រុង ក៏ប៉ុន្តែកាត់បន្ថយតំបន់ធម្មជាតិ។

ជាក់ស្តែង ដើម្បីបំពេញកង្វះចន្លោះលើកការបាត់បង់ផ្ទៃតំបន់ធម្មជាតិដែលមានតួនាទីធ្វើនិយ័តកម្មសារជាតុបំពុលតាមបែបធម្មជាតិ គេត្រូវស្វែងរកចម្លើយនៅក្នុងដំណោះស្រាយបច្ចេកវិទ្យា។ នៅគ្រប់ទីកន្លែងក្នុងពិភពលោក បញ្ហាប្រឈមដែលចោទឡើងចំពោះយើងគឺតម្រូវឱ្យមានដំណោះស្រាយដែលមិនធ្លាប់មានពីមុនមក និងតម្រូវឱ្យមានសមត្ថភាពសម្របខ្លួន ការប្រយុទ្ធប្រឆាំងនឹងងភាពទន់ខ្សោយរបស់យើង។ហើយទីក្រុងគួរតែមានទំហំដែលអនុញ្ញាតឱ្យគេងាយធ្វើសកម្មភាពជាក់ស្តែង នេះជាអ្វីដែលលោក ង៉ោ ណាត្តរុន បានប្រាប់យើង។

សូមកុំច្រឡំឱ្យសោះ ទីក្រុងទៅថ្ងៃអនាគត គឺជាទីក្រុងកាលពីអតីតកាលនិងទីក្រុងបច្ចុប្បន្ន ដែលយើងនឹងទទួលជាកេរ្តិ៍មរតក។ ទីក្រុងនេះនឹងជាបេតិកភណ្ឌរបស់យើង ដែលធ្វើឱ្យយើងចោទជាសំណួរអំពីដំណោះស្រាយដែលយើងត្រូវរកឱ្យឃើញ។ ទីក្រុងទៅថ្ងៃអនាគតត្រូវតែជាទីក្រុងមួយដែលដោះស្រាយឱ្យបានរាល់បញ្ហាផ្គត់ផ្គង់ បញ្ហាគ្រប់គ្រងកាកសំណល់ ភាពកខ្វក់ ផាសុកភាព ប៉ុន្តែក៏ត្រូវតែជាទីក្រុងដែលមានសុខដុមរមណីកម្មរវាងប្រជាពលរដ្ឋ និងសាមគ្គីភាពគ្នាដែរ។

តើត្រូវទទួលយកប្រជាជនគ្រប់គ្នាយ៉ាងដូចម្តេច ទទ្ទឹមនឹងការផ្តល់ជូនពួកគេនូវក្របខណ្ឌល្អសម្រាប់ការរស់នៅ ដោយគោរពចំពោះភពផែនដី ?

វាមិនគ្រប់គ្រាន់ទៀតទេ ដោយគ្រាន់តែផ្តល់សេវាកម្ម ឬក៏បំពេញតាមតម្រូវការម្តងម្កាលនោះ គេក៏ត្រូវផ្តល់ឡើងវិញផងដែរនូវអត្ថន័យជីវិត ធ្វើឱ្យប្រជាពលរដ្ឋក្លាយជាពលរដ្ឋល្អ កៀរគរសមត្ថភាពរបស់ពួកគេឱ្យចូលរួមជាមួយទីក្រុងរស់នៅក្នុងទីក្រុង វិនិយោគខ្លួនឯងក្នុងទីក្រុង ដូចដែលលោក សេង វណ្ណៈ បានលើកឡើងកាលពីប៉ុន្មាននាទីមុននេះ។ របៀបវារៈបែបនេះមិនត្រឹមតែតម្រូវឱ្យមានការយល់ដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតម្រូវឱ្យផ្លាស់ប្តូររបៀបនៃការអនុវត្តកន្លងមកទៀតផង... ហើយដែលយើងត្រូវវាស់វែងច្រើនជាងមុននូវការពាក់ព័ន្ធជាសកលនៃការអនុវត្តទាំងនោះ។

ទោះជាទម្រង់ណាក្តី រដ្ឋឬឯកជន បរិយាប័ន្នភាពសង្គមនិងសាមគ្គីភាព គំនិតផ្តួចផ្តើមនានា តម្រូវឱ្យមានការពិភាក្សាខ្លាំងជាងមុនអំពីគោលបំណង និងផលជះនៃការអនុវត្តទាំងនោះ។

ទីក្រុងត្រូវរៀនយល់អំពីបញ្ហានានា និងផលប៉ះពាល់នៃបញ្ហាទាំងនោះនាពេលបច្ចុប្បន្ន និងទៅអនាគត ក្នុងពេលតែមួយ។ ហេតុដូច្នេះ ទីក្រុងគួរតែពិចារណារកអភិបាលកិច្ចថ្មី ដកបទពិសោធន៍លើមធ្យោបាយនៃការកែច្នៃអភិបាលកិច្ចថ្មីៗទាំងនោះ ប៉ុន្តែ (ហើយអាចថា ជាពិសេសទៅទៀតនោះ គឺ) ត្រូវចែករំលែកបទពិសោធន៍ទាំងនោះដែរ។

Biographies / Bibliographies

CHRISTIANE BLANCOT, architecte, est directrice d'études à l'Atelier parisien d'urbanisme. Elle travaille sur le développement urbain de Phnom Penh depuis 1990 dans le cadre de la coopération Paris-Phnom Penh.

CHRISTIANE BLANCOT is an architect and director of studies at *Atelier parisien d'urbanisme*. She has been working on Phnom Penh's urban development since 1990, under a long term cooperation framework signed between Paris and Phnom Penh.

S.E. EK SONN CHAN a dirigé la Régie des Eaux de Phnom Penh de 1993 à 2012. Aujourd'hui il est ministre délégué attaché au Premier ministre.

H.E. EK SONN CHAN was director of Phnom Penh Water Supply Authority from 1993 to 2012 and led a successful transformation that became a best practice in water management around the globe. Presently, he works as a Vice-Minister reporting to the Prime Minister of the Kingdom of Cambodia.

DR. GABRIEL FAUVEAUD est docteur en géographie et en études urbaines de l'université Paris I Panthéon-Sorbonne (2013). Il est enseignant-chercheur dans le département de géographie et le Centre d'Asie du Sud-Est de l'Université de Montréal.

DR. GABRIEL FAUVEAUD is a teacher and researcher in the Geography Department and the Southeast Asia Centre at University of Montreal. He holds a PhD in geography and urban studies from University Paris I Panthéon-Sorbonne (2013).

HASSAN HAJAM travaille dans le domaine de l'économie sociale et solidaire. Il a mis au point un modèle d'incubateur pour aider à la promotion de commerces sociaux. Il est directeur administratif de Platform Impact, une société de conseil pour le développement de l'entrepreneuriat social en Asie du Sud-Est.

HASSAN HAJAM is an impact investment expert and Executive director of Platform Impact, an advisory firm supporting Social Entrepreneurship and Socially Responsible Investing projects across Southeast Asia. Graduated from Compiegne University of Technology with a Master of Science, double majoring in Engineering and Innovation Management.

HUN CHANSAN est architecte diplômé de la Northeastern University de Boston. Il a créé Re-edge architecture/design en 2011. Il vit et travaille à Phnom Penh où il enseigne aussi comme professeur ou professeur invité dans plusieurs universités de Phnom Penh.

HUN CHANSAN is the founder of Re-Edge Architecture / Design. He graduated with a Master of Architecture from North-eastern University in Boston in 2009. He also teaches in several universities in Phnom Penh.

S.E. KEP CHUKTEMA est député du Parlement du Royaume du Cambodge. Il a été gouverneur de la province de Kampot puis de Phnom Penh de 2003 à 2013 et de de 2008 à 2013 puis conseiller personnel du Premier Ministre Samdech Techo Hun Sen avec rang de ministre.

H.E. KEP CHUKTEMA has been a Member of Parliament of the Kingdom of Cambodia since 2018. He was Governor of Phnom Penh from 2003 to 2013, and then personal advisor to the Prime Minister with ministerial rank.

DR. FABIENNE LUCO est docteure en anthropologie sociale de l'Ecole des Hautes études en Sciences Sociales (EHESS-Paris) et chercheuse associée au CASE (Centre ASIE du Sud-Est/UMR 8170 - EHESS-CNRS-INALCO). Elle vit au Cambodge depuis 1993. Elle a travaillé pour plusieurs agences des Nations Unies au Cambodge.

DR. FABIENNE LUCO holds a PhD in social anthropology from Ecole des Hautes Études en Sciences Sociales (EHESS-Paris) and is an associate researcher at CASE (Southeast Asia Centre/UMR 8170 - EHESS-CNRS-INALCO). She has lived in Cambodia since 1993 and has worked for several UN agencies in Cambodia.

S.E. MANN CHOEUN est sénateur du parlement du Royaume du Cambodge depuis 2015. Après 1979, il a été responsable du planning stratégique de la ville de phnom Penh puis, à partir de 1992, chef de cabinet de la Municipalité de Phnom Penh avant de devenir vice-gouverneur de Phnom Penh de 2005 à 2010.

H.E. MANN CHOEUN has been a Senator of the Kingdom of Cambodia since 2015. After 1979, he oversaw strategic planning for Phnom Penh City Hall and then, from 1992, head of cabinet of Phnom Penh City Hall before becoming Vice-Governor of Phnom Penh from 2005 to 2010.

S.E. DR MOK MARETH est député du parlement du Royaume du Cambodge en tant que député depuis 2013. Il a été vice-gouverneur de Phnom Penh de 1979 à 1988, puis de 1988 à 1992, vice-ministre de l'Agriculture, et ministre de l'Environnement de 2003 à 2013.

H.E. DR MOK MARETH has been a Member of Parliament of the Kingdom of Cambodia since 2013. He was Vice-Governor of Phnom Penh from 1979 to 1988, then Vice-Minister of Agriculture from 1988 to 1992, and Minister of the Environment from 2003 to 2013.

M. NATHAROUN NGO est directeur du Centre des études khmères (CKS), centre de recherche indépendant créé en 1999 au Cambodge.
Il est diplômé de l'université de Paris XII Val de Marne et de la Harvard Kennedy School. Il a travaillé de 2008 à 2016 au sein du Programme des Nations Unies pour le Développement (PNUD) au Cambodge.

MR. NATHAROUN NGO is Director of the Center for Khmer Studies (CKS). Prior to joining the research center in Cambodia, Natharoun worked for the United Nations Development Program and for global business consulting firms. He holds an MBA from University Paris XII Val de Marne (1999), and an MPA from the Harvard Kennedy School (2015).

LIONEL PRIGENT est urbaniste et économiste, chercheur et professeur à l'Institut de Géoarchitecture (Université de Brest) où il dirige le Master Aménagement et Urbanisme. Ses recherches portent sur les politiques publiques et leurs effets pour le développement, l'habitat, le tourisme et l'environnement.

LIONEL PRIGENT is an urbanist and economist, researcher and professor at the Institut de Géoarchitecture (University of Brest) where he runs a Master programme in Spatial Planning and Urbanism. His research focuses on public policies and their effects on development, habitat, tourism and the environment.

S.E. PA SOCHEATVONG est président du Conseil de Phnom Penh Capitale. Il est aussi conseiller personnel de Samdech Akka Moha Sena Padei Techo Hun Sen, Premier ministre du Cambodge. De 1996 à 2013, il a été vice-gouverneur de Phnom Penh puis gouverneur jusqu'en 2017.

H.E. PA SOCHEATVONG is Chairman of Phnom Penh Capital. He is also personal adviser to the Prime Minister of Cambodia. From 1996 to 2013, he was Vice-Governor of Phnom Penh, then Governor until 2017.

SENG VANNAK est directeur de l'administration de la Municipalité de Phnom Penh depuis 2018 après avoir été directeur adjoint du service de la gestion urbaine Il est architecte, diplômé de l'Ecole Nationale Supérieure d'Architecture de Paris Malaquais.

SENG VANNAK has been Director of the administration of Phnom Penh City Hall since 2018, after being Deputy-Director of the Urban Management Department. He is an architect, a graduate of the Paris Malaquais Advanced National School of Architecture.

DR. SISOWATH MEN CHANDÉVY est docteure en architecture, vice-rectrice et professeure de l'Université Royale des Beaux-Arts de Phnom Penh où elle enseigne et dirige les formations en archéologie, architecture et protection du patrimoine bâti.

DR. SISOWATH MEN CHANDÉVY holds a PhD in architecture. She is Vice-Rector and professor at the Royal University of Fine Arts in Phnom Penh, where she teaches and heads courses in Archaeology, Architecture and Protection of Heritage.

S.E. DR THONG KHON est ministre du Tourisme du Royaume du Cambodge depuis 2007. Après 1979 il a été chef de cabinet du Bureau de la municipalité de Phnom Penh, puis en 1983, vice-gouverneur avant de devenir gouverneur de 1985 à 1990.

H.E. DR THONG KHON has been Minister of Tourism of the Kingdom of Cambodia since 2007. After 1979, he was head of cabinet in the Office of Phnom Penh City Hall. He then became Vice-Governor in 1983, and Governor from 1985 to 1990.



DR JEAN-MARIE DULIX THÉODAT est agrégé et docteur de géographie de l'Université de Paris I Sorbonne. Il est maître de conférences à l'Université Paris I Panthéon-Sorbonne où il a enseigné la politique, l'économie et la géographie culturelle de 1998 à 2010. Il vit à Haïti depuis 2010 où Il est professeur à l'université d'Etat.

DR JEAN-MARIE DULIX THÉODAT is an *agrégé* and holder of a PhD in geography from University Paris I Sorbonne. He is senior lecturer at University Paris I Panthéon-Sorbonne, where he taught politics, economics and cultural geography from 1998 to 2010. Since 2010, he has lived in Haiti, where he is a professor at the State University.

NADINE UMUTONI GATSINZI est vice maire chargée des affaires socio –économique de la ville de Kigali. Elle a été auparavant, secrétaire générale du ministère de la promotion de l'égalité des sexes et de la Famille.

NADINE UMUTONI GATSINZI is Vice-Mayor in charge of socio-economic affairs for the City of Kigali. She was previously Secretary-General of the Ministry of Gender and Family Promotion.

ជីវប្រវត្តិ

លោកស្រី **CHRISTIANE BLANCOT** ជាស្ថាបត្យករ និងជានាយិកានៃការសិក្សារបស់អង្គភាពនគររូបនីយកម្មក្រុងប៉ារីស ហៅកាត់ថា APUR។ លោកស្រីធ្វើការពាក់ព័ន្ធនឹងការអភិវឌ្ឍក្រុងភ្នំពេញ តាំងពីឆ្នាំ១៩៩០ នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការរវាងទីក្រុងប៉ារីស និងទីក្រុងភ្នំពេញ។

ឯកឧត្តម **ឯក ស៊ុនចាន់** បានដឹកនាំរដ្ឋករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១២។ បច្ចុប្បន្ននេះ ឯកឧត្តមជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។

លោកបណ្ឌិត **GABRIEL FAUVEAUD** គឺជាបណ្ឌិតខាងផ្នែកភូមិសាស្ត្រនិងការសិក្សាអំពីទ្រីកុង នៅសាកលវិទ្យាល័យ Paris I Panthéon-Sorbonne (ឆ្នាំ២០១៣)។ លោកជាសាស្ត្រាចារ្យ និងជាអ្នកសិក្សាស្រាវជ្រាវ នៅដេប៉ាតឺម៉ង់ភូមិវិទ្យា និងនៅមជ្ឈមណ្ឌលអាស៊ីអាគ្នេយ៍នៃសាកលវិទ្យាល័យ-Montréal ។

លោក **HASSAN HAJAM** ធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចសង្គម និងសាមគ្គីភាព។ លោកបានបង្កើតគំរូនៃការបង្កើតក្រុមហ៊ុនថ្មីដើម្បីជួយលើកស្ទួយសេដ្ឋកិច្ចសង្គម។ លោកគឺជានាយករដ្ឋបាលនៃថ្នាលដែលមានឈ្មោះថា Platform Impact គឺជាក្រុមហ៊ុនមួយផ្តល់ប្រឹក្សាខាងផ្នែកអភិវឌ្ឍន៍សប្រាគិនភាពសង្គមនៅអាស៊ីអាគ្នេយ៍។

លោក **ហ៊ុន ចាន់សាន** គឺជាស្ថាបត្យករទទួលសញ្ញាប្រ័តពីសាកលវិទ្យាល័យ Northeastern University ក្រុងបូស្តុន។ លោកបានបង្កើតក្រុមហ៊ុន Re-edge ស្ថាបត្យកម្មនិងឌីហ្សាញ នៅឆ្នាំ២០១១។រស់នៅក្នុងទីក្រុងភ្នំពេញ លោកធ្វើការជាសាស្ត្រាចារ្យ ឬជាសាស្ត្រាចារ្យផ្តល់បាឋកថានៅតាមសកលវិទ្យាល័យជាច្រើននៅទីក្រុងភ្នំពេញ។

ឯកឧត្តម **កែប ជុតិមា** គឺជាសមាជិករដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមធ្លាប់ធ្វើជាអភិបាលខេត្តកំពត បន្ទាប់មក ជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៣ និងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ បន្ទាប់មក ជាទីប្រឹក្សាផ្ទាល់របស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋមន្ត្រី។

លោកស្រីបណ្ឌិត **FABIENNE LUCO** គឺជាបណ្ឌិតខាងផ្នែកនរវិទ្យាសង្គម នៃសាលាសិក្សាជាន់ខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រសង្គម ដែលហៅកាត់ថា EHESS នៅទ្រីកុងប៉ារីស និងជាអ្នកសិក្សាស្រាវជាវនៅវិទ្យាស្ថានអាស៊ីអាគ្នេយ៍ដែលហៅកាត់ថា CASE នៃវិទ្យាស្ថានជាតិភាសា និងអរិយធម៌បូព៌ា ហៅកាត់ថា INALCO។ លោកស្រីរស់នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៣។ លោកស្រីបានបម្រើការជូនភ្នាក់ងារនៃអង្គការសហប្រជាជាតិជាច្រើន នៅប្រទេសកម្ពុជា។

ឯកឧត្តម **ម៉ាន់ ឈឿន** គឺជាសមាជិកព្រឹទ្ធសភាពនៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ២០១៥មក។ បន្ទាប់ពីឆ្នាំ១៩៧៩ ឯកឧត្តមបានទទួលខុសត្រូវលើការងារធ្វើផែនការកម្មយុទ្ធសាស្ត្រនៃទីក្រុងភ្នំពេញ បន្ទាប់មក ចាប់ពីឆ្នាំ១៩៩២ ឯកឧត្តមជានាយកខុទ្ទកាល័យនៃសាលារាជធានីភ្នំពេញ មុននឹងក្លាយជាអភិបាលរងរាជធានីភ្នំពេញ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០។

ឯកឧត្តម បណ្ឌិត **ម៉ុក ម៉ារ៉េត** គឺជាសមាជិករដ្ឋសភាពជាតិនៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ២០១៣។ ឯកឧត្តម ធ្លាប់កាន់តួនាទីជាអភិបាលរងក្រុងភ្នំពេញ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៨ បន្ទាប់មក ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩២ ឯកឧត្តមជាអនុរដ្ឋមន្ត្រីក្រសួងកសិកម្ម និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៣។

លោក **ង៉ោ ណាត្តរុន** គឺជានាយកមជ្ឈមណ្ឌលខេមរសិក្សា ដែលជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវឯករាជ្យមួយ បង្កើតឡើងនៅឆ្នាំ១៩៩៩ នៅកម្ពុជា។ លោកទទួលបានសញ្ញាប័ត្រពីសាកលវិទ្យាល័យ Paris XII នៅក្រុង Val de Marne និងពីសាកលវិទ្យាល័យ Harvard Kennedy School ។ លោកបានធ្វើការ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៦ ជូនអង្គការ UNDP ជាកម្មវិធីអង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍនៅកម្ពុជា។

លោកបណ្ឌិត **LIONEL PRIGENT** គឺជានគររូបនីយករនិងជាអ្នកសេដ្ឋកិច្ច អ្នកសិក្សាស្រាវជ្រាវនិងជាសាស្ត្រាចារ្យនៅវិទ្យាស្ថាន Géoarchitecture នៃសាកលវិទ្យាល័យ Brest ។ លោកធ្វើជាគ្រូបង្គោលដឹកនាំនិស្សិតថ្នាក់អនុបណ្ឌិត ខាងផ្នែករៀបចំក្រុងនិងនគរូបនីយកម្ម។ ការសិក្សាស្រាវជ្រាវរបស់លោកផ្តោតទៅលើគោលនយោបាយសាធារណៈ និងផលជះនៃគោលនយោបាយទាំងនោះ ទៅលើការអភិវឌ្ឍលំនៅដ្ឋាន ទេសចរណ៍ និងបរិស្ថាន។

ឯកឧត្តម **ប៉ា សុជាតិវង្ស** គឺជាប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ។ ឯកឧត្តមក៏ជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០១៣ ឯកឧត្តមធ្លាប់ធ្វើជាអភិបាលរងរាជធានីភ្នំពេញ បន្ទាប់មក ឯកឧត្តមបានកាន់តួនាទីជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រហូតដល់ឆ្នាំ២០១៧។

លោក **សេង វណ្ណៈ** គឺជានាយករដ្ឋបាលសាលារាជធានីភ្នំពេញ តាំងពីឆ្នាំ២០១៨មក បន្ទាប់ពីលោកបានធ្វើជានាយករងការិយាល័យនគររូបនីយកម្ម។ លោកជាស្ថាបត្យករទទួលសញ្ញាប័ត្រពីសាលាជាតិជាន់ខ្ពស់ស្ថាបត្យកម្មក្រុងប៉ារីស Malaquais។

អ្នកម្នាងបណ្ឌិត **ស៊ីសុវត្ថិ ម៉ែន ចាន់ទេវី** គឺជាបណ្ឌិតខាងផ្នែកស្ថាបត្យកម្ម ជាសាកលវិទ្យាធិការរង និងជាសាស្ត្រាចារ្យនៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ រាជធានីភ្នំពេញ។ អ្នកម្នាងបណ្ឌិត បង្រៀន និងដឹកនាំការងារបណ្តុះបណ្តាលខាងផ្នែកបុរាណវិទ្យា ស្ថាបត្យកម្ម និងការពារបេតិកភណ្ឌសំណង់។

ឯកឧត្តមបណ្ឌិត **ថោង ខុន** គឺជារដ្ឋមន្ត្រីក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ២០០៧។ ក្រោយឆ្នាំ១៩៧៩ ឯកឧត្តមបានធ្វើជានាយកខុទ្ទកាល័យសាលាក្រុងភ្នំពេញ បន្ទាប់មក នៅឆ្នាំ១៩៨៣ ឯកឧត្តម ធ្វើជាអភិបាលរងសាលាក្រុងភ្នំពេញ មុននឹងក្លាយជាអភិបាលនៃគណៈអភិបាលក្រុងភ្នំពេញ ពីឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩០។

លោកបណ្ឌិត **JEAN-MARIE DULIX THÉODAT** គឺជាសាស្ត្រាចារ្យ និងជាបណ្ឌិតខាងផ្នែកភូមិវិទ្យានៃសកលវិទ្យាល័យ Paris I Sorbonne។ លោកបណ្ឌិតគឺជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យ Université Paris I Panthéon-Sorbonne បង្រៀនខាងផ្នែកនយោបាយសេដ្ឋកិច្ច និងភូមិសាស្ត្រវប្បធម៌ ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១០។ លោករស់នៅក្នុងប្រទេសហៃទីតាំងពីឆ្នាំ២០១០មក។ នៅក្នុងប្រទេសហៃទី លោកធ្វើជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យរដ្ឋ។

លោកស្រី **NADINE UMUTONI GATSINZI** គឺជាអភិបាលរងក្រុងគីហ្គាលី ទទួលបន្ទុកកិច្ចការ សង្គម និងសេដ្ឋកិច្ច។ ពីមុន លោកស្រីគឺជាអគ្គលេខាធិការនៃក្រសួងលើកស្ទួយសមភាពយេនឌ័រ និង គ្រួសារ។

Bibliographie / Bibliography / គន្ថនិទ្ទេស

Kigali

Crisafulli, P. and Redmond, A. (2012), *Rwanda, Inc.: How a Devastated Nation Became an Economic Model for the Developing World,* Palgrave Macmillan in the US-division of St. Martin's Press.

Goodfellow, T. & Smith, A. (2013) *From urban catastrophe to 'model'city? Politics, security and development in post-conflict Kigali.* Urban studies, 50 (15), 3185-3202.

Michelon, B. (2008) *Kigali: Une urbanisation entre modernisation et réconciliation* (N°. ARTICLE, pp. p-33).

Port-au-Prince

Barthélémy, G. (1997) *L'univers rural haïtien. Le pays en-dehors.* L'Harmattan, Paris.

Chaléard, J-L, (2014) dir. Métropoles aux Suds. *Le défi des périphéries*. Karthala, Paris.

Châtaignier J-M. Magro, (2007) Hervé, dir. États et sociétés fragiles. *Entre conflits, reconstruction et développement.* Éditions Karthala, Paris.

Clastres, P. (1974) *La société contre l'État*, Éditions de Minuit, Paris.

Croix-Rouge Internationale. (2014) *World Disasters Report. Focus on culture and risk.*

EMMUS, (2014) *Enquête sur la Mortalité, la Morbidité et l'Utilisation des Services*, Port-au-Prince.

Fabiani, J-L. (1987) Theys, Jacques, dir. *La société vulnérable*. Presses de l'ENS, Paris.

Lamaute, E. (1999) *Le vieux Port-au-Prince. Une tranche de la vie haïtienne*. Illustré.[1939], publié par les Éditions Henri Deschamps, Port-au-Prince.

Lucien, G-E. (2013) *Une modernisation manquée, Port-au-Prince 1915-1956*. Éditions de l'Université d'État d'Haïti.

Nora, P. (1984) Dir. *Les lieux de mémoire*, Gallimard, parid.

Prépetit, C. *La menace sismique en Haïti. Hier, aujourd'hui et demain. Pour que la menace ne soit plus oubliée.* Éditions de l'Université d'État d'Haïti, 2011.

Seitenfus, R. (2015) *L'échec de l'aide internationale à Haïti. Dilemmes et égarements.* Éditions de l'Université d'État d'Haïti, Port-au-Prince.

Théodat, J-M. (2008) *L'autre pays en dehors : le pays lòtbòdlo.* Conjonction, Port-au-Prince,

Théodat, J-M. (2009) *L'eau dans l'Etat, l'Etat nan dlo* : crise urbaine et dilution des responsabilités publiques dans l'aire métropolitaine de Port-au-Prince. Bulletin de l'Association des Géographes Français, Paris.

Théodat, J-M. (2011) *Haïti, pouvoir, nature et culture. In Conjonction, Le séisme du 12 janvier 2010 en Haïti*. n° 223, pp71-80. Port-au-Prince, 2011.

Théodat, J-M. (2013) *Port-au-Prince en sept lieux*, in *Haiti, Sichuan, Fukushima, États d'urgence.* Paris Outre Terre, numéros 35 et 36, janvier 2013.

Phnom Penh

Blancot, C. et Goldblum, C. (1994) *Phnom Penh – Seconde vie d'une capitale d'Asie du Sud-est. Regards d'urbanistes.* In: Bizot F (ed) Recherches nouvelles sur le Cambodge. Paris : Ecole Française d'Extrême Orient, pp.315-349.

Blancot, C. (2003) *Phnom Penh centre ancien*, in Phnom Penh à l'aube du XXIe siècle, Paris, Phnom Penh, Venise, programme ASIA URBS, APUR, pp. 72-79.

Blancot, C. (2009), *Phnom Penh, des extensions rapides et dispersées, in* Croissance et transformation, Municipalité de Phnom Penh, Ville de Paris, Atelier parisien d'urbanisme, APUR, pp.12-17.

Brickell, K., & Springer, S. (Eds.). (2016). *The handbook of contemporary Cambodia*. Taylor & Francis.

Carrier, A., (2019), *Phnom Penh privatisée : la propriété à l'usage de la coutume*, Cahiers de Péninsule, Irasec.

Carrier, A. (2007) «*Les lois de la possession» à Phnom Penh: conversion des droits d'usage résidentiel issus du contexte socialiste de réappropriation urbaine (1979-1989) en droits de propriété*. Paris 8.

Chandler, D. (2018). *A history of Cambodia*. Routledge.

Clément-Charpentier, (2008), *Mort et Renaissance d'une capitale : Phnom Penh victime des Khmers rouges,* in Géographie et culture, n° 65, pp. 91-110.

Clerc, V. et Rachmuhl, V. (2008) *Les marchés fonciers et immobiliers des quartiers informels à Phnom Penh.* Groupe de recherche et d'échanges technologiques (GRET).

Daravuth L and Muan I (2001) *Cultures of Independence: An Introduction to Cambodian Arts and Culture in the 1950's and 1960's.* Art Media Resources Ltd.

Fauveaud, G. (2015) *La production des espaces urbains à Phnom Penh : pour une géographie sociale de l'immobilier*. Publications de la Sorbonne.

Gerles, F. (2008) *L'économie cambodgienne. In* : Forest A (ed) *Cambodge contemporain.* Bangkok-Paris : IRASEC/Les Indes Savantes, pp.189-256.

Goldblum, C. (2012) *Phnom Penh ou la métropolisation dépendante: entre processus d'urbanisation et stratégie d'aménagement. In*: Franck M, Goldblum C and Taillard C (eds) Territoires de l'urbain en Asie du Sud-Est. Métropolisations en mode mineur. Paris: Éditions du CNRS, pp.25-73.

Hughes, C. (2003) *The political economy of the Cambodian transition.* Routledge.

Khieu Kanharith (1997), *1979, les premiers jours du nouveau Phnom Penh*, in Phnom Penh développement urbain et patrimoine, Paris, Ministère de la Culture – Atelier parisien d'urbanisme, APUR, p 50-53.

Luciolli E. (1988), *le mur de bambou*, Paris, ed Régine Deforges.

Mysliwiec, E. (1988), "*Punishing the poor – the international isolation of Kampuchea*." Oxfam.

Nam, S. (2011). Phnom Penh: From the politics of ruin to the possibilities of return. *Traditional Dwellings and Settlements Review*, 55-68.

Népote, J. et De Vienne, M-S. (1993) *Cambodge, Laboratoire d'une crise, bilan économique et prospective.* Paris : CHEAM.

Percival, T. and Waley, P. (2012) *Articulating Intra-Asian Urbanism: The Production of Satellite Cities in Phnom Penh.* Urban Studies 49(13): 2873-2888.

Shatkin, G. (1998) '*Fourth World'cities in the global economy: the case of Phnom* Penh, Cambodia. In International Journal of Urban and Regional Research 22(3): pp. 378-393.

Slocomb Margaret, (2003), *the people's Republic of Kampuchea 1979-1989, the revolution after Pol Pot, Chiang Mai,* Silkwork books.

Saphan, L. (2007). *Renaissance des espaces publics à Phnom Penh : processus d'appropriations urbaines et dynamiques de la citadinité des nouveaux habitants de la capitale cambodgienne* (Doctoral dissertation, Paris 10).

Simone, A. (2008) *The politics of the possible: Making urban life in Phnom Penh.* Singapore Journal of Tropical Geography 29(2): 186-204.

Vann Molyvann (2003) *Modern Khmer Cities.* Phnom Penh: Reyum.

Phnom Penh/ Habitat

Halgand, M.P. (2003), *une ville nouvelle au nord de Phnom Penh ?* in Phnom Penh à l'aube du XXIe siècle, Paris, Phnom Penh, Venise, programme ASIA URBS, Apur, pp. 57-61

Pen Khon, (2000) *Phnom Penh Before and after 1997*, Raksmey Kampuchea Newspaper

Phnom Penh Millennium Development Goals 2009, support the Decentralization and Deconcentration Policy, Improve Good Governance and Local Development. 2009.

Pen Khon, (2001) *Samdech Hun Sen and the Resettlement of the Poor*,

Urban Poor Development Fund (UPDF), (May 2003) *News about Some of the Recent Activities of the Urban Poor Development Fund in Cambodia* (Khmer version).

Urban Poor Development Fund (UPDF), (May 2008), *News about Some of the Recent Activities of the Urban Poor Development Fund in Cambodia,*

Royal Government of Cambodia, (2010), *Circular on Resolution on Temporary Settlement on Land which Has Been Illegally Occupied in the Capital,* Municipal and Urban Areas, N° 03, May 31. 2010.

Royal Government of Cambodia, (May 09 2014), *National Policy on Housing*, Royal Government of Cambodia, approved by Council of Ministers on published by MLMUPC.

Royal Government of Cambodia, (October 24, 2017), *National Policy on the Encouragement and Development of National Programs for Affordable Housing Development Policy.*

Urban Poor Development Fund (UPDF), (September 2019), *News about Some of the Recent Activities of the Urban Poor Development Fund in Cambodia*.

La ville résiliente

Directeur de publication :
Pierre Baillet

Conception graphique :
Shannon/design dept.

Photogravure :
Open graphic, Bagnolet

Traductions :
John Crisp,
Lim Bunhok,
Rebecca Oudin-Shannon

Photographie de couverture :
Kanel Khiev

Photographies non créditées dans l'ouvrage :
Atelier Parisien d'Urbanisme

Edition :
Association Internationale des Maires Francophones
9 Rue des Halles
Paris 75001 France

Paris, Mai 2020

Resilient cities

Managing Editor:
Pierre Baillet

Graphic Design:
Shannon/design dept.

Color separation:
Open graphic, Bagnolet

Translators:
John Crisp,
Lim Bunhok,
Rebecca Oudin-Shannon

Cover Photograph:
Kanel Khiev

Photos without credits in the text:
Atelier Parisien d'Urbanisme

Published by:
Association Internationale des Maires Francophones
9 Rue des Halles
Paris 75001 France

Paris, May 2020

ទីក្រុងប្រកបដោយភាពធន់៖

នាយកនៃការបោះពុម្ពផ្សាយ៖
ឯកឧត្តម Pierre Baillet

រចនាដោយ៖
Shannon/design dept.

ផ្តិតរូបថតចេញពីហ្វីលដោយ៖
Open graphic, Bagnolet

បកប្រែដោយ៖
លោក John Crisp
លោក លីម ប៊ុនហុក
លោកស្រី Rebecca Oudin-Shannon

រូបថតលើគម្របមុខ៖
លោក ខៀវ កាណែល

រូបថតមិនបញ្ជាក់កម្មសិទ្ធិ
ប្រើក្នុងស្នាដៃនេះ៖
Atelier Parisien d'Urbanisme

បោះពុម្ពផ្សាយដោយ៖
សមាគមអន្តរជាតិនៃអភិបាលក្រុងនិយាយភាសាបារាំង (AIMF)
9 Rue des Halles
Paris 75001 France

ទីក្រុងប៉ារីស ខែឧសភា ឆ្នាំ២០២០